# ទីស្ដីការគណៈរដ្ឋមន្ត្រី
## អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស

# សៀវភៅស
# ស្ដីពី
# ស្ថានការណ៍នយោបាយនៅកម្ពុជា
## «ការពង្រឹងនីតិរដ្ឋ និង ដំណើរការលទ្ធិប្រជាធិបតេយ្យ»

ថ្ងៃព្រហស្បតិ៍ ៨រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៨




# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមនៃប្រជាជាតិខ្មែរ

«ប្រជាធិបតេយ្យពិតប្រាកដនៅកម្ពុជាមិនដើរថយក្រោយ ឬធ្លាក់ចុះឡើយ ផ្ទុយទៅវិញ កំពុងត្រូវបានថែរក្សា និងពង្រឹងឱ្យកាន់តែរឹងមាំឡើង ដើរស្របជាមួយគោលការណ៍នីតិរដ្ឋ នៅក្នុងផលប្រយោជន៍របស់ជាតិ និងប្រជាជនកម្ពុជា។ មានតែប្រជាធិបតេយ្យក្លែងក្លាយទេ ដែលត្រូវបានលុបបំបាត់»

# មាតិកា

**សេចក្តីសង្ខេប** ........ i
**១. សេចក្តីផ្តើម** ........ ១
**២. មូលដ្ឋានគ្រឹះនៃការពង្រឹងនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ** ........ ៥
២.១. ការកសាងស្ថាប័ន ........ ៥
២.២ .ការកសាងក្របខ័ណ្ឌច្បាប់ ........ ១២
២.៣ .ការអនុវត្តច្បាប់ ........ ១៥
២.៤ .ការរៀបចំការបោះឆ្នោត ........ ១៦
២.៥. ការធានាសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ........ ១៨
**៣ .កិច្ចសហប្រតិបត្តិការអន្តរជាតិនិងសមាហរណកម្មក្នុងតំបន់** ........ ៣១
**៤ .បដិវត្តន៍ពណ៌** ........ ៣៥
៤.១. ការកកើតបដិវត្តន៍ពណ៌នៅក្នុងប្រទេសមួយចំនួន ........ ៣៥
៤.២. ចលនាបដិវត្តន៍ពណ៌នៅកម្ពុជា ........ ៤១
៤.២.១. គម្រោងការបដិសេធលទ្ធផលបោះឆ្នោត ........ ៤៣
៤.២.២. ស្ថានការណ៍នៅថ្ងៃបោះឆ្នោត ........ ៤៩
៤.២.៣. ស្ថានការណ៍ក្រោយថ្ងៃបោះឆ្នោត ........ ៥៥
៤.២.៤. ដំណោះស្រាយបណ្តឹងតវ៉ា ........ ៦៦
៤.២.៥. ការបញ្ចប់ពហិការបស់គណបក្សប្រឆាំង ........ ៦៧
៤.៣. បរាជ័យនៃបដិវត្តន៍ពណ៌នៅកម្ពុជា ........ ៦៩
**៥. ការពង្រឹងនីតិរដ្ឋ និងការធានាសណ្តាប់ធ្នាប់សង្គម** ........ ៧៩
**៦. សកម្មភាពក្រុមប្រឆាំងក្រៅច្បាប់** ........ ៨១
**៧. ធម្មានុរូបភាពនៃចំណាត់ការនិងវិធានការរបស់រាជរដ្ឋាភិបាល** ........ ៨៥

៧.១. លទ្ធិប្រជាធិបតេយ្យ ........................................................................................ ៨៦
៧.២. សិទ្ធិមនុស្ស.................................................................................................... ៨៨
៧.៣. សេរីភាពសារព័ត៌មាន ......................................................................................... ៩៣
៧.៤. អង្គការសង្គមស៊ីវិល ........................................................................................... ៩៨
៧.៥. ការធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ.......................... ១០១
៧.៦. ការចាប់ខ្លួន កឹម សុខា ...................................................................................... ១០៥
៧.៧. ការរំលាយគណបក្សសង្គ្រោះជាតិ....................................................................... ១០៨
៧.៨. ការគំរាមលុបភាពអនុគ្រោះពន្ធសម្រាប់ទំនិញកម្ពុជានាំចូលអឺរ៉ុប............ ១១២
៧.៩. គម្រោងរឹតត្បិតទិដ្ឋាការនិងការបង្កកទ្រព្យសម្បត្តិ ........................... ១១៣
៧.១០. ការផ្តាច់ជំនួយ និងបុរេវិនិច្ឆ័យសម្រាប់ការបោះឆ្នោតឆ្នាំ២០១៨......១១៤

# សេចក្ដីសង្ខេប

ប្រវត្តិសាស្ត្របង្ហាញថា កម្ពុជាបានឆ្លងកាត់ដំណាក់កាលនៃសង្គ្រាម និងការផ្លាស់ប្ដូររបបគ្រប់គ្រងរដ្ឋជាបន្តបន្ទាប់ ដែលកើតឡើងដោយមូលហេតុជាច្រើន រួមមានការដណ្ដើមភូមិសាស្ត្រនយោបាយ ការប្រកួតប្រជែងមនោគមវិជ្ជា ការជ្រៀតជ្រែកពីមហាអំណាច ជម្លោះដណ្ដើមទឹកដី និងការដណ្ដើមអំណាចផ្ទៃក្នុង របបប្រល័យពូជសាសន៍។ តាមរយៈអាជ្ញាធរបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) កម្ពុជាបានរៀបចំការបោះឆ្នោតសកលលើកទី១ នៅឆ្នាំ១៩៩៣ ក្រោយសង្គ្រាមស៊ីវិលអស់ជាង ២ទសវត្សរ៍។

ដោយសារពួកឧទ្ទាមខ្មែរក្រហមបានធ្វើពហិកាការបោះឆ្នោត សង្គ្រាមស៊ីវិលនៅតែបន្តលើទឹកដីកម្ពុជា រហូតដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ ដែលជាថ្ងៃរចនាសម្ព័ន្ធនយោបាយ និងយោធារបស់ខ្មែរក្រហម ត្រូវបានបញ្ចប់តាមរយៈនយោបាយឈ្នះ-ឈ្នះរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។

រដ្ឋធម្មនុញ្ញកម្ពុជាដែលបានអនុម័តនៅឆ្នាំ១៩៩៣ បានរួមបញ្ចូលនូវខ្លឹមសារសំខាន់ៗនៃកិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩១ ស្ដីពីដំណោះស្រាយនយោបាយនៅកម្ពុជា និងបានបង្កើតស្ថាប័ននីតិប្បញ្ញត្តិ ដែលមានរដ្ឋសភា និងព្រឹទ្ធសភា ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នតុលាការ ក្រុមប្រឹក្សាធម្មនុញ្ញ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្ថាប័នព័ត៌មាន អង្គការសង្គមស៊ីវិល និងគណបក្សនយោបាយ។

ក្នុងរយៈពេលតែ២០ឆ្នាំចុងក្រោយ កម្ពុជាសម្រេចបាននូវសមិទ្ធផលជាច្រើន ប៉ុន្តែក្រុមប្រឆាំងនៅតែព្រងើយកន្តើយ និងមិនទទួលស្គាល់នូវសមិទ្ធផលទាំងនេះទេ។ ផ្ទុយទៅវិញ ក្រុមនេះតែងតែចោទនិងប្រឌិតរឿងបំផ្លើសការពិត ដើម្បីធ្វើឱ្យមានការយល់ច្រឡំនិងបំផុសគំនិតអវិជ្ជមាន ដល់

សាធារណជនខ្មែរនិងបរទេស អំពីការដឹកនាំរបស់រាជរដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលប្ដេជ្ញាចិត្តរៀបចំស្ថាប័នរដ្ឋ កសាងក្របខ័ណ្ឌច្បាប់ អនុវត្តច្បាប់ ធានាសន្តិភាពនិងស្ថិរភាពនយោបាយ និងអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដែលជាមូលដ្ឋានគ្រឹះនៃការពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។

សេដ្ឋកិច្ចកម្ពុជាបានសម្រេចកំណើនយ៉ាងឆាប់រហ័ស ដោយរក្សាអត្រាជាមធ្យម៧% ដែលត្រូវបានចាត់ទុកថា ជាប្រទេសមានកំណើនខ្ពស់ដោយធនាគារពិភពលោក និងជាខ្លាសេដ្ឋកិច្ចថ្មីមួយនៅអាស៊ី។ កំណើនដ៏រឹងមាំនៃផលិតផលសរុបក្នុងស្រុក (ផ.ស.ស.) ធ្វើឱ្យចំណូលមធ្យមសម្រាប់មនុស្សម្នាក់កើនឡើងដល់ ១ ៤៣៥ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ ធៀបនឹងឆ្នាំ ២០១០ សម្រាប់មនុស្សម្នាក់មានត្រឹមតែ៨៣០ដុល្លារអាមេរិកប៉ុណ្ណោះ។ អត្រាភាពក្រីក្រនៅកម្ពុជាមានចំនួន១០០% នៅឆ្នាំ១៩៧៩ ហើយធ្លាក់ចុះមកត្រឹម១៣,៥% នៅឆ្នាំ២០១៤។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ជាមួយកំណើនសេដ្ឋកិច្ច ប្រាក់បៀវត្សអប្បបរមារបស់មន្ត្រីរាជការបានកើនឡើងបីដង។ ចំណែកប្រាក់បៀវត្សរបស់កម្មករ កម្មការិនីនៅកម្ពុជា មានចំណាត់ថ្នាក់ទី៥ ធៀបនឹងប្រាក់បៀវត្សរបស់កម្មករ កម្មការិនី នៅប្រទេសចំនួន១៣ក្នុងតំបន់អាស៊ី ដោយមិនគិតអំពីអត្ថប្រយោជន៍ដទៃទៀត ក្រៅពីប្រាក់បៀវត្ស។

កម្ពុជាបានរៀបចំការបោះឆ្នោតជាទៀងទាត់ តាមអាណត្តិដែលកំណត់ដោយរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ទាំងការបោះឆ្នោតសកលនិងអសកលរួមមាន ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺប្រព្រឹត្តទៅ

ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ពុំមានការគំរាមកំហែង និងការភ័យខ្លាច ដែលបានបង្ហាញឱ្យឃើញអំពីការវិវឌ្ឍជាវិជ្ជមាន នៃការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ដោយឡែក ចំពោះការបោះឆ្នោតសកលឆ្នាំ២០១៣ គឺជាការបោះឆ្នោតដែលមានព្រឹត្តិការណ៍ពិសេស ទាក់ទងនឹងចលនាបដិវត្តន៍ពណ៌ ដោយសារមេដឹកនាំគណបក្សសង្គ្រោះជាតិ រួមជាមួយអង្គការសង្គមស៊ីវិលមួយចំនួន ដែលមានការឃុបឃិតជាមួយបរទេស បានប្រើល្បិចកលប្រឌិតបំផ្លើស បំភ័ន្ត និងបង្កការរំខាន នៅថ្ងៃបោះឆ្នោតនិងក្រោយថ្ងៃបោះឆ្នោត។ ចលនានេះបានបរាជ័យ ដោយខ្វះការគាំទ្រពីមហាជន ដោយវិធានការទប់ស្កាត់របស់រាជរដ្ឋាភិបាលបានទាន់ពេលវេលា ហើយដោយមានការចូលរួមពីគ្រប់សមត្ថកិច្ចពាក់ព័ន្ធ សំដៅពង្រឹងសណ្តាប់ធ្នាប់សាធារណៈនិងនីតិរដ្ឋ ដើម្បីការពារអាយុជីវិតប្រជាជន ទ្រព្យសម្បត្តិសាធារណៈនិងឯកជន ពីការបំផ្លាញដោយកម្លាំងកុបកម្ម ដែលវិវត្តមកពីបាតុកម្មអហិង្សា។

បដិវត្តន៍ពណ៌ឬបដិវត្តន៍ដោយអំណាចមហាជន គឺជាចលនាបះបោរតាមរយៈបាតុកម្មអហិង្សា ហើយប្រែក្លាយទៅជាកុបកម្ម ដោយមានការជួយរៀបចំនិងផ្តល់មធ្យោបាយហិរញ្ញវត្ថុ ពីប្រទេសមហាអំណាចនិងសម្ព័ន្ធមិត្ត ក្រោមលេសលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស ក្នុងគោលដៅផ្តួលរំលំមេដឹកនាំប្រទេស ដែលមិនព្រមបម្រើផលប្រយោជន៍ដល់ប្រទេសមហាអំណាចនិងសម្ព័ន្ធមិត្ត ទោះបីជាប្រទេសគោលដៅនោះមានលទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស ឬគ្មានក៏ដោយ។ ឧបករណ៍ឃោសនាដ៏មានប្រសិទ្ធភាពគឺបណ្តាញសារព័ត៌មាននិងបណ្តាញទំនាក់ទំនងសង្គម និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលបានដើរតួនាទីស្នូលជួយគណបក្សប្រឆាំង ក្នុងការចែកចាយព័ត៌មានដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ដែលមានចរិតប្រឌិតបំផ្លើសរឿង បញ្ឆេះកំហឹង បង្កើនការស្អប់ឬប្រឆាំងនឹងរដ្ឋអំណាច ជាដើម។

ចលនាបដិវត្តន៍ពណ៌ត្រូវបានបរាជ័យយ៉ាងធ្ងន់ធ្ងរនៅកម្ពុជា ទោះបីជាមានការបណ្តុះបណ្តាលកម្លាំង ជួយរៀបចំកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រ និងការផ្តល់មធ្យោបាយហិរញ្ញវត្ថុ ពីមហាអំណាចនិងសម្ព័ន្ធមិត្តសម្រាប់ផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ ដោយមានតួអង្គជាអង្គការមិនមែនរដ្ឋាភិបាលនិងស្ថានទូតបរទេសមួយចំនួនជាទីបង្អែកក៏ដោយ។ ទោះបីជាចលនាបដិវត្តន៍ពណ៌ត្រូវបានបរាជ័យ ហើយគណបក្សប្រឆាំងត្រូវបង្ខំចិត្តចូលសភាក៏ដោយ ក៏ចលនានោះមិនទាន់បានបញ្ចប់នៅឡើយទេ ពីព្រោះក្រុមប្រឆាំងនិងសកម្មជនទាំងនេះ នៅតែចិញ្ចឹមមហិច្ឆតាបន្តធ្វើបដិវត្តន៍ពណ៌តទៀត តាមរូបភាពផ្សេងៗ ដូចជាការបង្កើតចលនាខុសច្បាប់ និងការឃោសនាទុច្ចរិតនានា នៅក្នុងនិងក្រៅប្រទេស ជាដើម។

បដិវត្តន៍ពណ៌មិនមែនជាការការពារ និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ដូចក្រុមគណបក្សប្រឆាំងយកមកធ្វើជាអាជីវកម្មនយោបាយនោះទេ តែគឺជាចលនាគាស់រំលើងរបបដឹកនាំដែលមិនយល់ព្រមដើរតាមគោលនយោបាយបង្គាប់បញ្ជារបស់មហាអំណាចនិងសម្ព័ន្ធមិត្ត ឬបម្រើផលប្រយោជន៍មនោគមវិជ្ជា ឥទ្ធិពលនយោបាយ និងភូមិសាស្ត្រនយោបាយរបស់ខ្លួនតែប៉ុណ្ណោះ។

ការទប់ស្កាត់ចលនាបដិវត្តន៍ពណ៌ តាមរយៈការរំលាយអង្គការចាត់តាំងនយោបាយ ដោយវិធានការច្បាប់ គឺដើម្បីធានាសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម និងការអភិវឌ្ឍ។ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្តបន្តដឹកនាំប្រទេសស្របតាមរដ្ឋធម្មនុញ្ញ ដោយគោរពតាមគោលការណ៍នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងការគោរពសិទ្ធិមនុស្ស។ ដោយយល់ច្បាស់ពីតម្លៃនៃសន្តិភាព និងការអភិវឌ្ឍ រាជរដ្ឋាភិបាលមិនអនុញ្ញាតឱ្យ

ជនណាម្នាក់ឬក្រុមណាមួយ ធ្វើសកម្មភាពបំផ្លាញសន្តិភាពនិងសមិទ្ធផលដែលសម្រេចបានដោយលំបាក ឬការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងពីបរទេសដែលអាចធ្វើឱ្យកម្ពុជា ធ្លាក់ចូលភ្លើងសង្គ្រាមសារជាថ្មីទៀតបានឡើយ។ ប្រសិនបើសង្គ្រាមកើតឡើងមែននោះ ប្រជាជនកម្ពុជាគឺជាអ្នកទទួលរងគ្រោះ មិនមែនជនបរទេសដែលនៅខាងក្រៅប្រទេសនោះទេ។

នៅកម្ពុជា ការចាប់ខ្លួនអ្នកនយោបាយ សមាជិកសភា ឬព្រឹទ្ធសភាមួយចំនួន គឺធ្វើឡើងតាមនីតិវិធីច្បាប់ ហើយមិនមែនជាការរំលោភសិទ្ធិមនុស្ស និងសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ឬបិទសិទ្ធិធ្វើនយោបាយនោះទេ តែជាការអនុវត្តគោលការណ៍នីតិរដ្ឋ ក្នុងនាមជារដ្ឋឯករាជ្យនិងអធិបតេយ្យតែប៉ុណ្ណោះ។ ការចាប់ខ្លួនអ្នកនយោបាយដែលប្រព្រឹត្តល្មើសច្បាប់ មិនមែនកើតមានឡើងតែនៅកម្ពុជាទេ តែមាននៅប្រទេសដទៃទៀត តែគ្រាន់ជាបទចោទប្រកាន់ ឬការប្រព្រឹត្តបទល្មើសមានលក្ខណៈខុសៗគ្នា ដូចជា នៅប្រទេសថៃ ហ្វីលីពីន ម៉ាឡេស៊ី សាធារណរដ្ឋកូរ៉េ ឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតចិន សហរដ្ឋអាមេរិក រុស្ស៊ី ប្រទេសនៅអាមេរិកឡាទីន អាហ្វ្រិក និងអឺរ៉ុប ជាដើម។ នៅកម្ពុជា គ្មានទេអ្នកទោសនយោបាយ តែមានអ្នកនយោបាយជាប់ទោសដោយសារអំពើរំលោភបំពានច្បាប់។

ប្រជាធិបតេយ្យដែលគ្មាននីតិរដ្ឋ គឺជាឫសគល់នៃអនាធិបតេយ្យ។ ដូច្នេះ រាជរដ្ឋាភិបាលមានភារកិច្ចគ្រប់គ្រងស្ថានការណ៍ក្នុងប្រទេស អនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព និងលើកតម្កើងតម្លៃនៃអំណាចរដ្ឋ។ នីតិបុគ្គលឬរូបវន្តបុគ្គលទាំងឡាយណា ដែលប្រព្រឹត្តអំពើធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់សង្គម សន្តិសុខជាតិនិងទំនាក់ទំនងការទូត ព្រមទាំងញុះញង់ឱ្យមានការរើសអើងជាតិសាសន៍ និងបញ្ឆេះកំហឹងមហាជន គឺត្រូវ

ទទួលខុសត្រូវចំពោះមុខច្បាប់ ហើយប្រទេសផ្សេងៗក៏ចាត់វិធានការបែបនេះ ដូចកម្ពុជាដែរ។

ការយល់ដឹងអំពីសិទ្ធិសេរីភាពរបស់បុគ្គលឱ្យកាន់តែច្បាស់ ការយល់ដឹងអំពីច្បាប់ឱ្យបានទូលំទូលាយ ការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ការលើកកម្ពស់សីលធម៌របស់អ្នកនយោបាយ និងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច គឺជាមូលដ្ឋានគ្រឹះ ក្នុងការសម្រេចគោលដៅពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។ កម្ពុជាប្រកាន់ខ្ជាប់នូវគោលជំហរដ៏មុតមាំក្នុងការធានានិងការពារប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ឱ្យកាន់តែរឹងមាំ ស្របតាមនិន្នាការជាក់ស្តែងនៃការរីកចម្រើនរបស់សង្គមជាតិ និងការថែរក្សាសន្តិភាព ព្រមទាំងធានានូវសិទ្ធិសេរីភាពគ្រប់យ៉ាងរបស់ពលរដ្ឋ ដោយផ្អែកលើរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។

រាជរដ្ឋាភិបាល សូមអំពាវនាវដល់មជ្ឈដ្ឋានមួយចំនួន ដែលបាននិងកំពុងជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ឱ្យបញ្ឈប់រាល់សកម្មភាពទាំងនេះ ហើយសូមស្វាគមន៍អ្នកនយោបាយ ស្ថាប័នបរទេស និងបណ្តាប្រទេសជាមិត្ត ចូលរួមគាំទ្រនិងរួមចំណែកក្នុងបុព្វហេតុកសាងមូលដ្ឋានគ្រឹះនៃការពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាមួយប្រជាជននិងរាជរដ្ឋាភិបាលកម្ពុជា។

## ១. សេចក្ដីផ្ដើម

នៅក្នុងពិភពលោកយើងនេះ មនុស្សជាតិមានចម្រុះជាតិសាសន៍ មានភាពខុសគ្នានៃភាសា ជំនឿ សាសនា វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ របៀបរស់នៅ ការអប់រំ ចំណេះដឹង និងដំណើរឆ្លងកាត់ប្រវត្តិសាស្ត្រខុសៗគ្នា។ ជាមួយគ្នានេះ ប្រព័ន្ធគ្រប់គ្រងរដ្ឋនៃប្រជាជាតិនីមួយៗ ក៏ខុសៗគ្នាដែរ ដូចជា ប្រព័ន្ធគ្រប់គ្រងបែបរាជានិយមផ្ដាច់ការ បែបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ បែបសង្គមនិយម បែបផ្ដាច់ការ និងបែបប្រជាធិបតេយ្យសេរី អាស្រ័យលើកត្តាប្រវត្តិសាស្ត្ររបស់ខ្លួន។ ហេតុដូច្នេះ ប្រព័ន្ធគ្រប់គ្រងរដ្ឋនៃប្រទេសមួយ មិនអាចយកមកប្រៀបធៀប ឬចម្លងយកទៅអនុវត្តនៅក្នុងប្រទេសមួយផ្សេងទៀត បានទាំងស្រុងទេ។ ផ្អែកតាមប្រវត្តិសាស្ត្រកម្ពុជាធ្លាប់បានឆ្លងកាត់ទម្រង់នៃប្រព័ន្ធគ្រប់គ្រងរដ្ឋជាច្រើន ដូចបានរៀបរាប់ខាងលើ ជាពិសេស ក្នុងដំណាក់កាលចុងក្រោយ ដែលបានផ្ដល់បទពិសោធន៍ដ៏ល្វីងជូរចត់ ដែលកម្ពុជាបានខិតខំតស៊ូយ៉ាងលំបាក ដើម្បីស្ដារនិងអភិវឌ្ឍប្រទេសចេញពីគំនរផេះផង់។

ក្នុងអំឡុងពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ កម្ពុជាបានឆ្លងកាត់របបប្រល័យពូជសាសន៍ ដែលបានសម្លាប់ប្រជាជនអស់ជាង៣លាននាក់ ក្នុងនោះ បានកាប់សម្លាប់បញ្ញវន្តខ្មែរ មន្ត្រីរាជការ គ្រូបង្រៀន និងអ្នកជំនាញ ដែលសុទ្ធសឹងតែជាធនធានស្នូលសម្រាប់ការអភិវឌ្ឍសង្គមជាតិ ហើយបានបន្សល់ទុកស្ត្រីមេម៉ាយ ក្មេងកំព្រា និងអ្នកបាត់បង់កាយសម្បទា ព្រមទាំងភាពខ្ទេចខ្ទាំនៃហេដ្ឋារចនាសម្ព័ន្ធ កង្វះខាតស្បៀងអាហារ និងកម្លាំងផលិតកម្ម។ ដោយសារថ្ងៃជ័យជំនះ៧មករា១៩៧៩ ប្រជាជាតិយើងបានរួចផុតពីរបបដ៏សាហាវយង់ឃ្នងនេះ បានរស់រានមានជីវិត និងបានទទួលសិទ្ធិសេរីភាពឡើងវិញ។ បន្ទាប់ពីឆ្នាំ១៩៨៥មក កម្ពុជាមិនគ្រាន់តែបានធ្វើកំណែទម្រង់ប្រព័ន្ធនយោបាយដឹកនាំប្រទេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានដាក់ចេញនូវគោលនយោបាយ

និងយុទ្ធសាស្ត្រ សម្រាប់ស្តារនិងអភិវឌ្ឍប្រទេសតាមប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។ នៅឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានឈានចូលដំណាក់កាលថ្មីនៃការរក្សាសន្តិភាព និងការបង្រួបបង្រួមជាតិ ព្រមទាំងបានទទួលយករដ្ឋធម្មនុញ្ញថ្មីតាមរបបប្រជាធិបតេយ្យ សេរីពហុបក្ស។

ទោះបីជាការបោះឆ្នោតឆ្នាំ១៩៩៣ បាននាំមកនូវការបង្រួបបង្រួមជាតិ និងការទទួលស្គាល់កម្ពុជានៅលើឆាកអន្តរជាតិក៏ដោយ ក៏ខ្មែរក្រហមនៅតែបន្តសកម្មភាពបំផ្លិចបំផ្លាញរហូតដល់ឆ្នាំ១៩៩៨។ បន្ទាប់ពីការដួលរលំអង្គការចាត់តាំងខ្មែរក្រហម កម្ពុជាបានទទួលសន្តិភាពទាំងស្រុង ហើយរាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី បានដឹកនាំប្រទេសឱ្យទទួលបានសុខសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍ គួរឱ្យកត់សម្គាល់ស្របតាមគោលការណ៍នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងការគោរពសិទ្ធិមនុស្ស។ ការដួលរលំអង្គការចាត់តាំងនយោបាយ និងយោធារបស់ខ្មែរក្រហមនៅឆ្នាំ១៩៩៨ គឺជាជោគជ័យដ៏ធំធេង ហើយបានធ្វើឱ្យប្រជាជនស្គាល់សុខសន្តិភាពពេញលេញ ដែលមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្ររយៈពេលប្រហែល៥០០ឆ្នាំចុងក្រោយរបស់កម្ពុជា។

ត្រឹមតែរយៈពេល២០ឆ្នាំចុងក្រោយប៉ុណ្ណោះ កម្ពុជាសម្រេចបាននូវសមិទ្ធផលជាច្រើន ប៉ុន្តែផ្ទុយទៅវិញ ក្រុមប្រឆាំងនៅតែព្រងើយកន្តើយ និងមិនទទួលស្គាល់សមិទ្ធផលទាំងនេះ ហើយតែងតែចោទប្រកាន់ ប្រឌិតបំផ្លើសរឿង និងបំភ័ន្តការពិត ដើម្បីធ្វើឱ្យសាធារណជនក្នុងនិងក្រៅប្រទេស មានការយល់ច្រឡំ និងមានគំនិតអវិជ្ជមាន លើការដឹកនាំរបស់រាជរដ្ឋាភិបាល។ សកម្មភាពជាច្រើនរបស់ក្រុមទាំងនេះ គឺផ្ទុយនឹងគោលការណ៍ច្បាប់ តែពួកគេតែងតែធ្វើអាជីវកម្មលើស្ថានភាពនយោបាយ ក្រោមលេសប្រជាធិបតេយ្យ

និងសិទ្ធិមនុស្ស។ អស់រយៈពេលជាច្រើនឆ្នាំ ក្រុមប្រឆាំងបានឃុបឃិតជាមួយបរទេស រៀបចំផែនការទុច្ចរិត ប៉ុនប៉ងផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ នៅរាល់ពេលដែលទទួលបរាជ័យក្នុងការបោះឆ្នោត។

ទង្វើរបស់ក្រុមប្រឆាំងបានប្រព្រឹត្តទៅជាបន្តបន្ទាប់ ទៅតាមដំណាក់កាល ជាពិសេសគឺការប្រមូលផ្តុំកម្លាំងមហាជន ដើម្បីប្រឆាំងតទល់ជាមួយរដ្ឋអំណាចក្នុងអំឡុងពីឆ្នាំ២០១៣ និងឆ្នាំ២០១៤ ហើយចលនានេះនៅតែបន្តអនុវត្តផែនការផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ ដោយយកគំរូតាមប្រទេសយូហ្គោស្លាវី។ ភស្តុតាងដែលមានលក្ខណៈស៊ីសង្វាក់គ្នានឹងសកម្មភាពជាច្រើន បានបង្ហាញយ៉ាងច្បាស់អំពីការធ្វើបដិវត្តន៍ពណ៌ ដើម្បីផ្តួលរំលំរបបដឹកនាំតាមបែបលទ្ធិប្រជាធិបតេយ្យ ដែលផ្ទុយនឹងគោលការណ៍ច្បាប់និងរដ្ឋធម្មនុញ្ញ។ ដោយប្រកាន់ខ្ជាប់គោលការណ៍នីតិរដ្ឋ អាជ្ញាធរមានសមត្ថកិច្ចបានចាត់វិធានការទប់ស្កាត់ចលនានេះដោយជោគជ័យ ហើយបានឈានដល់ការចាប់ខ្លួន កឹម សុខា និងការរំលាយគណបក្សសង្គ្រោះជាតិ។

ដើម្បីការពារសមិទ្ធផល ធម្មានុរូបភាពនៃចំណាត់ការ និងជំហររបស់រាជរដ្ឋាភិបាល អង្គភាពព័ត៌មាននិងប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រី បានរៀបចំតាក់តែងសៀវភៅសនេះឡើង សំដៅបកស្រាយបំភ្លឺជូនសាធារណជនអំពីស្ថានភាពពិតនៅកម្ពុជា ពាក់ព័ន្ធនឹងដំណើរការលទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋ ព្រមទាំងការពិតទាក់ទងនឹងព្រឹត្តិការណ៍នានា ដែលជាផែនការនិង ការអនុវត្តផែនការបដិវត្តន៍ពណ៌ ក្រោមការជួយជ្រោមជ្រែងផ្នែកយុទ្ធសាស្ត្រ មធ្យោបាយ បច្ចេកទេស និងហិរញ្ញវត្ថុពីបរទេស។ ឯកសារនេះក៏បានលើកឡើងអំពីជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការការពារអធិបតេយ្យភាព និងឯករាជ្យភាពរបស់ខ្លួន រួមទាំងវិធានការមួយចំនួនទប់ទល់នឹងមេខ្លោងក្បត់ជាតិនិងបក្សពួក ដើម្បីធានាការពារសន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់ សង្គម និងសន្តិសុខជាតិ

ព្រមទាំងទប់ស្កាត់មិនឱ្យមានការកកើតសង្គ្រាមឡើងវិញនៅកម្ពុជា ដូចដែលកំពុងកើតមានឡើងនៅក្នុងប្រទេសមួយចំនួន ដែលកំពុងទទួលរងផលវិបាកបណ្តាលមកពីបដិវត្តន៍ពណ៌។ ចំណាត់ការរបស់រាជរដ្ឋាភិបាលកម្ពុជា គឺធ្វើឡើងដោយផ្អែកលើមូលដ្ឋានច្បាប់ជាធរមាន សំដៅពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិតេយ្យ និងការគោរពសិទ្ធិមនុស្ស ដើម្បីជាប្រយោជន៍រួមដល់ប្រទេសជាតិនិងប្រជាជន។

## ២. មូលដ្ឋានគ្រឹះនៃការពង្រឹងនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ

ព្រះរាជាណាចក្រកម្ពុជា ប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដែលមានព្រះមហាក្សត្រគ្រងរាជ្យសម្បត្តិ និងជាព្រះប្រមុខរដ្ឋអស់មួយជីវិត ប៉ុន្តែមិនកាន់អំណាច។

ការបោះឆ្នោតជ្រើសរើសសភាធម្មនុញ្ញ ត្រូវបានរៀបចំឡើងជាលើកដំបូងក្នុងឆ្នាំ១៩៩៣ ដោយអាជ្ញាធរបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (United Nations Transitional Authority in Cambodia – UNTAC) តាមស្មារតីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ ស្ដីពីដំណោះស្រាយនយោបាយនៅកម្ពុជា ហើយសភាធម្មនុញ្ញនេះ បានតាក់តែង និងអនុម័តរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មុននឹងក្លាយជារដ្ឋសភានីតិកាលទី១។ រដ្ឋធម្មនុញ្ញថ្មីនេះ គឺជាច្បាប់កំពូលរបស់ជាតិ ដែលក្នុងនោះខ្លឹមសារសំខាន់ៗ នៃកិច្ចព្រមព្រៀងនេះ ត្រូវបានច្របាច់បញ្ចូល។ តាមរយៈរដ្ឋធម្មនុញ្ញនេះ ស្ថាប័នកំពូលៗរបស់ជាតិត្រូវបានបង្កើតឡើង និងចាប់ដំណើរការ។ នៅឆ្នាំ២០១៦ លោក Jean-David Levitte អតីតអ្នកការទូតជាន់ខ្ពស់នៃក្រសួងការបរទេសបារាំង ដែលបានចូលរួមយ៉ាងសកម្មក្នុងដំណើរការសន្តិភាពនៅកម្ពុជា បានកត់សម្គាល់ថា បន្ទាប់ពីការបោះឆ្នោតដែលបានរៀបចំដោយ UNTAC នៅឆ្នាំ១៩៩៣ រដ្ឋជាហត្ថលេខីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសបានបញ្ចប់បេសកកម្មនៅកម្ពុជា ហើយក្នុងនាមជារដ្ឋអធិបតេយ្យមួយ កម្ពុជាបានស្ថិតលើមាគ៌ាសន្តិភាពនិងការអភិវឌ្ឍ។

### ២.១. ការកសាងស្ថាប័ន

ដូចនៅបណ្ដាប្រទេសប្រកាន់យកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សនានាដែរ កម្ពុជាប្រកាន់យកប្រព័ន្ធបែងចែកអំណាចកំពូលជាបីដាច់ដោយឡែកនិងឯករាជ្យពីគ្នា គឺស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ សំដៅធានា

និរន្តរភាពនៃអំណាចរដ្ឋ។ អំណាចទាំងអស់គឺជារបស់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋប្រើសិទ្ធិអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងតុលាការ។ ក្រៅពីអំណាចទាំងបីនេះ ស្ថាប័ន ឯករាជ្យមួយចំនួនត្រូវបានបង្កើតឡើង ដើម្បីធានាដំណើរការប្រព្រឹត្តទៅនៃអំណាចទាំងបីដោយរលូន ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ មានជាអាទិ៍ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រុមប្រឹក្សាធម្មនុញ្ញ អាជ្ញាធរសវនកម្មជាតិ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាដើម។

**ស្ថាប័ននីតិប្បញ្ញត្តិ** រួមមាន រដ្ឋសភា និងព្រឹទ្ធសភា។

**រដ្ឋសភា** គឺជាសភាតំណាងរាស្ត្រ ដែលកើតចេញពីការបោះឆ្នោតជាសកល ដោយសេរី ស្មើភាព និងចំពោះ ហើយតាមវិធីបោះឆ្នោតជាសម្ងាត់ សម្រាប់អាណត្តិ៥ឆ្នាំ។ រដ្ឋសភាមានសិទ្ធិអំណាច ជាអាទិ៍ បោះឆ្នោតផ្តល់សេចក្តីទុកចិត្ត ឬទម្លាក់រាជរដ្ឋាភិបាល ឬសមាជិកគណៈរដ្ឋមន្ត្រី ធ្វើសេចក្តីស្នើច្បាប់ អនុម័តច្បាប់ ថវិការដ្ឋ និងផែនការរដ្ឋ ព្រមទាំងផ្តល់សច្ចាប័នលើសន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ។ គណៈកម្មការរបស់រដ្ឋសភា មានសិទ្ធិអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាពាក់ព័ន្ធនឹងវិស័យដែលខ្លួនទទួលខុសត្រូវ។ ចំណែកក្រុមតំណាងរាស្ត្រមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ពិភាក្សាច្បាប់ ស្នើធ្វើវិសោធនកម្មច្បាប់ និងចោទសួររាជរដ្ឋាភិបាល។ បច្ចុប្បន្ន រដ្ឋសភាមានសមាជិកចំនួន១២៣រូប ហើយនឹងកើនឡើងដល់១២៥រូប នៅក្នុងការបោះឆ្នោតឆ្នាំ២០១៨។ អង្គការដឹកនាំកំពូលរបស់រដ្ឋសភា គឺគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដែលដឹកនាំដោយប្រធាន និងអនុប្រធានពីររូប ដោយមានប្រធានគណៈកម្មការទាំង១០ ជាសមាជិក។

**ព្រឹទ្ធសភា** មានសមាជិកចំនួនមិនលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភា។ សមាជិក២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ

និងសមាជិក២រូបត្រូវបានជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដោយប្រៀប ហើយសមាជិកផ្សេងទៀត ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកលសម្រាប់អាណត្តិ៦ឆ្នាំ។ ព្រឹទ្ធសភាមានសិទ្ធិអំណាច ជាអាទិ៍ ពិនិត្យនិងផ្ដល់យោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ បន្ទាប់ពីរដ្ឋសភាបានអនុម័តយល់ព្រមរួច និងបញ្ហាសំខាន់ៗមួយចំនួនទៀត។ អង្គការដឹកនាំកំពូលរបស់ព្រឹទ្ធសភា គឺគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដែលដឹកនាំដោយប្រធាន និងអនុប្រធានពីររូប ដោយមានប្រធានគណៈកម្មការទាំង១០ជាសមាជិក។

**ស្ថាប័ននីតិប្រតិបត្តិ៖** រាជរដ្ឋាភិបាលគឺជាស្ថាប័ននីតិប្រតិបត្តិ ដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូបជាតំណាងរាស្ត្រនៃគណបក្សឈ្នះឆ្នោត អមដោយឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិកដែលត្រូវបានបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តដោយរដ្ឋសភា ហើយព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។ រាជរដ្ឋាភិបាលមានភារកិច្ចដឹកនាំប្រទេស ធ្វើសេចក្ដីព្រាងច្បាប់ ធ្វើផែនការអភិវឌ្ឍន៍ ស្នើគម្រោងថវិកាជាតិ ការពារលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស និងការអនុវត្តគោលនយោបាយការបរទេស ជាដើម។ រាជរដ្ឋាភិបាលគ្រប់គ្រង បញ្ជា និងប្រើប្រាស់យោធា នគរបាល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដើម្បីធានានិងការពារសន្តិសុខជាតិ សណ្ដាប់ធ្នាប់សាធារណៈ បូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ។ រាជរដ្ឋាភិបាលដឹកនាំការចរចានិងចុះហត្ថលេខាលើកិច្ចព្រមព្រៀងនានា ជាអាទិ៍ កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម សហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស។ ដោយគោរពតាមគោលការណ៍នៃការបែងចែកអំណាចរដ្ឋ រាជរដ្ឋាភិបាលរក្សាកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងតុលាការ។ ទន្ទឹមនឹងនេះ

រាជរដ្ឋាភិបាល ត្រូវពិនិត្យជាបន្តបន្ទាប់នូវគោលនយោបាយ និងកំណែទម្រង់លើគ្រប់វិស័យ ជាពិសេសកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដើម្បីជំរុញការបំពេញការងារឱ្យកាន់តែមានឯករាជ្យភាពនិងប្រសិទ្ធភាព។ រាជរដ្ឋាភិបាលសហការយ៉ាងជិតស្និទ្ធជាមួយវិស័យឯកជន អង្គការសារព័ត៌មាន សង្គមស៊ីវិល និងសហជីព ក្នុងភាពជាដៃគូ ដើម្បីធានាកំណើនសេដ្ឋកិច្ច លទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាពជាមូលដ្ឋាន អភិបាលកិច្ចល្អ និងយុត្តិធម៌សង្គម។

រាជរដ្ឋាភិបាលទទួលខុសត្រូវចំពោះមុខរដ្ឋសភា អំពីនយោបាយក្នុងស្រុកនិងការបរទេស ហើយសមាជិករាជរដ្ឋាភិបាលម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និងរដ្ឋសភា។ ប្រមុខរាជរដ្ឋាភិបាល និងសមាជិករាជរដ្ឋាភិបាលអាចទៅឆ្លើយបំភ្លឺជូនរដ្ឋសភា ឬឆ្លើយតបជាលាយលក្ខណ៍អក្សរជូនតំណាងរាស្ត្រ តាមការស្នើសុំលើបញ្ហាជាក់លាក់ណាមួយ។

**ស្ថាប័នតុលាការ៖** តុលាការជាស្ថាប័នឯករាជ្យ ដែលធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពពលរដ្ឋ។ អំណាចតុលាការគ្របដណ្តប់លើរឿងក្តីទាំងអស់។ អំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិមិនអាចជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់អំណាចតុលាការបានឡើយ។ ព្រះមហាក្សត្រជាធានាឯករាជ្យភាពនៃអំណាចតុលាការ ដែលមានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាសេនាធិការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជម្រះក្តី។ ចៅក្រមមានសិទ្ធិជម្រះក្តី និងត្រូវបំពេញភារកិច្ចដោយឯករាជ្យ និងគោរពច្បាប់យ៉ាងម៉ឺងម៉ាត់។ ទណ្ឌកម្មវិន័យពាក់ព័ន្ធនឹងករណីអសមត្ថភាព កំហុសផ្នែកវិន័យ និងក្រមសីលធម៌វិជ្ជាជីវៈរបស់ចៅក្រមនិងព្រះរាជអាជ្ញា ត្រូវបានត្រួតពិនិត្យនិងចាត់វិធានការ ដោយក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ទន្ទឹមនឹងនេះ ដើម្បីបណ្តុះបណ្តាលធនធានមនុស្សបន្ថែមប្រកបដោយសមត្ថភាព

និងវិជ្ជាជីវៈក្នុងវិស័យយុត្តិធម៌ រាជរដ្ឋាភិបាលបានបង្កើតរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ ដែលមានសាលាជំនាញចំនួន៤គឺ សាលាភូមិន្ទចៅក្រម សាលាភូមិន្ទក្រឡាបញ្ជី សាលាភូមិន្ទសារការី និងសាលាភូមិន្ទអាជ្ញាសាលា ព្រមទាំងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

**ក្រុមប្រឹក្សាធម្មនុញ្ញ** មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញនិងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ។ ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យនិងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកចំនួន៩រូប ដែលសមាជិក៣រូបត្រូវតែងតាំងដោយព្រះមហាក្សត្រ សមាជិក៣រូបជ្រើសតាំងដោយរដ្ឋសភា និងសមាជិក៣រូបទៀតតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រាប់អាណត្តិ៩ឆ្នាំ។ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។ សមាជិក១ភាគ៣នៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានផ្លាស់ប្តូររៀងរាល់៣ឆ្នាំម្តង។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានវិសមិតភាពនឹងមុខងារសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រមក្នុងតំណែង តំណែងមុខងារសាធារណៈ ប្រធានឬអនុប្រធានគណបក្សនយោបាយ និងប្រធានឬអនុប្រធានសហជីព។

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.)** ជាស្ថាប័នឯករាជ្យ និងអព្យាក្រឹត ដែលធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។ គ.ជ.ប. មានសមត្ថកិច្ចរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់។ ក្នុងដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត គ.ជ.ប.

បានធ្វើតាមនីតិវិធីត្រឹមត្រូវ និងតាមច្បាប់កំណត់ ដើម្បីបង្កលក្ខណៈឱ្យប្រជាពលរដ្ឋទាំងអស់អាចទៅចុះឈ្មោះ អាចទៅកែឈ្មោះខុស ឬក៏កែថ្ងៃ ខែ ឆ្នាំកំណើត និងភេទជាដើម ជាពិសេស បញ្ជីឈ្មោះអ្នកបោះឆ្នោតថ្មីឆ្នាំ២០១៧ត្រូវបានធ្វើទំនើបកម្មក្រោមជំនួយឧបត្ថម្ភរបស់រដ្ឋាភិបាលជប៉ុន ដែលមានលក្ខណៈកាន់តែល្អប្រសើរគ្រប់ជ្រុងជ្រោយ។ អាជ្ញាធរពាក់ព័ន្ធ និង គ.ជ.ប. ក៏បានបង្កលក្ខណៈនិងបង្កើតបរិយាកាស ឱ្យដំណើរការនៃយុទ្ធនាការបោះឆ្នោតប្រព្រឹត្តទៅដោយរលូន គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សា។ គ្រប់គណបក្សនយោបាយទាំងអស់ មានសិទ្ធិពេញលេញក្នុងការធ្វើយុទ្ធនាការទោះជាទ្រង់ទ្រាយតូចឬធំក៏ដោយ។ ស្របពេលដែលការរៀបចំការបោះឆ្នោតប្រព្រឹត្តទៅបានកាន់តែល្អប្រសើរឡើង គ.ជ.ប. បានធ្វើកំណែទម្រង់ជាបន្តបន្ទាប់៖ (១) សមាជិកត្រូវបានជ្រើសរើសចេញពីគណបក្សនយោបាយមានអាសនៈនៅរដ្ឋសភា និងសង្គមស៊ីវិល (២) បញ្ជីឈ្មោះថ្មីនៃអ្នកបោះឆ្នោតត្រូវបានរៀបចំតាមប្រព័ន្ធព័ត៌មានវិទ្យា និង (៣) គ.ជ.ប. បានក្លាយជាស្ថាប័នដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៅឆ្នាំ២០១៤ ជាដើម។

**គណបក្សនយោបាយ** ជាតួអង្គនិងជាតុដ៏សំខាន់នៅក្នុងការដឹកនាំគ្រប់គ្រងរដ្ឋក្នុងប្រព័ន្ធប្រជាធិបតេយ្យ។ ការចូលរួមសកម្មភាពនយោបាយនិងការប្រកួតប្រជែងក្នុងការបោះឆ្នោត ឆ្លុះបញ្ចាំងអំពីការអនុវត្តគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។ បច្ចុប្បន្ន កម្ពុជាមានគណបក្សនយោបាយចំនួន៣៥ ដែលបានចុះបញ្ជីនិងត្រៀមចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅឆ្នាំ២០១៨។ គណបក្សនយោបាយអាចចងសម្ព័ន្ធភាព និងមានសេរីភាពក្នុងការរៀបចំកម្មវិធីនយោបាយ ស្របតាមលក្ខន្តិកៈរបស់ខ្លួន ប៉ុន្តែត្រូវគោរពតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់នានាជាធរមាន។

គណបក្សនយោបាយ មានតួនាទីចូលរួមចំណែកដល់ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍប្រទេស ដូចជា ការទិតៀនដើម្បីកែលម្អសកម្មភាពរបស់រាជរដ្ឋាភិបាល។ នៅកម្ពុជា គណបក្សនយោបាយមានសិទ្ធិសេរីភាព ក្នុងការធ្វើយុទ្ធនាការបោះឆ្នោត ឃោសនាអំពីកម្មវិធីនយោបាយ ធ្វើពិធីជួបជុំសមាជិក និងចូលរួមរាល់សកម្មភាពនយោបាយដោយសេរី ប៉ុន្តែ ក៏ត្រូវទទួលខុសត្រូវចំពោះរាល់សកម្មភាពទាំងឡាយណា ដែលផ្ទុយនឹងច្បាប់កំណត់ដែរ។ រាល់ការបោះឆ្នោត មានការចូលរួមប្រកួតប្រជែងពីគណបក្សដែលមាននិន្នាការនិងកម្មវិធីនយោបាយខុសៗគ្នា ដោយសេរី និងស្មើភាព។ គណបក្សធ្វើសកម្មភាពនយោបាយ ស្របតាមច្បាប់និងនីតិវិធីជាធរមាន ដោយស្មើភាព និងគ្មានការគំរាមកំហែង។

**ស្ថាប័នព័ត៌មាន៖** ក្រសួងព័ត៌មានជាស្ថាប័នគ្រប់គ្រងសារព័ត៌មានទាំងអស់នៅកម្ពុជា។ ច្បាប់ស្តីពីរបបសារព័ត៌មានមានលក្ខណៈសេរីនិងបើកទូលាយ ក្នុងការបង្កើតអង្គភាពសារព័ត៌មាន ស្ថានីយវិទ្យុនិងទូរទស្សន៍ ភ្នាក់ងារនិងការិយាល័យតំណាងវិទ្យុ ទូរទស្សន៍បរទេស ព្រមទាំងភ្នាក់ងារនិងការិយាល័យតំណាងសារព័ត៌មានបរទេសជាដើម ប៉ុន្តែសារព័ត៌មានក៏ត្រូវបំពេញវិជ្ជាជីវៈរបស់ខ្លួនដោយសុចរិត ផ្សព្វផ្សាយផ្អែកលើការពិត មានភាពឯករាជ្យ ទទួលខុសត្រូវ និងមិនត្រូវមួលបង្កាច់ ឬប្រឌិតបំផ្លើសរឿង ដើម្បីតែផលប្រយោជន៍អាជីវកម្ម និងនយោបាយ នោះទេ។ ក្នុងរយៈពេលជិត៣ទសវត្សរ៍នេះ អង្គភាពស្ថានីយ ភ្នាក់ងារ និងការិយាល័យសារព័ត៌មានចំនួន៨២៦អង្គភាព ត្រូវបានអនុញ្ញាតឱ្យដំណើរការ ក្នុងនោះអាជ្ញាបណ្ណចំនួន៣៣០ត្រូវបានលុប ដោយមូលហេតុមិនដំណើរការឬផុតសុពលភាព ចំណែកអាជ្ញាបណ្ណចំនួន៤៩៦កំពុងដំណើរការ។ អ្នកសារព័ត៌មានមានសិទ្ធិសេរីភាពក្នុងការប្រកបវិជ្ជាជីវៈដោយសេរីនិងគ្មានការបំភិតបំភ័យ ប៉ុន្តែមិនត្រូវបំពានលើសិទ្ធិសេរីភាពអ្នក

ដទៃនោះឡើយ។ សមាគមសារព័ត៌មាន មជ្ឈមណ្ឌលសារព័ត៌មាន និងក្លឹបអ្នកកាសែតត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ដើម្បីពង្រឹងវិស័យព័ត៌មានឱ្យកាន់តែល្អប្រសើរ និងការពារផលប្រយោជន៍របស់អង្គភាពសារព័ត៌មាន និងអ្នកសារព័ត៌មាន។

**អង្គការសង្គមស៊ីវិល៖** ក្រសួងមហាផ្ទៃទទួលគ្រប់គ្រងនិងចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាល និងសមាគមក្នុងស្រុក ចំណែកក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ទទួលគ្រប់គ្រងនិងចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលបរទេស ទៅតាមនីតិវិធីដែលមានភាពងាយស្រួលនិងឆាប់រហ័ស។ តាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល អង្គការដែលធ្វើប្រតិបត្តិការនៅកម្ពុជា ត្រូវបញ្ជូនរបាយការណ៍ស្តីពីសកម្មភាពនិងហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន ជូនក្រសួងមានសមត្ថកិច្ច។ រហូតដល់បច្ចុប្បន្ននេះ អង្គការមិនមែនរដ្ឋាភិបាលនិងសមាគមក្នុងស្រុកជាង៣ ០០០ និងសហជីពជាច្រើនទៀត បាននិងកំពុងធ្វើប្រតិបត្តិការនៅកម្ពុជា ដោយសេរីស្របតាមច្បាប់។ សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល មានភារកិច្ចចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម ដោយឈរលើគោលការណ៍អព្យាក្រឹត និងផលប្រយោជន៍ប្រជាពលរដ្ឋជាធំ ហើយមិនត្រូវចូលរួមសកម្មភាពទាំងឡាយណាដែលបម្រើដល់ការងារនយោបាយ គណបក្សនយោបាយ ឬក្រុមដែលមាននិន្នាការនយោបាយ ផ្ទុយនឹងបេសកកម្មរបស់ខ្លួន ជាពិសេស គឺប្រើប្រាស់ថវិកាដែលជាជំនួយរបស់បរទេស សប្បុរសជន ដើម្បីប៉ុនប៉ងផ្តួលរំលំរដ្ឋអំណាចស្របច្បាប់។

### ២.២. ការកសាងក្របខ័ណ្ឌច្បាប់

ចាប់តាំងពីឆ្នាំ២០០៣ រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ និងផ្តល់អាទិភាពដល់ការធ្វើកំណែទម្រង់ច្បាប់

និងប្រព័ន្ធយុត្តិធម៌។ ផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ជាតិ លិខិតបទដ្ឋានគតិយុត្ត និងសកម្មភាពជាច្រើន ត្រូវបានដាក់ចេញដើម្បីសម្រេចឱ្យបានជោគជ័យនៃកំណែទម្រង់នេះ។ យុទ្ធសាស្ត្រនិងផែនការសកម្មភាពនានាត្រូវបានដាក់ចេញនៅក្នុងឯកសារសំខាន់ចំនួន២គឺ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ និងយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី៣ នៅឆ្នាំ២០១៣។ លើសពីនេះទៀត ដើម្បីធានានូវឯករាជ្យភាពនៃអំណាចតុលាការ នៅឆ្នាំ២០១៤ រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយនិងច្បាប់ថ្មីៗ គឺការរៀបចំនិងដាក់ឱ្យអនុវត្តច្បាប់គោល៣ រួមមាន (១) **ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ** (២) **ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា** និង(៣) **ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។**

ក្នុងពេលដែលស្ថាប័នទ្រទ្រង់លទ្ធិប្រជាធិបតេយ្យ ត្រូវបានបង្កើតឡើង ការងារចម្បងរបស់រាជរដ្ឋាភិបាល គឺត្រូវយកចិត្តទុកដាក់កសាងក្របខ័ណ្ឌច្បាប់ដែលជាឧបករណ៍សម្រាប់ពង្រឹង ទ្រទ្រង់ និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ។ ក្នុងរយៈពេល៣ទសវត្សរ៍ចុងក្រោយនេះ ដោយមានការប្តេជ្ញាចិត្តយ៉ាងមោះមុត កម្ពុជាបានប្រកាសឱ្យប្រើច្បាប់ចំនួន៤៩៧ ដែលមានចរិតនិងខ្លឹមសារស្របតាមគោលការណ៍នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស តម្លាភាព សង្គតិភាព និងបម្រើផលប្រយោជន៍សាធារណៈ ហើយការតាក់តែងច្បាប់នេះមានការចូលរួមពីតួអង្គពាក់ព័ន្ធនានា ដើម្បីអាចឆ្លុះបញ្ចាំងនិងឆ្លើយតបទៅនឹងតថភាពសង្គមជាក់ស្តែង និងធានាឱ្យការអនុវត្តមានភាពរលូននិងប្រសិទ្ធភាព សម្រាប់ជាឧត្តមប្រយោជន៍ជាតិនិងប្រជាជន ស្របតាមគោលការណ៍តាក់តែងច្បាប់នៅតាមបណ្តាប្រទេសប្រជាធិបតេយ្យនានាផងដែរ។ បន្ថែមលើនេះទៀត កម្ពុជាបានចូលរួមជាមួយសហគមន៍អន្តរជាតិ ជាហត្ថលេខីក្នុងកិច្ចព្រមព្រៀង

សំខាន់ៗ ពាក់ព័ន្ធនឹងសន្តិសុខ អំពើភេរវកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ចតំបន់ និងពិភពលោក ព្រមទាំងបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងជាច្រើន ដែលផ្តល់ផលប្រយោជន៍ដល់មនុស្សជាតិទាំងមូល។ សមាហរណកម្មរបស់កម្ពុជាក្នុងពិភពលោក ដូចបញ្ជាក់ខាងលើនេះ តម្រូវឱ្យកម្ពុជាកសាងបទដ្ឋានគតិយុត្តស្របតាមគោលការណ៍អន្តរជាតិ និងបង្កើតស្ថាប័នពាក់ព័ន្ធ ដើម្បីធានាដល់ការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិនានា ឱ្យមានប្រសិទ្ធភាព។

ដើម្បីធានាដល់ការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាច្រើន ត្រូវបានកសាងនិងប្រកាសឱ្យប្រើ ដែលក្នុងនោះមានច្បាប់មួយចំនួនពាក់ព័ន្ធផ្ទាល់ទៅនឹងការរៀបចំការបោះឆ្នោត មានជាអាទិ៍ រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតនានា ក្រមជាមូលដ្ឋានទាំង៤ ដែលមាន ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត។ លើសពីនេះទៀត ក្នុងគោលដៅធានាឱ្យប្រជាពលរដ្ឋអនុវត្តសិទ្ធិរបស់ខ្លួន ដោយរលូននិងគ្មានការគំរាមកំហែង ក្នុងការចូលរួមគ្រប់ដំណាក់កាល នៃការបោះឆ្នោតតាមបែបប្រជាធិបតយ្យ រាជរដ្ឋាភិបាលបានបង្កើតយន្តការដែលមានឈ្មោះថា «**គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ**

**២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩»។**

### ២.៣. ការអនុវត្តច្បាប់

មាត្រា៤៩ នៃរដ្ឋធម្មនុញ្ញ ចែងថា «ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញនិងគោរពច្បាប់»។ ក្រោយពីច្បាប់ត្រូវបានប្រកាសឱ្យប្រើនិងចូលជាធរមាន អត្ថបទច្បាប់ទាំងនោះត្រូវបានបោះពុម្ពផ្សាយនៅក្នុងរាជកិច្ចដែលជាកម្រងឯកសារផ្លូវការរបស់រដ្ឋ។ ក្រសួង ស្ថាប័នធ្វើការផ្សព្វផ្សាយទូលំទូលាយជាមួយភាគីពាក់ព័ន្ធនានា ជាពិសេសប្រជាពលរដ្ឋទូទៅ ដើម្បីបញ្ជ្រាបការយល់ដឹងអំពីខ្លឹមសារនៃច្បាប់ទាំងនេះ ដល់ស្រទាប់មហាជនតាមរយៈសិក្ខាសាលា ការផ្សព្វផ្សាយ និងកម្មវិធីអប់រំផ្សេងៗ ក្នុងគោលដៅជំរុញការអនុវត្តឱ្យរលូននិងមានប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏យកចិត្តទុកដាក់បណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់តាមវិស័យ កងកម្លាំងមានសមត្ថកិច្ច មន្ត្រីតុលាការ ចៅក្រម និងព្រះរាជអាជ្ញា។ល។

រាជរដ្ឋាភិបាលប្តេជ្ញាចិត្តអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ដោយមានធាតុផ្សំពីសមាសធាតុសំខាន់៣យ៉ាងតិច គឺ (១) ច្បាប់មានសង្គតិភាពនិងឆ្លុះបញ្ចាំងពីតថភាពពិតក្នុងសង្គម (២) ប្រជាពលរដ្ឋយល់ដឹងច្បាស់ អំពីខ្លឹមសារនិងការគោរពច្បាប់ និង (៣) អ្នកអនុវត្តច្បាប់ត្រូវមានវិជ្ជាជីវៈ និងយល់ដឹងអំពីខ្លឹមសារច្បាប់ និងអនុវត្តច្បាប់ ដោយអព្យាក្រឹត មិនលម្អៀង ស្មើភាព និងប្រសិទ្ធភាព។

ក្នុងរយៈពេល៣ទសវត្សរ៍ចុងក្រោយនេះ ការបង្កើតស្ថាប័នដែលជាយន្តការគ្រប់គ្រងនិងអនុវត្តច្បាប់ ត្រូវបានរៀបចំ ហើយច្បាប់ជាច្រើនត្រូវបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ និងត្រូវបានប្រកាសឱ្យប្រើជាបន្តបន្ទាប់។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏យកចិត្តទុកដាក់រៀបចំលិខិតបទដ្ឋានគតិយុត្ត

ជាច្រើន លើការពង្រឹងសមត្ថភាពស្ថាប័ន បណ្តុះបណ្តាលធនធានមនុស្ស មន្ត្រីអនុវត្តច្បាប់ប្រកបដោយវិជ្ជាជីវៈ ព្រមទាំងបញ្ជ្រាបការយល់ដឹងអំពីខ្លឹមសារនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដល់អ្នកពាក់ព័ន្ធទាំងអស់ រួមទាំងប្រជាពលរដ្ឋផង។ ការងារទាំងអស់នេះពាក់ព័ន្ធទាំងស្រុងទៅនឹងការលើកកម្ពស់ និងទ្រទ្រង់ដល់ដំណើការនៃការអនុវត្តលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅកម្ពុជា។

អាទិភាពចម្បងមួយ ឆ្ពោះទៅរកការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសមួយ គឺការរៀបចំឱ្យមានយន្តការស្ថាប័ន និងក្របខ័ណ្ឌច្បាប់សម្រាប់ការគាំទ្រដល់ការអនុវត្តលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងការគោរពសិទ្ធិមនុស្ស។ ក្នុងន័យនេះ ដោយសារការប្តេជ្ញាចិត្តដ៏មោះមុតបំផុតរបស់រាជរដ្ឋាភិបាល កម្ពុជាបានបង្កើតស្ថាប័ននិងក្របខ័ណ្ឌច្បាប់ចាំបាច់និងពាក់ព័ន្ធជាច្រើន។ ជារួម យើងសង្កេតឃើញថា ស្ថាប័នប្រជាធិបតេយ្យទាំងអស់ខាងលើ បាននិងកំពុងបំពេញការងាររបស់ខ្លួនយ៉ាងសកម្ម តែដំណើរការត្រូវការទាមទារពេលវេលាថែមទៀត ដើម្បីពង្រឹងសមត្ថភាព ភាពជាម្ចាស់ និងប្រសិទ្ធភាពការងាររបស់មន្ត្រីពាក់ព័ន្ធ ឱ្យបានកាន់តែល្អប្រសើរ។

### ២.៤. ការរៀបចំការបោះឆ្នោត

ដោយមិនរាប់បញ្ចូលការបោះឆ្នោតដែលរៀបចំដោយ UNTAC នៅឆ្នាំ១៩៩៣ គ.ជ.ប. បានរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចំនួន ៤ដង និងកំពុងដំណើការរៀបចំការបោះឆ្នោតលើកទី៥ នៅខែកក្កដា ឆ្នាំ ២០១៨ ហើយសមាជិកព្រឹទ្ធសភាចំនួន៣ដង និងកំពុងដំណើការរៀបចំការបោះឆ្នោតលើកទី៤ នៅខែកុម្ភៈ ឆ្នាំ២០១៨ ព្រមទាំងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចំនួន២ដង និងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ចំនួន៤ដង ដោយជោគជ័យរួចមកហើយ។ ការបោះឆ្នោតឆ្នាំ២០១៣

បង្ហាញថា ប្រជាជនដែលបានទៅបោះឆ្នោតមានអត្រា៦៩,៦១% ស្មើនឹង ៦ ៧៣៥ ២៤៤នាក់ ក្នុងចំណោមអ្នកចុះឈ្មោះបោះឆ្នោតចំនួន៩ ៦៧៥ ៤៥៣ នាក់ ហើយការបោះឆ្នោតឆ្នាំ២០១៧ ប្រជាជនដែលបានទៅបោះឆ្នោតមានអត្រា៩០,៣៧% ស្មើនឹង៧ ១០៧ ៣៩៥នាក់ ក្នុងចំណោមអ្នកចុះឈ្មោះបោះឆ្នោតចំនួន៧ ៨៦៥ ០៣៣នាក់ ដែលអត្រានេះមានកម្រិតខ្ពស់ ធៀបនឹងអត្រាប្រជាជនដែលទៅបោះឆ្នោតនៅប្រទេសជាច្រើន។ បរិយាកាសនៃការបោះឆ្នោតបានប្រព្រឹត្តទៅ ដោយរលូន និងសន្តិភាព។ ជោគជ័យនៃការបោះឆ្នោតនេះ ឆ្លុះបញ្ចាំងឱ្យឃើញអំពីការវិវត្តជាវិជ្ជមាន ប្រកបដោយមោទនភាពចំពោះលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ប្រជាពលរដ្ឋមានសិទ្ធិពេញលេញ ក្នុងការសម្តែងចេញនូវឆន្ទៈរបស់ខ្លួន នៅគ្រប់ដំណាក់កាលនៃដំណើរការបោះឆ្នោត។ ប្រជាពលរដ្ឋ បានចូលរួមក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ដើម្បីបង្ហាញអំពីការគាំទ្រចំពោះគណបក្សនយោបាយ ដែលខ្លួនពេញចិត្ត ដោយពុំមានការភ័យខ្លាច។ សកម្មជនគណបក្សនីមួយៗ បានធ្វើសកម្មភាពនយោបាយរបស់ខ្លួនដោយសេរី ពុំមានការគាបសង្កត់ឬការគំរាមកំហែងពីមជ្ឈដ្ឋានណាមួយឡើយ។ ក្នុងដំណើរការបោះឆ្នោតនេះ ពុំមានអំពើហិង្សាធ្ងន់ធ្ងរដែលប៉ះពាល់ដល់ដំណើរការបោះឆ្នោត ហើយក៏ពុំឃើញមានរបាយការណ៍ណាមួយ អំពីការរំលោភបំពានឬការធ្វើឃាតខាងនយោបាយ ដល់សមាជិកគណបក្សនយោបាយណាមួយនោះទេ។ ការបោះឆ្នោតបានប្រព្រឹត្តទៅក្រោមការឃ្លាំមើលរបស់អ្នកសង្កេតការណ៍អន្តរជាតិ ចំនួន២៩២នាក់ និងអ្នកសង្កេតការណ៍ជាតិចំនួន៤០ ១៤២នាក់ ដែលបានវាយតម្លៃថា ការបោះឆ្នោតនេះបានប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ និងតម្លាភាព។ អ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិបានធ្វើការវាយតម្លៃថា ការរៀបចំការបោះឆ្នោតជាបន្តបន្ទាប់ បានប្រព្រឹត្តទៅកាន់តែល្អប្រសើរឡើង ជាពិសេស ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់កាលពីខែមិថុនា ឆ្នាំ២០១៧ កន្លងទៅនេះ ហើយប្រព័ន្ធចុះឈ្មោះ

បោះឆ្នោតដែលត្រូវបានធ្វើទំនើបកម្ម ពុំត្រូវបានគណបក្សនយោបាយណាមួយ ធ្វើការរិះគន់ឬយកទៅបង្កើតជាលេស ដើម្បីមួលបង្កាច់លទ្ធផលនៃការបោះឆ្នោតនេះ ថាមានភាពមិនប្រក្រតីនោះទេ។

## ២.៥. ការធានាសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម

ប្រវត្តិសាស្ត្របានបង្ហាញថា កម្ពុជាបានឆ្លងកាត់នូវដំណាក់កាលនៃសង្គ្រាម និងការផ្លាស់ប្តូររបបគ្រប់គ្រងរដ្ឋ ដោយមូលហេតុជាច្រើន ដូចជាការដណ្តើមភូមិសាស្ត្រនយោបាយ ការប្រកួតប្រជែងមនោគមវិជ្ជា ជម្លោះដណ្តើមទឹកដី ការដណ្តើមអំណាចផ្ទៃក្នុង របបប្រល័យពូជសាសន៍ ដែលបណ្តាលមកពីការជ្រៀតជ្រែក និងការពង្រីកឥទ្ធិពលនយោបាយក្នុងតំបន់របស់បរទេស។ ចាប់ពីសម័យចក្រភពអង្គរមក រហូតដល់បច្ចុប្បន្ននេះ កម្ពុជាបានឆ្លងកាត់របបប្រល័យពូជសាសន៍ដ៏សាហាវឃោរឃៅ ដែលជាមហាវិនាសកម្មដ៏ធំបំផុតក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ នាចុងសតវត្សរ៍ទី២០ នៅចន្លោះឆ្នាំ១៩៧៥-១៩៧៩។

បន្ទាប់ពីការដួលរលំរបប ប៉ុល ពត ប្រជាពលរដ្ឋខ្មែរបានទទួលសិទ្ធិសេរីភាពឡើងវិញ និងបានខិតខំកសាងប្រទេសពីចំណុចសូន្យ ទោះបីជាធនធានមនុស្សត្រូវបានកាប់សម្លាប់ស្ទើរតែទាំងអស់ ហើយប្រជាពលរដ្ឋភាគច្រើនជាស្ត្រីមេម៉ាយ ជនពិការ និងកុមារកំព្រា ហើយមានជំងឺនិងសុខភាពទ្រុឌទ្រោមក៏ដោយ។ ស្របពេលដែលរាជរដ្ឋាភិបាលខិតខំស្តារនិងកសាងស្ថាប័នរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមឡើងវិញ ការដោះស្រាយបញ្ហាអត់ឃ្លាន និងការទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ ប៉ុល ពត គឺជាអាទិភាពដ៏សំខាន់បំផុតនៅពេលនោះ។ បន្ថែមលើកាលៈទេសៈដ៏លំបាកនេះ បស្ចិមប្រទេសបានដាក់ការហ៊ុំព័ទ្ធសេដ្ឋកិច្ច និងនយោបាយ ដើម្បីធ្វើឱ្យកម្ពុជាស្ថិតនៅក្នុងភាពឯកោលើឆាកអន្តរជាតិ ហើយប្រទេសខ្លះ

ទៀតបានគាំទ្រពួកឃាតករ ប៉ុល ពត ឱ្យបន្តកាន់កាប់អាសនៈកម្ពុជានៅអង្គការសហប្រជាជាតិ អស់រយៈពេលជាង១០ឆ្នាំ ។

ទោះបីជាមានអន្តរាគមន៍របស់សហគមន៍អន្តរជាតិ តាមរយៈ UNTAC ដែលបានចំណាយថវិកាអស់ជាង២ពាន់លានដុល្លារអាមេរិក ដើម្បីបញ្ចប់សង្គ្រាមនិងរៀបចំការបោះឆ្នោតនៅឆ្នាំ១៩៩៣ ស្របតាមស្មារតីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ក្តី ក៏សង្គ្រាមនៅតែបន្តកើតមានលើទឹកដីកម្ពុជាដដែល ដោយសារពួកឧទ្ទាមខ្មែរក្រហមធ្វើពហិកាការបោះឆ្នោត ហើយរចនាសម្ព័ន្ធអង្គការចាត់តាំងនយោបាយ និងយោធារបស់ខ្មែរក្រហមមិនទាន់ត្រូវបានរំលាយនៅឡើយ។ ទន្ទឹមគ្នានេះដែរ ភាគីបីក្នុងចំណោមភាគីទាំងបួន គឺភាគីរដ្ឋកម្ពុជា ភាគីហ៊្វុនស៊ិនប៉ិច និងភាគីរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ បានចូលរួមអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ នេះបញ្ជាក់ថាការអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលមាន UNTAC ជាអាជ្ញាធរបណ្តោះអាសន្ន និងឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់(SNC) មិនអាចសម្រេចបានជោគជ័យ ក្នុងការបង្រួបបង្រួមជាតិទាំងស្រុងនៅកម្ពុជានោះទេ។ នៅពេលដែល UNTAC បានចាកចេញពីកម្ពុជា ស្ថាប័នរដ្ឋនានាមិនទាន់ត្រូវបានពង្រឹង និងដាក់ឱ្យដំណើរការរលូននៅឡើយទេ ហើយអង្គការចាត់តាំងនយោបាយ និងយោធារបស់ខ្មែរក្រហម នៅតែបន្តសកម្មភាពឧទ្ទាមប្រឆាំងរាជរដ្ឋាភិបាលស្របច្បាប់ ដែលត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោតជាសកលលើកទី១នៅកម្ពុជា។ អង្គការចាត់តាំងនយោបាយនិងយោធារបស់ខ្មែរក្រហមទើបតែត្រូវបានរំលាយចោលទាំងស្រុង នៅឆ្នាំ១៩៩៨ ដោយសារនយោបាយឈ្នះ-ឈ្នះ របស់សម្តេចតេជោ **ហ៊ុន សែន** ដែលឈរលើគោលការណ៍ ៣គឺ (១) ការធានាអាយុជីវិតនិងរូបកាយ (២) ការធានារក្សានូវអាជីពនិងមុខរបរ និង(៣) ការរក្សានូវកម្មសិទ្ធិលើទ្រព្យសម្បត្តិ ទាំងអចលនទ្រព្យនិង

ទាំងចលនទ្រព្យរបស់កម្លាំងអតីតខ្មែរក្រហមគ្រប់ជាន់ថ្នាក់ ដែលផ្តាច់ខ្លួនចេញពីចលនារបស់ខ្មែរក្រហម។ ជាមួយគ្នានេះដែរ ច្បាប់ដាក់ឱ្យខ្មែរក្រហមនៅក្រៅច្បាប់ ក៏ត្រូវបានអនុម័តដោយរដ្ឋសភា។

ក្នុងគោលដៅសម្រេចបានជោគជ័យ នៃការអនុវត្តគោលនយោបាយខាងលើ សម្តេចតេជោ **ហ៊ុន សែន** បានលះបង់គ្រប់បែបយ៉ាង តម្កល់ផលប្រយោជន៍ជាតិជាធំ និងស្វែងរកការបង្រួបបង្រួមជាតិ ដែលបែកបាក់ដោយសារសង្គ្រាម។ ការលះបង់ដ៏គ្រោះថ្នាក់បំផុតមួយ គឺសម្តេចតេជោបានចូលទៅដល់តំបន់ប៉ៃលិន ដែលជាមូលដ្ឋានដ៏រឹងមាំរបស់ខ្មែរក្រហម ដើម្បីផ្តល់ជំនឿទុកចិត្ត និងស្វាគមន៍ចំពោះការធ្វើសមាហរណកម្មរបស់បងប្អូនអតីតខ្មែរក្រហម ហើយការលះបង់នេះ បានក្លាយទៅជាចំណុចចាប់ផ្តើមនៃការទាក់ទាញកម្លាំងខ្មែរក្រហមផ្សេងទៀត ឱ្យវិលត្រឡប់ចូលមករួមរស់ក្នុងសង្គមជាតិវិញ ដែលនេះជាកត្តា ធ្វើឱ្យកម្ពុជាទទួលបានសុខសន្តិភាពពេញលេញនៅទូទាំងប្រទេស។ **តើនរណាជាអ្នកទទួលផលពីសន្តិភាពនេះ? គឺប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ហើយក្នុងនោះក៏មានក្រុមអ្នកប្រឆាំងដែរ។**

ក្នុងរយៈពេលជិត៣ទសវត្សរ៍នៃសង្គ្រាមផ្ទៃក្នុង កម្ពុជាមិនគ្រាន់តែបាត់បង់ឱកាសទាំងស្រុងក្នុងការអភិវឌ្ឍ ធៀបនឹងប្រទេសនានាក្នុងតំបន់និងលើពិភពលោកប៉ុណ្ណោះទេ តែថែមទាំងត្រូវបានបំផ្លិចបំផ្លាញដល់ឫសគល់។ តាមរយៈមេរៀននិងបទពិសោធន៍ដ៏ល្វីងជូរចត់នេះ ប្រជាជនកម្ពុជាប្រឆាំងដាច់ខាតចំពោះទង្វើឬការប៉ុនប៉ងណាមួយ ដែលអាចបង្កឱ្យកើតមានសង្គ្រាមឡើងវិញ។ ក្នុងនាមជាប្រជាជាតិមួយ ដែលធ្លាប់ឆ្លងកាត់នូវព្រឹត្តិការណ៍ដ៏ខ្លោចផ្សារនេះ កម្ពុជាសូមចូលរួមសោកស្តាយយ៉ាងខ្លាំង ចំពោះប្រជាជននៃប្រទេសមួយចំនួន ដែលកំពុងទទួលរងទុក្ខវេទនាគ្រប់បែបយ៉ាង ដែលបង្កឡើង

ដោយសង្គ្រាមនៅអាស៊ី មជ្ឈិមបូព៌ា អាហ្វ្រិក និងអឺរ៉ុបខាងកើត ដែលបានផុតពេលដោយមហាអំណាច។

កម្ពុជាជាប្រជាជាតិ ដែលត្រូវបានស្គាល់តាមរយៈអំពើប្រល័យពូជសាសន៍ (វាលពិឃាដ) និងសង្គ្រាម ប៉ុន្តែបច្ចុប្បន្នបានលេចមុខមាត់លើឆាកអន្តរជាតិ តាមរយៈការចូលរួមយ៉ាងសកម្មក្នុងកិច្ចការតំបន់និងអន្តរជាតិ ដោយឈរលើគោលការណ៍ស្មើភាព និងស្មើសិទ្ធិ។ កម្ពុជាដែលធ្លាប់ត្រូវបានប្រទេសជិតខាង និងសហគមន៍អន្តរជាតិជួយស្វែងរកសន្តិភាព និងការពារសន្តិសុខ តែបានប្រែក្លាយជាប្រជាជាតិមួយ ដែលចូលរួមជួយការពារសន្តិសុខនិងស្វែងរកសន្តិភាព ជូនប្រជាជាតិដទៃ ដែលកំពុងជួបវិបត្តិ ឬមានសង្គ្រាមធ្ងន់ធ្ងរ។ បន្ថែមលើនេះទៀត កម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងការថែរក្សានិងអភិរក្សសម្បត្តិវប្បធម៌មនុស្សជាតិ នៅតាមវេទិកាវប្បធម៌អន្តរជាតិនានា ទន្ទឹមពេលដែលកម្ពុជាក៏បានក្លាយជាគំរូនៃការស្តារ ជួសជុល និងអភិរក្សសម្បត្តិបេតិកភណ្ឌ និងវប្បធម៌របស់មនុស្សជាតិ។

ក្នុងប្រវត្តិសាស្ត្រ៥០០ឆ្នាំចុងក្រោយនេះ កម្ពុជាទទួលបានសុខសន្តិភាពពេញលេញជាលើកដំបូងនៅទូទាំងប្រទេស។ សន្តិភាពមានតម្លៃធំធេងបំផុតសម្រាប់ប្រជាពលរដ្ឋខ្មែរទូទៅ ដូច្នេះហើយទើបសម្តេចតេជោ **ហ៊ុន សែន** បុគេដ្ឋាថែរក្សាសន្តិភាពដែលសម្រេចបានដោយលំបាកនេះ ឱ្យស្ថិតស្ថេរជារៀងរហូត ទោះក្នុងតម្លៃណាក៏ដោយ។ **សង្គ្រាមអាចកើតឡើងយ៉ាងងាយនិងឆាប់រហ័ស ហើយរីករាលដាលយ៉ាងលឿន ប៉ុន្តែមិនអាចបញ្ចប់ទៅវិញដោយងាយស្រួលនោះទេ។** សម្តេចតេជោ **ហ៊ុន សែន** ថ្លែងម្តងហើយម្តងទៀតថា **សង្គ្រាមដែលទើបចប់ថ្មីៗនេះ អាចកើតឡើងវិញបាននៅកម្ពុជា**។ ប្រសាសន៍បែបនេះ មិនមែនជាការគំរាមកំហែង ឬការប្រើចិត្តសាស្ត្រ ដើម្បីយកប្រៀបលើគូប្រជែង ដូចការលើកឡើងរបស់ក្រុមប្រឆាំង ដែលថា ពួកគេគ្មានអាវុធនោះ

ទេ ប៉ុន្តែដោយសារសំដី សកម្មភាព និងអំពើប្រទូស្តរ៉ាយផ្សេងៗ ក៏ជាមូលហេតុដែលអាចនាំឱ្យមានសង្គ្រាមកើតឡើងដែរ ដូចជា៖

១. គណបក្សប្រឆាំង បានប្រើប្រាស់បញ្ហាព្រំដែនជាមួយប្រទេសជិតខាង ធ្វើជាមធ្យោបាយបញ្ឆេះកំហឹងនិងញុះញង់ឱ្យមានគំនុំជាតិសាសន៍ ក្នុងគោលបំណងទាក់ទាញសមានចិត្តពីអ្នកគាំទ្រខ្លួន ដែលជាហេតុធ្វើឱ្យមានការប្រទូស្តរ៉ាយ រវាងប្រជាជនកម្ពុជានិងប្រជាជននៃប្រទេសមួយផ្សេង រវាងរដ្ឋាភិបាលនិងរដ្ឋាភិបាល ដែលអាចនាំទៅដល់ការបែកបាក់ជាតិនិងការកកើតសង្គ្រាមរវាងប្រទេសនិងប្រទេស។ ដោយសារតែចង់បានអំណាចអ្នកនយោបាយមិនគួរលេងល្បែងដ៏គ្រោះថ្នាក់បែបនេះ ដើម្បីរុញច្រានប្រទេសឱ្យធ្លាក់ក្នុងភ្នក់ភ្លើងសង្គ្រាមឡើងវិញនោះទេ។

២. សម រង្ស៊ី និងបក្សពួកបានអំពាវនាវជាច្រើនលើកច្រើនសា ឱ្យប្រជាជននិងកងកម្លាំងប្រដាប់អាវុធ បះបោរនិងបែរចុងអាវុធប្រឆាំងនឹងរាជរដ្ឋាភិបាលស្របច្បាប់។ ទង្វើជ្រុលនិយមបែបនេះ គឺជាការអុចអាលដែលអាចបង្កឱ្យមានភាពប្រទូស្តរ៉ាយ និងការបែកបាក់ផ្ទៃក្នុងក្នុងចំណោមកម្លាំងប្រដាប់អាវុធ ប្រសិនបើមានក្រុមណាមួយធ្វើតាមការអំពាវនាវរបស់មេដឹកនាំគណបក្សប្រឆាំង ហើយរាជរដ្ឋាភិបាលគ្មានសមត្ថភាពគ្រប់គ្រងស្ថានការណ៍។

៣. គណបក្សប្រឆាំង បានទាមទារឱ្យកាត់ទោសមេដឹកនាំខ្មែរក្រហមពាក់ព័ន្ធជាច្រើននាក់ទៀត ដោយមិនខ្វល់អំពីផលវិបាកធ្ងន់ធ្ងរនានា ដែលនឹងអាចកើតមានឡើង ដូចជា ការងើបបះបោរនិងការវិលត្រឡប់របស់អតីតខ្មែរក្រហម ទៅបង្កបង្កើតជាកម្លាំងឧទ្ទាមឡើងវិញ ដែលអាចធ្វើឱ្យប៉ះពាល់ដល់សន្តិភាពនិងការអភិវឌ្ឍប្រទេស និងដោយមិនបានគិតគូរដល់គោលការណ៍សំខាន់ៗមួយចំនួន ដូចជា (១) ការកាត់ទោសអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ដែលបានបាត់បង់ជីវិត និង

ជនរងគ្រោះនិងក្រុមគ្រួសារដែលនៅរស់រានមានជីវិត (២) ការរួមចំណែកដល់ការពង្រឹងប្រព័ន្ធយុត្តិធម៌អន្តរជាតិ និង (៣) ជាមេរៀនដល់មនុស្សជំនាន់ក្រោយ ឱ្យចៀសវាងប្រព្រឹត្តបទឧក្រិដ្ឋបែបនេះទៀត។

៤. បដិវត្តន៍ពណ៌ ដែលបានរៀបចំដោយគណបក្សប្រឆាំងអស់រយៈពេលជាច្រើនឆ្នាំមកនេះ ជាពិសេស នៅឆ្នាំ២០១៣ និងដែលបន្តដាក់គោលដៅក្នុងការធ្វើបដិវត្តន៍ពណ៌ជាថ្មីនៅឆ្នាំ២០១៨ គឺជារងើកភ្លើងដែលអាចនាំឱ្យកើតមានសង្គ្រាមនៅកម្ពុជា បើគ្មានការទប់ស្កាត់ និងការរំលាយចោលអង្គការចាត់តាំងនយោបាយរបស់ចលនាបដិវត្តន៍ពណ៌បានទាន់ពេលវេលានោះទេ។

ថ្នាក់ដឹកនាំកម្ពុជាមានសុភវិនិច្ឆ័យយ៉ាងច្បាស់ថា សន្តិភាព និងស្ថិរភាពនយោបាយ គឺជាកត្តាចម្បងសម្រាប់នាំប្រទេស ឱ្យមានការអភិវឌ្ឍ លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ហើយមិនអនុញ្ញាតឱ្យបុគ្គល បក្ស ក្រុម ឬបរទេសណាមួយ បំផ្លាញជាដាច់ខាត។ ទង្វើទាំងឡាយណាដែលបង្កឡើងដោយក្រុមណាមួយក្នុងគោលដៅបំផ្លិចបំផ្លាញជាតិ សន្តិភាព និងបង្កបង្កើតឱ្យមានសង្គ្រាមជាថ្មីម្តងទៀតនៅលើទឹកដីកម្ពុជានោះ គឺមិនអាចអត់ឱនឱ្យបានជាដាច់ខាត និងត្រូវចាត់វិធានការតាមផ្លូវច្បាប់ ពីព្រោះទង្វើបែបនេះអាចប៉ះពាល់ដល់ជីវភាពរស់នៅ ឬអាយុជីវិតរបស់មនុស្សរាប់ម៉ឺនរាប់សែន ឬរាប់លាននាក់។

សង្គ្រាមរយៈពេល៣ទសវត្សរ៍ បានបង្កជាឧបសគ្គយ៉ាងធំដល់ការកសាងប្រទេស ក្នុងអំឡុងពេលនេះបណ្តាប្រទេសនានាបានខិតខំប្រឹងប្រែងកៀរគរធនធានសរុបក្នុងស្រុក ទាក់ទាញជំនួយអភិវឌ្ឍន៍ និងវិនិយោគបរទេសដើម្បីពង្រឹងមូលដ្ឋានផលិតកម្ម ជំរុញវិស័យឯកជន និងកសាងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។ បន្ទាប់ពីការបោះឆ្នោត

ឆ្នាំ១៩៩៣មក កម្ពុជាបានផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍ ទោះបីជាខ្មែរក្រហមនៅតែបន្តបង្កវិនាសកម្ម និងបំផ្លិចបំផ្លាញនៅតាមតំបន់មួយចំនួន ហើយរាជរដ្ឋាភិបាលចម្រុះមិនមានភាពស៊ីសង្វាក់ការងារ និងបង្កជាភាពចម្រូងចម្រាស់ជាច្រើន។ នៅក្នុងដំណាក់កាលថ្មីនេះ កម្ពុជាត្រូវប្រឈមការប្រកួតប្រជែងយ៉ាងស្រួចស្រាល់ជាមួយប្រទេសនានា ក្នុងការទាក់ទាញវិនិយោគបរទេស និងការអភិវឌ្ឍផលិតកម្មក្នុងស្រុក ស្របពេលដែលកម្ពុជានៅខ្វះទុនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្សសម្រាប់ការអភិវឌ្ឍរបស់ខ្លួន។ ប្រឈមមុខនឹងសភាពការណ៍បែបនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកម្មវិធីកំណែទម្រង់នានា ដូចជា កំណែទម្រង់រដ្ឋបាលសាធារណៈនិងអភិបាលកិច្ច កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់ដីធ្លី ជាដើម ដើម្បីទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។

ដោយសារនយោបាយឈ្នះ-ឈ្នះ នៅឆ្នាំ១៩៩៨ អង្គការចាត់តាំងយោធា និងនយោបាយរបស់ខ្មែរក្រហមត្រូវបានដួលរលំ ហើយកម្ពុជាបានទទួលនូវសន្តិភាពទាំងស្រុង។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចតេជោ **ហ៊ុន សែន** បានប្តេជ្ញាចិត្តជំរុញការអភិវឌ្ឍប្រទេសលើគ្រប់វិស័យ ប៉ុន្តែក្នុងកំលុងពេលវិបត្តិហិរញ្ញវត្ថុឆ្នាំ១៩៩៧ ដែលផ្តើមចេញពីប្រទេសថៃ ហើយដែលបានរាលដាលនិងបក់បោកយ៉ាងខ្លាំងដល់បណ្តាប្រទេសអាស៊ានជាច្រើនទៀត សេដ្ឋកិច្ចកម្ពុជាក៏រងផលប៉ះពាល់ជាអវិជ្ជមានពីវិបត្តិនេះផងដែរ។ បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុត្រូវបានបញ្ចប់ សេដ្ឋកិច្ចកម្ពុជាក៏បានងើបឡើងវិញ ស្របពេលដែលសេដ្ឋកិច្ចក្នុងតំបន់ ត្រូវបានធ្វើកំណែទម្រង់ស៊ីជម្រៅ ដើម្បីស្តារទំនុកចិត្តនិងដាក់ចេញនូវគោលនយោបាយថ្មីនៃការអភិវឌ្ឍប្រកបដោយចីរភាព។ ទន្ទឹមនឹងនេះ កម្ពុជាក៏បានរងផលប៉ះពាល់ជាបន្តទៀតពីវិបត្តិនៃជម្ងឺ SARS ដែលបានកើតឡើងក្នុងតំបន់ នៅឆ្នាំ

២០០៣ បន្ថែមលើវិបត្តិនយោបាយផ្ទៃក្នុង អស់រយៈពេលជិតមួយឆ្នាំ ក្រោយពីការបោះឆ្នោតឆ្នាំ២០០៣ រហូតដល់ឆ្នាំ២០០៤។



*រូបភាពទី១៖ វិមានឯករាជ្យ*

ទោះជាយ៉ាងនេះក្តី ដោយសារកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានកំណើន ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ក្នុងអត្រា ១៣,៣% ក្នុងឆ្នាំ២០០៥ ប៉ុន្តែអត្រានេះបានធ្លាក់ចុះយ៉ាងខ្លាំង ដល់០,១% ក្នុងឆ្នាំ២០០៩ ដោយសារផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុនិងសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០០៨ ក្នុងពេលដែលប្រទេសភាគច្រើនក្នុងតំបន់និងពិភពលោកមានអត្រាកំណើនអវិជ្ជមាន។ នៅឆ្នាំ២០១០ សេដ្ឋកិច្ចកម្ពុជាទទួលបានកំណើន៦% ហើយបានរក្សាកំណើននេះក្នុងរង្វង់៧% ចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៧។ ជាមួយគ្នានេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានចាត់ទុកកម្ពុជាថា ជាប្រទេសមួយ ក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្ពស់បំផុតនៅក្នុងតំបន់អាស៊ី ហើយបានប្រសិទ្ធនាមថា ជា«ខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី» ទៀតផង។ នៅឆ្នាំ២០១៧-២០១៨ តាមការប៉ាន់ស្មាន កម្ពុជាបានបន្តរក្សាកំណើនសេដ្ឋកិច្ចក្នុងអត្រាជាមធ្យម៧% ដោយសារកំណើនជាវិជ្ជមាន ក្នុង

វិស័យកសិកម្ម ឧស្សាហកម្ម វិស័យកាត់ដេរ ទេសចរណ៍ និងការរីកធំធាត់នៃវិស័យសំខាន់ៗដទៃទៀត ដូចជាសេវាកម្ម និងអចលនទ្រព្យ។

ដោយសារកំណើនរឹងមាំនៃសេដ្ឋកិច្ច ប្រាក់ចំណូលមធ្យមសម្រាប់មនុស្សម្នាក់មានចំនួន១ ៤៣៥ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ ធៀបនឹងប្រាក់ចំណូលមធ្យមសម្រាប់មនុស្សម្នាក់ មានត្រឹមតែ៨៣០ដុល្លារអាមេរិក នៅឆ្នាំ២០១០។ អតិផរណាត្រូវបានប៉ាន់ស្មានថានឹងមានអត្រា៣,៨% ក្នុងឆ្នាំ២០១៧ ធៀបនឹង៣,០% ក្នុងឆ្នាំ២០១៦ ដោយសារការកើនឡើងនៃថ្លៃប្រេងក្នុងទីផ្សារអន្តរជាតិ។

អត្រាភាពក្រីក្រនៅកម្ពុជាមានចំនួន១០០% នៅឆ្នាំ១៩៧៩ បានធ្លាក់មកនៅត្រឹម៥៣,២% នៅឆ្នាំ២០០៤ ហើយបន្តធ្លាក់ចុះយ៉ាងលឿនមកត្រឹម១៣,៥% នៅឆ្នាំ២០១៤។ អត្រានៃភាពក្រីក្រនេះបានបន្តធ្លាក់ចុះថែមទៀតនៅឆ្នាំ២០១៦ ដោយសារកំណើនសេដ្ឋកិច្ចនៅរក្សាក្នុងអត្រាមធ្យម៧% ពីឆ្នាំ២០១៥-២០១៧។ ជាមួយគ្នានេះដែរ ក្នុងខណៈដែលគម្លាតរវាងអ្នកមានចំណូលទាបនិងអ្នកមានចំណូលខ្ពស់លើសកលលោក បន្តកើនឡើង គម្លាតនេះបែរជាមានការធ្លាក់ចុះជាបន្តបន្ទាប់នៅកម្ពុជា។ ដោយសារសន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខដ៏រឹងមាំ កម្ពុជាបន្តសម្រេចបាននូវសមិទ្ធផលថ្មីៗជាច្រើនទៀត ក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងកែលម្អជីវភាពរស់នៅរបស់ប្រជាជន។ ជាលទ្ធផល កម្ពុជាបានក្លាយពីប្រទេសមានចំណូលទាប ទៅជាប្រទេសចំណូលមធ្យមកម្រិតទាប និងកំពុងបន្តក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០។ **តើក្រុមប្រឆាំងមានបានឃើញទេអំពីសមិទ្ធផលទាំងនេះ?**

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានកៀរគរហិរញ្ញវត្ថុសម្រាប់ការវិនិយោគសាធារណៈ យ៉ាងច្រើនសន្ធឹកសន្ធាប់ពីដៃគូអភិវឌ្ឍន៍

បណ្ដាប្រទេសជាមិត្ត និងវិស័យឯកជន ព្រមទាំងបានអនុម័តលើគម្រោងវិនិយោគឯកជនដ៏ច្រើនសន្ធឹកសន្ធាប់ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

ទេសចរណ៍វប្បធម៌ គឺជាវិស័យអាទិភាពចម្បង ផ្អែកលើសម្បត្តិបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ នៅតំបន់សៀមរាប-អង្គរ ប្រាសាទព្រះវិហារ ប្រាសាទសំបូរព្រៃគុក និងតំបន់ផ្សេងៗទៀត ខណៈដែលទេសចរណ៍ធម្មជាតិក៏មានសក្តានុពលធំធេង និងមានប្រៀបប្រកួតប្រជែងក្នុងតំបន់ផងដែរ។ ដោយសារមានស្ថិរភាពនិងសន្តិភាព នៅទូទាំងប្រទេស ភ្ញៀវទេសចរអន្តរជាតិមកទស្សនាកម្ពុជា មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ជាក់ស្តែង នៅឆ្នាំ ១៩៩៣ ចំនួនភ្ញៀវទេសចរអន្តរជាតិមានតែ១១៨ ១៨៣នាក់ប៉ុណ្ណោះ ធៀបនឹងចំនួន៥,៦លាននាក់នៅឆ្នាំ២០១៧ ហើយតាមការប៉ាន់ស្មាន ចំណូលបានមកពីវិស័យនេះ មានអត្រាប្រមាណ១២% នៃ ផ.ស.ស. និងអាចបង្កើតការងារដោយផ្ទាល់និងប្រយោលរាប់លានកន្លែង។ តាមការព្យាករ កម្ពុជានឹងទទួលបានភ្ញៀវទេសចរអន្តរជាតិប្រមាណ១៥លាននាក់ នៅឆ្នាំ២០៣០។ ក្នុងពេលដែលសហរដ្ឋអាមេរិក ក៏ដូចជាសភាអឺរ៉ុបកំពុងគំរាមដាក់សម្ពាធមកលើកម្ពុជាដោយគ្មានសុភវិនិច្ឆ័យ ក្រុមប្រឹក្សាទេសចរណ៍ និងពាណិជ្ជកម្មអឺរ៉ុបបានផ្តល់យុត្តិធម៌ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការជ្រើសតាំង សម្តេចតេជោ **ហ៊ុន សែន** ជា «**ឯកអគ្គរដ្ឋទូតសុច្ឆន្ទៈពិភពលោកសម្រាប់វិស័យទេសចរណ៍ និងគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព**» ហើយថែមទាំងបានផ្តល់ជ័យលាភីជូនរាជធានីភ្នំពេញជា «**រាជធានីនៃវប្បធម៌និងទេសចរណ៍ពិភពលោក**» ផងដែរ។

រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ចំពោះកំណែទម្រង់លើវិស័យអប់រំ ហើយជាលទ្ធផល យើងពិនិត្យឃើញថា វិស័យអប់រំត្រូវបានកែលម្អឱ្យ

កាន់តែប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងគោលដៅធ្វើឱ្យគុណភាពនៃការអប់រំសម្រេចបាននៅគ្រប់កម្រិត។ ទន្ទឹមនឹងនេះ នៅឆ្នាំ២០១៨ រាជរដ្ឋាភិបាលក៏យកចិត្តទុកដាក់លើវិស័យបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដើម្បីពង្រឹងសមត្ថភាពចំណេះដឹង ចំណេះធ្វើ និងជំនាញដល់កម្មករ កម្មការិនី បុគ្គលិកក្រុមហ៊ុន និងអ្នកពាក់ព័ន្ធទាំងអស់ ឱ្យស្របទៅនឹងលក្ខខណ្ឌការងារថ្មី និងបម្រែបម្រួលនៃស្ថានភាពការងារនិងបច្ចេកវិទ្យាទំនើប។

រាជរដ្ឋាភិបាល បានកំណត់យកការលើកកម្ពស់សុខភាពសាធារណៈជាអាទិភាពមួយ ក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្សតាមរយៈការកសាងមណ្ឌលសុខភាពនៅតាមមូលដ្ឋានគ្រប់ឃុំ សង្កាត់ បន្ថែមទៅលើមន្ទីរពេទ្យបង្អែក មន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យជាតិ។ រាជរដ្ឋាភិបាលក៏យកចិត្តទុកដាក់លើការកសាងសមត្ថភាពបុគ្គលិកពេទ្យ គិលានុបដ្ឋាក និងវេជ្ជបណ្ឌិតទូទៅនិងជំនាញ ដើម្បីឱ្យពួកគេមានលទ្ធភាពផ្ដល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋ ប្រកបដោយសីលធម៌ វិជ្ជាជីវៈ និងប្រសិទ្ធភាពខ្ពស់។

ក្នុងរយៈពេល៥ឆ្នាំនេះ ជាមួយនឹងផ្លែផ្កានៃកំណើនសេដ្ឋកិច្ច ប្រាក់បៀវត្សអប្បបរមារបស់មន្ត្រីរាជការបានកើនឡើងបីដង ហើយនៅឆ្នាំ២០១៨នេះ ប្រាក់បៀវត្សមន្ត្រីរាជការនឹងកើនដល់យ៉ាងតិច១លានរៀល ក្នុងមួយខែ។

វិស័យកាត់ដេរមានការអភិវឌ្ឍយ៉ាងខ្លាំង បន្ទាប់ពីកម្ពុជាបានទទួលសន្តិភាពទូទាំងប្រទេស។ នៅឆ្នាំ១៩៩៦ រោងចក្រកាត់ដេរមានចំនួនប្រមាណ៤០ប៉ុណ្ណោះ និងប្រាក់បៀវត្សប្រហែល៣៥ដុល្លារអាមេរិក ដោយពុំមានអត្ថប្រយោជន៍ផ្សេងៗទៀតឡើយ ប៉ុន្តែបច្ចុប្បន្នបានកើនឡើងដល់ប្រមាណ ១ ២០០រោងចក្រ ដោយបានផ្ដល់ការងារនិងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរាប់លាននាក់។ ក្នុងពេលដែលមានកំណើនការងារលើវិស័យកាត់ដេរ ស្ត្រីបានស្រូបយកការងារស្ទើរតែ៩០% ផ្ទុយនឹង២០ឆ្នាំមុន គឺស្ត្រី

ភាគច្រើនធ្វើការងារនៅក្នុងផ្ទះ ហើយសង្គមមិនសូវឱ្យតម្លៃខ្ពស់។ ដោយសារការចូលរួមចំណែករបស់ស្ត្រីយ៉ាងសំខាន់ នៅក្នុងសេដ្ឋកិច្ចគ្រួសារនិងសង្គម ដូច្នេះ យើងកត់សម្គាល់ឃើញថា តួនាទីរបស់ស្ត្រីកាន់តែល្អប្រសើរឡើង ហើយនេះគឺជាការលើកតម្កើងសិទ្ធិសេរីភាពរបស់ស្ត្រីបន្ថែមទៀត តាមរយៈការអភិវឌ្ឍសេដ្ឋកិច្ច ក្រោមការយកចិត្តទុកដាក់បំផុតរបស់រាជរដ្ឋាភិបាល។ ដោយមើលឃើញអំពីសារៈសំខាន់នៃការងាររបស់កម្មករ កម្មការិនី សម្តេចតេជោ **ហ៊ុន សែន** បានចុះជួបសំណេះសំណាលជាមួយកម្មករ កម្មការិនី នៅតាមរោងចក្រ រហូតដល់ពេលនេះ បានចំនួនជិត៤០ម៉ឺននាក់ ដើម្បីស្វែងយល់អំពីសុខទុក្ខ ដោះស្រាយបញ្ហាប្រឈមនិងសំណូមពរនានារបស់កម្មករ កម្មការិនី ពន្យល់អំពីអត្ថប្រយោជន៍ជាប្រាក់បៀវត្សនិងអត្ថប្រយោជន៍ផ្សេងៗក្រៅពីបៀវត្ស សភាពការណ៍នយោបាយ និងទិសដៅនៃការអភិវឌ្ឍប្រទេស ព្រមទាំងលើកទឹកចិត្តឱ្យកម្មករ កម្មការិនី ខិតខំយកចិត្តទុកដាក់បំពេញការងារ។

រាជរដ្ឋាភិបាលបានខិតខំកៀរគរវិនិយោគិន ឱ្យមកបណ្តាក់ទុនលើវិស័យកាត់ដេរ និងកសាងក្របខ័ណ្ឌច្បាប់នានា សម្រាប់គ្រប់គ្រងវិស័យនេះ ហើយក៏ខិតខំធ្វើយ៉ាងណាដើម្បីឱ្យកម្មករ កម្មការិនី ទទួលបាននូវអត្ថប្រយោជន៍ជាបៀវត្សនិងអត្ថប្រយោជន៍មិនមែនជាបៀវត្ស។ ដោយសារការយកចិត្តទុកដាក់នេះ ទើបទាំងក្របខ័ណ្ឌច្បាប់និងអត្ថប្រយោជន៍ផ្សេងៗរបស់កម្មករ កម្មការិនីនៅកម្ពុជា មានលក្ខណៈល្អប្រសើរធៀបទៅនឹងនៅបណ្តាប្រទេសជាច្រើន។ ប្រាក់បៀវត្សអប្បបរមារបស់កម្មការ កម្មការិនីនៅឆ្នាំនេះ មានចំនួន១៧០ដុល្លារអាមេរិក ដែលមានចំណាត់ថ្នាក់លេខ៥ ធៀបនឹងប្រាក់បៀវត្សរបស់កម្មករ កម្មការិនី នៅប្រទេសចំនួន១៣ ក្នុងតំបន់អាស៊ី។ តួលេខនេះបញ្ជាក់យ៉ាងច្បាស់ អំពីជោគជ័យរបស់រាជរដ្ឋាភិបាលក្នុងការ

អភិវឌ្ឍសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទូទៅ។ កម្មករ កម្មការិនី ក៏បានទទួលអត្ថប្រយោជន៍មិនមែនជាបៀវត្សផ្សេងៗ កាន់តែល្អប្រសើរ ដូចជា (១) គោលនយោបាយសុវត្ថិភាពការងារដែលកម្មករ កម្មការិនីទទួលបានជាប្រាក់សំណង អាស្រ័យលើស្ថានភាពគ្រោះថ្នាក់ដែលកើតមានជាយថាហេតុ (២) ប្រាក់ឧបត្ថម្ភ១២០%នៃប្រាក់បៀវត្សសម្រាប់លំហែមាតុភាពរយៈពេល៣ខែ បន្ថែមលើប្រាក់១០០ដុល្លារអាមេរិក សម្រាប់ការសម្រាលកូនម្នាក់ (៣) ការធានារ៉ាប់រងសុខភាព ដោយម្ចាស់រោងចក្រជាអ្នកបង់ថ្លៃសេវាសុខភាពទាំងស្រុង ចំណែកបេឡាជាតិសន្តិសុខសង្គមជាអ្នករ៉ាប់រងលើការពិនិត្យព្យាបាល (៤) ការធានារ៉ាប់រងចំណាយលើការធ្វើដំណើរសាធារណៈតាមរថយន្តក្រុង (៥) ការគ្រោងផ្តល់ប្រាក់សោធននិវត្តជូនកម្មករ កម្មការិនីចាប់ពីឆ្នាំ២០១៩ ជាដើម។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានពិចារណាធ្វើយ៉ាងណា ដើម្បីរក្សាវិនិយោគិនដែលបាននិងកំពុងវិនិយោគនៅកម្ពុជា ក៏ដូចជាការទាក់ទាញបន្ថែមទៀត។ ដូច្នេះ រាល់គោលនយោបាយដែលដាក់ចេញត្រូវមានតុល្យភាពរវាងវិនិយោគិន និងកម្មករ កម្មការិនី។

ការអភិវឌ្ឍលើគ្រប់វិស័យ ដែលជាសមិទ្ធផលនៃការខិតខំប្រឹងប្រែងនិងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល បានធ្វើឱ្យសង្គមកម្ពុជាទាំងមូលមានការវិវត្តជាវិជ្ជមាន ស្របតាមនិន្នាការអភិវឌ្ឍន៍ក្នុងតំបន់ ហើយសេដ្ឋកិច្ចកម្ពុជាក៏បាននិងកំពុងធ្វើសមាហរណកម្មប្រកបដោយសក្តានុពល ចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។ វឌ្ឍនភាពនេះបានជះឥទ្ធិពលជាវិជ្ជមានដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ហើយជាកត្តាធំបំផុតក្នុងការរួមចំណែកដល់ការលើកកម្ពស់សិទ្ធិសេរីភាព សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

ការបង្កើតស្ថាប័ន ការកសាងក្របខ័ណ្ឌច្បាប់ ការអនុវត្តច្បាប់ ការធានានូវសន្តិភាពនិងស្ថិរភាពនយោបាយ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម គឺ

ជាមូលដ្ឋានគ្រឹះ ដែលមានអន្តរទំនាក់ទំនងក្នុងការសម្រេចបាននូវគោលដៅនៃការពង្រឹងលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងការកសាងនីតិរដ្ឋ។ ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតមានការយល់ដឹងកាន់តែច្រើន និងទូលំទូលាយជាងមុនអំពីតម្លៃនៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស តាមគោលការណ៍សកលក្នុងបរិបទកម្ពុជា ដែលផ្សារភ្ជាប់ជាមួយនឹងតថភាពជាក់ស្តែង មរតកពីសង្គ្រាមនិងប្រវត្តិសាស្ត្រ តាមរយៈការប្រើប្រាស់សិទ្ធិសេរីភាព ការបញ្ចេញមតិ ការចូលរួមក្នុងសកម្មភាពនយោបាយ និងការចូលរួមបោះឆ្នោត ដើម្បីជ្រើសរើសគណបក្សនយោបាយ និងមេដឹកនាំដែលខ្លួនពេញចិត្ត។ ទោះបីជាកម្ពុជាសម្រេចបានសមិទ្ធផលជាវិជ្ជមានជាច្រើន គួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះក្តី ក៏លទ្ធិប្រជាធិបតេយ្យដ៏ក្មេងខ្ចីត្រូវបន្តដំណើរនៅលើផ្លូវដ៏វែងឆ្ងាយទៀត ដោយត្រូវជំនះឧបសគ្គនិងបញ្ហាប្រឈមជាច្រើន ហើយកម្ពុជានៅតែប្តេជ្ញាចិត្តបោះជំហានទៅមុខ ឆ្ពោះទៅសម្រេចបាននូវសង្គមប្រជាធិបតេយ្យនិងនីតិរដ្ឋ ដែលបម្រើឱ្យឧត្តមប្រយោជន៍ជាតិនិងប្រជាជន។

## ៣. កិច្ចសហប្រតិបត្តិការអន្តរជាតិ និងសមាហរណកម្មក្នុងតំបន់

សម្តេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍ថា «ដំណើរវិវត្តនៃនយោបាយការបរទេសរបស់ប្រទេសកម្ពុជា គឺឈរលើមូលដ្ឋានអព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធ ហើយធ្វើទំនាក់ទំនងជាមួយប្រទេសទាំងអស់ដើម្បីបម្រើគោលដៅរួមគឺការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា។ លើសពីនេះ កម្ពុជាកំពុងតែចរចាជាមួយបណ្តាប្រទេសនានា ដើម្បីចៀសវាងការយកពន្ធត្រួតគ្នា ក្នុងគោលបំណងសម្រួលឱ្យអ្នកវិនិយោគមកកាន់ប្រទេសកម្ពុជា ឬយើងទៅកាន់ប្រទេសគេ»។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងយ៉ាងច្បាស់អំពីគោលការណ៍សម្រាប់តម្រង់ទិសនយោបាយការបរទេសរបស់កម្ពុជា រួមមាន (១) ប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ (២) រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាងនិងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក (៣) មិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍គ្នាទៅវិញទៅមក (៤) មិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ (៥) មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ (៦) រក្សាសិទ្ធិទទួលយកជំនួយបរទេស ជាសម្ភារយោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស។

ក្នុងបរិបទនៃការកើនឡើងនូវភាពតានតឹង និងបាតុភូតដែលមិនអាចទស្សន៍ទាយបានក្នុងតំបន់និងពិភពលោក គោលនយោបាយការបរទេសកម្ពុជា ដែលរួមមាន នយោបាយ វប្បធម៌ សេដ្ឋកិច្ច និងសង្គម បានដើរតួនាទីកាន់តែសំខាន់ ដើម្បីធ្វើសមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក នាពេលបច្ចុប្បន្ននិងអនាគត។

គោលនយោបាយការបរទេសរបស់កម្ពុជា មានមូលដ្ឋានចេញពីភូមិសាស្ត្រនយោបាយ ប្រវត្តិសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ច។ ជាទ្រឹស្តីសកល គោលនយោបាយការបរទេស ត្រូវបានកំណត់ដោយនយោបាយក្នុងស្រុក

ការផ្លាស់ប្តូរជំនាន់អ្នកដឹកនាំ និងបាតុភូតខាងក្រៅប្រទេស។ កម្ពុជាជារដ្ឋតូចមួយ ត្រូវតែមានយុទ្ធសាស្ត្ររស់រាន និងរីកចម្រើនក្នុងប្រព័ន្ធសន្តិសុខ និងសេដ្ឋកិច្ចពិភពលោកដ៏ស្មុគស្មាញ ដែលមិនអាចទាយទុកជាមុនបាន។ ដូច្នេះ សន្តិភាព ឯករាជ្យភាព និងអព្យាក្រឹតភាព គឺជាបុរេលក្ខខណ្ឌនៃសុខដុមនីយកម្ម ការរួមរស់ដោយសន្តិសហវិជ្ជមាន និងការកសាងចក្ខុវិស័យសម្រាប់ពេលអនាគត។

ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រ បានក្លាយជាគោលដៅស្នូលនៃគោលនយោបាយការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ក្នុងន័យនេះ កម្ពុជាបានផ្តោតលើការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសអាស៊ាន និងយន្តការសហប្រតិបត្តិការដទៃទៀត ដែលមានតួនាទីអាស៊ានជាស្នូល និងដៃគូសន្ទនាសំខាន់ៗ ព្រមទាំងស្ថាប័នអន្តរជាតិនានាផងដែរ។ ក្រៅពីនេះ កម្ពុជាក៏បានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយយន្តការថ្មីៗ ដូចជា គំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង (Mekong-Lancang Cooperation) រួមទាំងយន្តការសហប្រតិបត្តិការអនុតំបន់ផ្សេងទៀត។

នៅឆ្នាំ២០១៨ កម្ពុជាបានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី២ ដោយមានការចូលរួមពីថ្នាក់ដឹកនាំកំពូលមកពីប្រទេសនៃតំបន់ទន្លេមេគង្គ រួមមានឯកឧត្តម **ថងលូន ស៊ីស៊ូលីត** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ឯកឧត្តម **មិន ស្វេ** អនុប្រធានាធិបតីនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ឯកឧត្តមនាយឧត្តមសេនីយ៍ **ប្រាយុទ្ធ ច័ន្ទអូចា** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ និងឯកឧត្តម **ង្វៀន សួនហ៊្វុក** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងឯកឧត្តម **លី ខឺឈាង** នាយករដ្ឋមន្ត្រីនៃសាធារណ

រដ្ឋប្រជាមានិតចិន។ ក្នុងនាមជាសហប្រធាន សម្ដេចតេជោ **ហ៊ុន សែន** និងឯកឧត្តម **លី ខឺឈាង** បានដឹកនាំកិច្ចប្រជុំប្រកបដោយជោគជ័យ ជាប្រវត្តិសាស្ត្រ ក្រោមប្រធានបទ «ទន្លេរបស់យើងដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព»។ ជាលទ្ធផល ប្រទេសនៅតំបន់ទន្លេមេគង្គបានផ្ដល់សារៈសំខាន់ដល់យន្តការនៃការកសាងមូលដ្ឋានគ្រឹះ ឆ្ពោះទៅកាន់ដំណាក់កាលរីកលូតលាស់ ក្នុងភាពជាដៃគូនិងសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ។

ការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន គឺក្នុងគោលបំណងដើម្បីធ្វើសមាហរណកម្មសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាសមាជិក ឱ្យក្លាយទៅជាសហគមន៍រួម ដូចជាទីផ្សាររួម មូលដ្ឋានផលិតកម្មស្តង់ដាតែមួយ និងរបបពន្ធគយរួម ជាដើម ដើម្បីប្រែក្លាយតំបន់នេះ ជាតំបន់សេដ្ឋកិច្ចមួយប្រកបដោយភាពប្រកួតប្រជែង ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ និងសមាហរណកម្មទៅក្នុងប្រព័ន្ធសេដ្ឋកិច្ចពិភពលោក។ កត្តាទាំងនេះនឹងជួយលើកស្ទួយដល់សេដ្ឋកិច្ចក្នុងតំបន់អាស៊ាន ក៏ដូចជាទាក់ទាញដៃគូសេដ្ឋកិច្ចក្រៅតំបន់ចូលមកវិនិយោគ។

គោលនយោបាយការបរទេសដ៏ត្រឹមត្រូវរបស់កម្ពុជា បាននាំមកនូវសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍយូរអង្វែង។ នាពេលអនាគត ការអភិវឌ្ឍប្រកបដោយចីរភាព ពុំត្រឹមតែពឹងផ្អែកលើការកសាងសេដ្ឋកិច្ចដែលឈរលើមូលដ្ឋានកម្លាំងពលកម្មជំនាញ នវានុវត្តន៍ បច្ចេកវិទ្យាសហគ្រិនភាព និងអភិបាលកិច្ចល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវពឹងផ្អែកលើការដាក់ចេញនូវគោលនយោបាយការបរទេសដ៏ត្រឹមត្រូវ ជាបន្តទៀតផងដែរ។

## ៤ .បដិវត្តន៍ពណ៌

### ៤.១. ការកកើតបដិវត្តន៍ពណ៌នៅក្នុងប្រទេសមួយចំនួន

**បដិវត្តន៍**គឺជាចលនាតស៊ូដណ្ដើមអំណាច ដើម្បីធ្វើការផ្លាស់ប្ដូររបបដឹកនាំ តាមរយៈសង្គ្រាមប្រដាប់អាវុធ ដើម្បីផ្ដួលរំលំរបបមួយ ដែលមនុស្សមួយក្រុមមិនពេញចិត្ត ឬមានមហិច្ឆតាក្នុងការដឹកនាំកិច្ចការរដ្ឋ។ បដិវត្តន៍តាមរូបភាពប្រដាប់អាវុធ គឺជាចលនាដ៏ពេញនិយមនៅក្នុងសម័យសង្គ្រាមត្រជាក់។ **បដិវត្តន៍ពណ៌** គឺជាចលនាបះបោរដោយមហាជន តាមរយៈបាតុកម្មអហិង្សា ឬកូដកម្ម ហើយប្រែក្លាយទៅជាកុបកម្មបន្តិចម្ដងៗ ដែលមានការជួយរៀបចំ និងផ្ដល់មធ្យោបាយហិរញ្ញវត្ថុ តាមរូបភាពផ្សេងៗ ពីប្រទេសមហាអំណាចនិងសម្ព័ន្ធមិត្ត ក្រោមលេសពង្រឹងលទ្ធិប្រជាធិបតេយ្យនិងការពារសិទ្ធិមនុស្ស ក្នុងគោលដៅផ្ដួលរំលំមេដឹកនាំប្រទេសណាមួយ ដែលមិនព្រមបម្រើឱ្យនយោបាយ ឬផលប្រយោជន៍ជាយុទ្ធសាស្ត្ររបស់ប្រទេសមហាអំណាចនោះ ទោះបីជាប្រទេសគោលដៅនោះមានលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ឬពុំមានក៏ដោយ។ បដិវត្តន៍ពណ៌គឺជាទម្រង់ថ្មីនៃរដ្ឋប្រហារ ដែលប្រើប្រាស់កម្លាំងមហាជន ជាឧបករណ៍ក្នុងការផ្ដួលរំលំរដ្ឋអំណាចស្របច្បាប់ ផ្ទុយនឹងគោលការណ៍លទ្ធិប្រជាធិបតេយ្យ ច្បាប់ និងស្មារតីនៃរដ្ឋធម្មនុញ្ញ។ នៅប្រទេសមួយចំនួន បដិវត្តន៍ពណ៌ផ្ដួលរំលំរដ្ឋអំណាចស្របច្បាប់បានទទួលបរាជ័យ ហើយសង្គ្រាមមិនបានកើតឡើងទេ។ ផ្ទុយទៅវិញ នៅប្រទេសផ្សេងទៀតជាច្រើន ដូចជា នៅអ៊ុយក្រែន លីប៊ី ស៊ីរី អេហ្ស៊ីប ទុយណេស៊ី យេម៉ែន និងហ្សកហ្ស៊ី ជាដើម ទោះបីជាជោគជ័យឬបរាជ័យក្ដី បដិវត្តន៍ពណ៌បាននាំមកនូវអស្ថិរភាពនយោបាយ ការបង្ហូរឈាម ការបែកបាក់ផ្ទៃក្នុង សង្គ្រាម ការបំបែករដ្ឋ ក្រុមផ្ដាច់ខ្លួន ឬក្រុមភេរវករផ្សេងៗ។




*រូបភាពទី២៖ ទិដ្ឋភាពប្រទេសលីប៊ីនៅមុនពេលនិងក្រោយពេលបដិវត្តន៍ពណ៌*

បដិវត្តន៍ពណ៌ បានកើតមានឡើងតាមរូបភាពនិងមានឈ្មោះផ្សេងៗគ្នា ដូចជា បដិវត្តន៍ប៊ុលដូហ្ស័រនៅយូហ្គោស្លាវី បដិវត្តន៍ផ្កាកុលាបនៅហ្សកហ្ស៊ី បដិវត្តន៍ពណ៌ទឹកក្រូចនៅអ៊ុយក្រែន បដិវត្តន៍ផ្កាម្លិះនៅទុយណេស៊ី បដិវត្តន៍ដើមឈើ Cedar នៅលីបង់ បដិវត្តន៍ផ្កាទុយលីបនៅគៀហ្គីគីស្តង់ បដិវត្តន៍ពណ៌ខៀវនៅគុយវ៉ែត បដិវត្តន៍ពណ៌ស្វាយនៅអ៊ីរ៉ាក់ បដិវត្តន៍ពណ៌បៃតងនៅអ៊ីរ៉ង់ បដិវត្តន៍ផ្កាឈូកនៅអេហ្ស៊ីប និងបដិវត្តន៍ពណ៌នៅលីប៊ី ហុងកុង យេម៉ែន ស៊ីរី បារ៉ែន ម៉ារ៉ុក អាល់ហ្សេរី ។ល។



*រូបភាពទី៣៖ បដិវត្តន៍ពណ៌ទឹកក្រូចនៅអ៊ុយក្រែន*

បដិវត្តន៍ពណ៌នៅយូហ្គោស្លាវី មានអង្គការចាត់តាំងច្បាស់លាស់ ដែលជាចលនាយុវជនហៅថា OTPOR។ បន្ទាប់ពីបានទទួលជោគជ័យនៅយូហ្គោស្លាវីរួចមក ចលនានេះក៏បានរាលដាលដល់ប្រទេសហ្សកហ្ស៊ី ហើយមេដឹកនាំបាតុករនៅយូហ្គោស្លាវី បានអញ្ជើញក្រុមមេដឹកនាំបាតុករនៅហ្សកហ្ស៊ីទៅបណ្តុះបណ្តាលអំពីវិធីសាស្ត្រធ្វើបដិវត្តន៍ពណ៌ និងជាញឹកញាប់ បានទៅជួយរៀបចំចលនានេះនៅហ្សកហ្ស៊ី។ ដូចគ្នានេះដែរ បដិវត្តន៍ពណ៌នៅអ៊ុយក្រែនត្រូវបានរៀបចំនិងជួយជ្រោមជ្រែងពីមេបាតុករនៃយូហ្គោស្លាវី និងហ្សកហ្ស៊ី និងមានការពាក់ព័ន្ធយ៉ាងជ្រៅជាមួយប្រទេសមហាអំណាច។



*រូបភាពទី៤៖ បដិវត្តន៍ប៊ុលដូហ្សើរនៅស៊ែប៊ី*

បដិវត្តន៍ពណ៌ត្រូវបានរៀបចំឡើងទៅតាមលំនាំស្រដៀងគ្នា ដោយមានការជួយបណ្តុះបណ្តាលបច្ចេកទេស រៀបចំផែនការយុទ្ធសាស្ត្រ និងផ្តល់មធ្យោបាយហិរញ្ញវត្ថុពីប្រទេសមហាអំណាចនិងសម្ព័ន្ធមិត្ត។ តាមប្រភពបណ្ឌិត្យសភាការពារជាតិនៃប្រទេស Latvia បានឱ្យដឹងថា មហាអំណាចបស្ចិមប្រទេសបានចំណាយថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់ ដើម្បីផ្តួលរំលំរដ្ឋាភិបាលប្រទេសយូហ្គោស្លាវី ហ្សកហ្ស៊ី និងអ៊ុយក្រែន។



*រូបភាពទី៥៖ លោក John McCain ដើរជាមួយក្រុមបាតុករនៅអ៊ុយក្រែន*

នៅប្រទេសអ៊ុយក្រែន លោក John McCain សមាជិកព្រឹទ្ធសភាអាមេរិក បានចូលរួមនៅក្នុងបាតុកម្ម ដើម្បីជំរុញលើកទឹកចិត្តបាតុករឱ្យផ្ដួលរំលំមេដឹកនាំប្រទេសនេះ ដែលលោកបានហៅថា«**ជាបាតុកម្មអហិង្សាដើម្បីផ្លាស់ប្ដូរ**»។ ប៉ុន្តែ ជាបណ្ដើរៗ បាតុកម្មនេះបានឈានដល់អំពើហិង្សាដែលបង្កការខូចខាតទ្រព្យសម្បត្តិរដ្ឋនិងឯកជន និងការបាត់បង់អាយុជីវិតមនុស្សជាច្រើន ហើយរដ្ឋាភិបាលស្របច្បាប់ត្រូវបានផ្ដួលរំលំ។ ជាលទ្ធផល ប្រទេសនេះត្រូវបានបែកបាក់ បំបែកជាតំបន់អបគមន៍ បាត់បង់ទឹកដី និងកើតមានសង្គ្រាមស៊ីវិលបង្ហូរឈាម ដែលធ្វើឱ្យបាត់បង់អាយុជីវិតមនុស្សរាប់ម៉ឺននាក់។ **តើ John McCain មានចំណែកទទួលខុសត្រូវចំពោះការខូចខាត និងបាត់បង់ទាំងនេះដែរឬទេ?** លោក John McCain ក៏បានទៅប្រទេសទុយណេស៊ី ហើយបានចូលរួមជាមួយបាតុករ ដែលកំពុងតែដើរធ្វើបាតុកម្មតាមដងវិថី។

បច្ចុប្បន្ន ប្រទេសនេះមានអស្ថិរភាពនយោបាយនិងជម្លោះប្រដាប់អាវុធ ដែលជាលទ្ធផលនៃបដិវត្តន៍ពណ៌។

របាយការណ៍បានបង្ហាញថា ទីបញ្ជាការរៀបចំផែនការបដិវត្តន៍ពណ៌ គឺចេញពីស្ថានទូតបរទេស និងបណ្តាញចារកម្មនៅក្នុងប្រទេសគោលដៅ ដោយមានអង្គការមិនមែនរដ្ឋាភិបាលនានា ជាតួអង្គសម្របសម្រួលអនុវត្តគម្រោងការបដិវត្តន៍ពណ៌។ បេសកកម្មសំខាន់បំផុតរបស់តួអង្គខាងលើទាំងនេះ គឺដើម្បីបញ្ជ្រាបមនោគមវិជ្ជា និងពង្រីកឥទ្ធិពលនយោបាយរបស់មហាអំណាចបស្ចិមប្រទេសនិងសម្ព័ន្ធមិត្ត។ សកម្មភាពរបស់អង្គការពាក់ព័ន្ធ គឺធ្វើយ៉ាងណាជំរុញឱ្យចលនាបដិវត្តន៍ពណ៌មានលក្ខណៈ ដូចជាបាតុភូតសង្គមនិងជាឆន្ទៈពិតរបស់ប្រជាពលរដ្ឋ ក្នុងគោលដៅលើកទឹកចិត្តឱ្យមហាជនហ៊ានចេញមុខតវ៉ា ដោយមោះមុតនិងគ្មានការភ័យខ្លាចប្រឆាំងនឹងរបបគ្រប់គ្រងឬមេដឹកនាំប្រទេស។ អង្គការមិនមែនរដ្ឋាភិបាលនិងសង្គមស៊ីវិល ជាអ្នកសហការជាមួយសកម្មជន និងមេដឹកនាំគណបក្សប្រឆាំង អនុវត្តគម្រោងការបដិវត្តន៍ពណ៌ ដោយកៀរគរកម្លាំងមហាជន ដើម្បីធ្វើការទាមទារ តវ៉ា ដង្ហែរក្បួនបាតុកម្ម និងបង្កើតនូវព្រឹត្តការណ៍ផ្សេងៗ ក្នុងគោលដៅបន្ទាបអំណាចរបស់រដ្ឋ ឬបន្ទាបតម្លៃថ្នាក់ដឹកនាំ តាមរយៈការជៀលត្មេះ ការចោទអំពីការប្រព្រឹត្តអំពើពុករលួយ អយុត្តិធម៌សង្គម ការបំផ្លិចបំផ្លាញធនធានធម្មជាតិ ឬការដឹកនាំតាមបែបផ្តាច់ការ ជាដើម។

អង្គការឈ្មោះ OTPOR ដែលមានន័យថា «ចលនាតស៊ូ» គឺជាអង្គការយុវជនដំបូង នៃចលនាបដិវត្តន៍ពណ៌បានជោគជ័យនៅប្រទេសយូហ្គោស្លាវី ហើយបានក្លាយជាតួអង្គគំរូសម្រាប់ប្រទេសផ្សេងៗ។ **នៅឆ្នាំ២០០៤ មេដឹកនាំអង្គការនេះ បានបង្កើតមជ្ឈមណ្ឌលដឹកនាំប្រតិបត្តិការបដិវត្តន៍ពណ៌ (Centre for Applied Nonviolent Action and Strategies – CANVAS) ដើម្បី**

**ផ្សព្វផ្សាយគំរូបដិវត្តន៍ពណ៌នៅប្រទេសស៊ែប៊ី ចេញទៅកាន់ពិភពលោក។** អ្នកជំនាញការរបស់ CANVAS បានជួយបណ្តុះបណ្តាលសកម្មជនជាយុវជនរបស់គណបក្សប្រឆាំងនៅក្នុងប្រទេសជាង៤០ ដែលមានរបបគ្រប់គ្រងផ្សេងៗគ្នា ដោយបានទទួលថវិកាពីមហាអំណាចបស្ចិមប្រទេសនិងសម្ព័ន្ធមិត្ត។

វិធីសាស្ត្រនៃការបណ្តុះបណ្តាលរបស់ CANVAS គឺរបៀបធ្វើបាតុកម្មតាមរយៈការបញ្ឆេះកំហឹងមហាជន ប្រឆាំងនឹងរបបគ្រប់គ្រងឬមេដឹកនាំប្រទេសដែលជាទូទៅត្រូវការប្រើពេលវេលាយូរ និងការបណ្តុះគ្រាប់ពូជបដិវត្តន៍ពណ៌ទុកជាមុន ដើម្បីមានសមត្ថភាពកៀរគរនិងប្រមូលផ្តុំមហាជន ធ្វើការតវ៉ានៅពេលវេលាចាំបាច់ណាមួយ។ ការតវ៉ាទាមទារក្រោមលេស «អហិង្សា» គឺជាឧបាយកលដ៏មានប្រសិទ្ធភាព ក្នុងការធានាឱ្យបដិវត្តន៍ពណ៌ភាគច្រើនបានទទួលជោគជ័យ ពីព្រោះថា (១) ការតវ៉ា ទាមទារតែងតែទទួលបានសមានចិត្តអាណិតអាសូរ និងការចូលរួមច្រើនកុះករពីមហាជន (២) នឹងធ្វើឱ្យបាត់បង់ជំនឿទុកចិត្ត និងធម្មានុរូបភាពរបស់រដ្ឋាភិបាល ប្រសិនបើមានការបង្ក្រាបដោយប្រើអំពើហិង្សា ឬមានការបាត់បង់អាយុជីវិតមនុស្ស និង(៣) អាចយកឈ្នះទឹកចិត្ត និងជំរុញឱ្យកងកម្លាំងប្រដាប់អាវុធ និងសមត្ថកិច្ចងាកទៅគាំទ្រហ្វូងបាតុករ ឬមានជំហរអព្យាក្រឹតវិញ នៅពេលដែលក្រុមបាតុករប្រើសម្តីផ្អែមល្ហែម យកផ្កាឈូក ទឹក ឬម្ហូបអាហារ ទៅឱ្យកម្លាំងសមត្ថកិច្ច។ ប៉ុន្តែលេសអហិង្សានេះ គឺគ្រាន់តែជាការបំភ័ន្ត ឬបិទបាំងនូវគោលបំណងពិតនៃគម្រោងការធ្វើបដិវត្តន៍ពណ៌តែប៉ុណ្ណោះ ពីព្រោះបុព្វហេតុពិតនៅពីក្រោយគឺដើម្បីប្រមូលផ្តុំកម្លាំងមហាជននិងកងកម្លាំងប្រដាប់អាវុធ ឱ្យចូលរួមធ្វើបាតុកម្មទាមទារតវ៉ា ឬបណ្តេញមេដឹកនាំចេញពីតំណែង សំដៅសម្រេចបំណងចុងក្រោយ គឺការដណ្តើមអំណាច។ **ដូច្នេះ បដិវត្តន៍ពណ៌មិនមែនជាការសម្តែងឆន្ទៈពិតរបស់ប្រជាពលរដ្ឋ ឬមហាជននោះទេ ប៉ុន្តែជាការរៀបចំ**

**គម្រោងសម្ងាត់គិតទុកជាមុន ឆ្ពោះទៅដណ្តើមអំណាចដោយមនុស្សមួយក្រុមតែប៉ុណ្ណោះ ផ្ទុយនឹងគោលការណ៍លទ្ធិប្រជាធិបតេយ្យ គឺការបោះឆ្នោត។**

ឧបករណ៍ឃោសនាដ៏មានប្រសិទ្ធភាព គឺបណ្តាញសារព័ត៌មានល្បីៗរបស់លោកខាងលិច និងបណ្តាញទំនាក់ទំនងសង្គម ដែលបានដើរតួនាទីស្នូលក្នុងការចែកចាយព័ត៌មានដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ដែលភាគច្រើនលើសលប់ គឺជាព័ត៌មានប្រឌិតបំផ្លើស បញ្ឆេះកំហឹង បង្កើនការស្អប់ ឬប្រឆាំងនឹងរដ្ឋអំណាច ជាដើម។

បដិវត្តន៍ពណ៌នៅមជ្ឈិមបូព៌ា អាហ្វ្រិកខាងជើង អឺរ៉ុបខាងកើត អាស៊ី និងតំបន់ដទៃទៀត បានបង្កភាពអន្តរាយ ដែលមិនអាចគណនាបាន ដូចជាវិបត្តិនយោបាយ អស្ថិរភាពសង្គម សង្គ្រាមស៊ីវិល ការតស៊ូប្រដាប់អាវុធ ភេរវកម្ម វិបត្តិជនភៀសខ្លួននិងជនភៀសសឹក ឱនភាពសេដ្ឋកិច្ច ការបាត់បង់ធនធានមនុស្ស ការបាត់បង់ឱកាសអភិវឌ្ឍន៍ និងការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ជាដើម។ **បដិវត្តន៍ពណ៌គឺជាឧបករណ៍នយោបាយថ្មី និងជាយុទ្ធសាស្ត្រឈ្លានពាន ដោយមិនប្រើកម្លាំងយោធា ក្រោមលេសនៃលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស ដើម្បីជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃ ពីសំណាក់ប្រទេសមហាអំណាចនិងសម្ព័ន្ធមិត្ត ដែលរដ្ឋាភិបាលឬមេដឹកនាំប្រទេសនោះ មិនព្រមបម្រើផលប្រយោជន៍របស់ប្រទេសមហាអំណាចនិងសម្ព័ន្ធមិត្ត។**

## ៤.២. ចលនាបដិវត្តន៍ពណ៌នៅកម្ពុជា

បដិវត្តន៍ពណ៌កើតឡើងក្រោមរូបភាព និងទម្រង់ផ្សេងៗគ្នានៅតាមប្រទេសនានា។ ដោយឡែកនៅកម្ពុជា បដិវត្តន៍ពណ៌បានកើតឡើងពាក់ព័ន្ធនឹងដំណើរការនៃការបោះឆ្នោត។ ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ បរិយាកាសនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក៏ដូចជាការបោះឆ្នោតឃុំ សង្កាត់

បានប្រព្រឹត្តទៅដោយរលូន សេរី និងគ្មានអំពើហិង្សា។ ជោគជ័យនេះបានបង្ហាញឱ្យឃើញពីការវិវត្តជាវិជ្ជមាននៃការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស នៅកម្ពុជា។ ប្រជាពលរដ្ឋមានសិទ្ធិពេញលេញក្នុងការសម្តែងឆន្ទៈរបស់ខ្លួនដោយសេរី នៅគ្រប់ដំណាក់កាលនៃដំណើរការបោះឆ្នោត ហើយបានចូលរួមក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ដើម្បីសម្តែងការគាំទ្រចំពោះគណបក្សនយោបាយដែលខ្លួនពេញចិត្ត ដោយពុំមានការគំរាមកំហែង និងការភ័យខ្លាច។




*រូបភាពទី៦៖ យុទ្ធនាការឃោសនាបោះឆ្នោតនាពេលកន្លងទៅ*
*(ប្រភព៖ កាសែតភ្នំពេញប៉ុស្តិ៍)*

សកម្មជនគណបក្សនយោបាយនីមួយៗ បានធ្វើសកម្មភាពនយោបាយដោយសេរី គ្មានការគាបសង្កត់ ឬការគំរាមកំហែង ពីមជ្ឈដ្ឋានណាមួយឡើយ។ ទាំងមុននិងក្រោយយុទ្ធនាការបោះឆ្នោត ពុំមានអំពើហិង្សា ដែលប៉ះពាល់ដល់ដំណើរការបោះឆ្នោត ហើយក៏ពុំមានរបាយការណ៍អំពីការរំលោភបំពាន ឬការធ្វើឃាតពាក់ព័ន្ធនឹងនយោបាយ ចំពោះសមាជិកគណបក្សនយោបាយណាមួយឡើយ។

### ៤.២.១. គម្រោងការបដិសេធលទ្ធផលបោះឆ្នោត

បើទោះបីជាលទ្ធផលនៃការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១២ ត្រូវបានគណបក្សទាំងអស់ទទួលយក ក៏ដោយ ក៏គណបក្សសង្គ្រោះជាតិបានរៀបចំគម្រោងផែនការជាបន្តបន្ទាប់ ដើម្បីបង្កើតលេសឈានទៅបដិសេធលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ ដូចខាងក្រោម៖

- ក្រោយការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១២ គណបក្ស សម រង្ស៊ី (បច្ចុប្បន្ន គណបក្សភ្លើងទៀន) និងគណបក្សសិទ្ធិមនុស្ស ដឹងយ៉ាងច្បាស់ថាខ្លួនមិនអាចដណ្ដើមយកជ័យជំនះលើគណបក្សប្រជាជនកម្ពុជា នៅលើសមរភូមិបោះឆ្នោតឆ្នាំ២០១៣បានទេ ដូច្នេះ ថ្នាក់ដឹកនាំនៃគណបក្សទាំងពីរត្រូវបង្ខំចិត្តបង្កើតជាគណបក្សតែមួយ គឺគណបក្សសង្គ្រោះជាតិ ដោយមានការចូលរួមជួយរៀបចំពីអង្គការមិនមែនរដ្ឋាភិបាល ក្រោមការជួយជ្រោមជ្រែង និងឧបត្ថម្ភពីបរទេស។ នៅក្នុងការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១២ គណបក្សប្រជាជនកម្ពុជាទទួលបាន៣ ៦៣១ ០៨២សំឡេង ចំណែកគណបក្ស សម រង្ស៊ី ទទួលបាន១ ២២៤ ៤60សំឡេង ហើយគណបក្សសិទ្ធិមនុស្សទទួលបាន៥៨០ ៤៨៣សំឡេង ជាសរុប គណបក្សទាំងពីរទទួលបាន ១ ៨០៤ ៩៤៣សំឡេង។ ទោះបីជាគណបក្សទាំងពីរទទួលបានសំឡេងតិចជាងគណបក្សប្រជាជនកម្ពុជាក៏ដោយ ក៏ពុំឃើញមានការតវ៉ាណាមួយគួរឱ្យកត់សម្គាល់ ប្រឆាំងនឹងលទ្ធផលនៃការបោះឆ្នោតនេះទេ ហើយគណបក្សទាំងអស់ក៏បានព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនេះ។

- គណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស បានបដិសេធមិនចូលរួម ក្នុងដំណើរការនៃការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០១៣ ដែលមានបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០១២ ជាមូលដ្ឋាន។ តួអង្គមួយចំនួនពាក់ព័ន្ធក្នុងដំណើរការបោះឆ្នោត បានវាយតម្លៃថា បញ្ជីឈ្មោះអ្នក

បោះឆ្នោតឆ្នាំ២០១២នេះ មានលក្ខណៈល្អប្រសើរជាងបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០០៨កន្លងទៅ។ គ.ជ.ប. បានទុកពេល៤ខែឱ្យគណបក្សនយោបាយទាំងអស់ រួមទាំងគណបក្សទាំងពីរនេះផងដែរ ធ្វើការប្ដឹងតវ៉ាឬប្ដឹងជំទាស់នានាពាក់ព័ន្ធនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោត។ ការមិនចូលរួមក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត គឺជាចេតនាបង្កើតលេសគ្រោងទុកជាមុនដើម្បីចោទ គ.ជ.ប. ថាបញ្ជីឈ្មោះអ្នកបោះឆ្នោតនេះមិនត្រឹមត្រូវ ដោយសារខ្លួនពុំបានចូលរួម។

- ក្រោយការប្រកាសជាផ្លូវការ នៃបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០១៣មក វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (National Democratic Institute - NDI) បានប្រឌិតតួលេខថា គ.ជ.ប. បានលុបឈ្មោះអ្នកគាំទ្រគណបក្សសង្គ្រោះជាតិចំនួន១,០៤លាននាក់ ហើយ COMFREL ក៏បានប្រឌិតតួលេខប្រហែលគ្នានេះដែរ គឺ១,២៥លាននាក់។ នេះគឺជាការត្រូវរ៉ូវគ្នាជាខ្សែចង្វាក់រវាងគណបក្សសង្គ្រោះជាតិ វិទ្យាស្ថាន NDI និង COMFREL ដើម្បីទម្លាក់កំហុសលើ គ.ជ.ប. ថាបានលួចលុបឈ្មោះអ្នកគាំទ្រខ្លួន ក្នុងបំណងបដិសេធលទ្ធផលនៃការបោះឆ្នោត នៅពេលគណបក្សប្រឆាំងចាញ់។ នៅឆ្នាំ២០០៨ វិទ្យាស្ថាន NDI បានចោទថា មានប្រជាពលរដ្ឋចំនួន៨៨នាក់បានបាត់ឈ្មោះពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ប៉ុន្តែ គ.ជ.ប. បានរកឃើញថា ក្នុងចំណោមមនុស្ស៨៨នាក់នោះ១៥នាក់មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ១៩នាក់មានឈ្មោះស្ទួនក្នុងការិយាល័យបោះឆ្នោតតែមួយ ៧នាក់ចុះឈ្មោះពីរដង ៩នាក់មានឈ្មោះពីរផ្សេងគ្នា ៣១នាក់ផ្លាស់ទីលំនៅចេញពីឃុំ ២នាក់បាត់បង់សិទ្ធិបោះឆ្នោត ២នាក់ស្លាប់ ២នាក់ពុំមានអាសយដ្ឋាន និង១នាក់ទៀតពុំបានចុះឈ្មោះ។ តួលេខនេះបញ្ជាក់ឱ្យឃើញថា ការចោទប្រកាន់របស់វិទ្យាស្ថាន NDI អំពីរឿងអ្នកបាត់ឈ្មោះទាំង៨៨នាក់ គឺមានចរិតមួលបង្កាច់ និងប្រឌិតរឿង។

នៅឆ្នាំ២០១៣ វិទ្យាស្ថាន NDI បានបដិសេធផ្តល់បញ្ជីឈ្មោះអ្នកបោះឆ្នោតដែលខ្លួនអះអាងថា បាត់ឈ្មោះចំនួន១,០៤លាននាក់ពីបញ្ជីបោះឆ្នោត ក្រោមហេតុផលថាដើម្បីរក្សាការសម្ងាត់ ហើយ COMFREL ក៏បានបដិសេធផ្តល់បញ្ជីឈ្មោះ១,២៥លាននាក់ដែរ។ ទង្វើខាងលើនេះ បង្ហាញឱ្យឃើញយ៉ាងច្បាស់ អំពីពុតត្បុតគិតទុកជាមុនរបស់អង្គការទាំងពីរនេះ និងគណបក្សសង្គ្រោះជាតិ។

- កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១១ ថ្លែងក្នុងកិច្ចប្រជុំតាមវីដេអូពីប្រទេសទុយណេស៊ី ទៅកាន់អ្នកគាំទ្រខ្លួន សម រង្ស៊ី បានលើកពីគោលបំណងផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ ដោយអនុវត្តការផ្លាស់ប្តូរដូចនៅទុយណេស៊ី។ សម រង្ស៊ី បានលើកឡើងពីក្តីសង្ឃឹមថា «កម្ពុជានឹងឃើញការផ្លាស់ប្តូរដូចទុយណេស៊ី ពីព្រោះចលនានេះកំពុងបន្តនៅក្នុងប្រទេសលីប៊ី យេម៉ែន និងស៊ីរី ហើយមិនយូរទេ នឹងឈានដល់កម្ពុជា»។ សម រង្ស៊ី ចង់ឱ្យស្ថានការណ៍នៅកម្ពុជាមានការផ្លាស់ប្តូរ ដូចនៅបណ្តាប្រទេសដែលបានរៀបរាប់ខាងលើ ហើយបច្ចុប្បន្ន ប្រទេសទុយណេស៊ី និងអេហ្ស៊ីប កំពុងមានភាពវឹកវរ អសន្តិសុខ និងអស្ថិរភាពនយោបាយ ចំណែកលីប៊ី យេម៉ែន និងស៊ីរី កំពុងធ្លាក់ចូលក្នុងភ្នក់ភ្លើងសង្គ្រាមយ៉ាងខ្លោចផ្សាបំផុត។

- ក្នុងដំណើរឆ្ពោះទៅកាន់ការបោះឆ្នោត មេដឹកនាំគណបក្សសង្គ្រោះជាតិ បានអនុវត្តផែនការកៀរគរប្រមូលផ្តុំកម្លាំងប្រជាពលរដ្ឋ ដោយញុះញង់ឱ្យធ្វើការទាមទារតវ៉ាលើបញ្ហាផ្សេងៗមានដូចជា បញ្ហាដីធ្លី សិទ្ធិមនុស្ស បរិស្ថាន និងធនធានធម្មជាតិ ខណៈដែលរាជរដ្ឋាភិបាលបាននិងកំពុងខិតខំដោះស្រាយ។ គណបក្សនេះបានមួលបង្កាច់ និងចោទប្រកាន់លើការដឹកនាំរបស់រាជរដ្ឋាភិបាលលើបញ្ហាផ្សេងៗ ដោយគ្មានមូលដ្ឋាន ក្នុងគោលបំណងបំភ័ន្តមតិជាតិនិងអន្តរជាតិឱ្យយល់ឃើញថា រាជរដ្ឋាភិបាលអសមត្ថភាពក្នុងការដឹកនាំប្រទេស។

- បណ្ដាញផ្សព្វផ្សាយព័ត៌មាន មាននិន្នាការគាំទ្រគណបក្សប្រឆាំង ទាំងក្នុងនិងក្រៅប្រទេស ដូចជាវិទ្យុសំឡេងសហរដ្ឋអាមេរិក (VOA) វិទ្យុអាស៊ីសេរី (RFA) វិទ្យុសំឡេងប្រជាធិបតេយ្យ (VOD) វិទ្យុសំបុកឃ្មុំ ក៏ដូចជាបណ្ដាញផ្សព្វផ្សាយសង្គមផ្សេងៗ ដូចជា Facebook, YouTube និង Twitter បានផ្សព្វផ្សាយដោយសេរី នូវព័ត៌មានបំផ្លើសពាក់ព័ន្ធនឹងនយោបាយនិងសង្គម ដែលមានចរិតប្រឌិតនិងញុះញង់ ដែលគណបក្សសង្គ្រោះជាតិ និងសកម្មជនរបស់ខ្លួនបានរៀបចំឡើង ក្នុងគោលបំណងបំពុលបរិយាកាសសង្គម កេងចំណេញនយោបាយ ឬញុះញង់បំបែកបំបាក់ផ្ទៃក្នុងគណបក្សប្រជាជនកម្ពុជា។ បណ្ដាញព័ត៌មានដែលមាននិន្នាការប្រឆាំងបានផ្គុំគ្នាចងជាបណ្ដាញ និងបានធ្វើសកម្មភាពទាំងមុននិងក្រោយការបោះឆ្នោត ដោយស៊ីសង្វាក់ប្រទាក់ក្រឡាគ្នា ហើយមិនបានគិតដល់សុចរិតភាពវិជ្ជាជីវៈ និងក្រមសីលធម៌អ្នកសារព័ត៌មានទេ ក្នុងគោលបំណងតែមួយគត់ គឺដើម្បីជួយគណបក្សសង្គ្រោះជាតិឱ្យឈ្នះឆ្នោត ឬផ្ដួលរំលំរដ្ឋអំណាចស្របច្បាប់។

- ពីរសប្ដាហ៍មុនថ្ងៃបោះឆ្នោត គណបក្សសង្គ្រោះជាតិបានបញ្ចេញឯកសារក្លែងក្លាយ និងហ៊ានប្រើឈ្មោះវិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិ (IRI) ថាបានធ្វើការស្ទង់មតិដោយទទួលបានលទ្ធផលដែលថា គណបក្សរបស់ខ្លួនបានទទួលសំឡេងឆ្នោតស្មើនឹង៦៤ភាគរយ។ ការបញ្ចេញឯកសារក្លែងក្លាយនេះមានគោលបំណងកេងយកចំណេញផ្នែកចិត្តសាស្ត្រពីមហាជន ដើម្បីឈ្នះឆ្នោត និងត្រៀមលក្ខណៈបដិសេធលទ្ធផលបោះឆ្នោត ដោយយកតួលេខនេះជាធ្វើជាលេសមួយ សំអាងថា មានការលួចបន្លំសន្លឹកឆ្នោត នៅពេលដែលគណបក្សខ្លួនចាញ់ឆ្នោត។ ក្រោយមក វិទ្យាស្ថាន IRI បានបដិសេធថា ឯកសារនេះពុំមែនជាឯកសាររបស់ខ្លួនទេ។

- នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣ សម រង្ស៊ី និង កឹម សុខា បាននិយាយនៅទីលានប្រជាធិបតេយ្យ និងក្នុងកិច្ចសម្ភាសន៍ជាមួយវិទ្យុ RFA ថា គ.ជ.ប. គឺជាអ្នកលួចសន្លឹកឆ្នោត ហើយបានប្រកាសទុកជាមុនថា គណបក្សសង្គ្រោះជាតិនឹងឈ្នះឆ្នោត ហើយមិនទទួលស្គាល់លទ្ធផលបោះឆ្នោត និងប្រកាសប្រមូលផ្តុំកម្លាំងតវ៉ា ប្រសិនបើគណបក្សសង្គ្រោះជាតិបែរជាចាញ់។

- នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៣ នៅខេត្តកំពង់ស្ពឺ សម រង្ស៊ី បាននិយាយថា «ជនរួមជាតិទាំងអស់ នេះជាឱកាសចុងក្រោយហើយ ប្រសិនបើយើងមិនសង្គ្រោះជាតិទេ បួន ឬប្រាំឆ្នាំទៀត គឺយឺតពេលហើយ ដោយសារជនជាតិវៀតណាមនឹងមករស់នៅពេញប្រទេសកម្ពុជា ហើយយើងនឹងក្លាយជាទាសករនៃប្រទេសវៀតណាម»។ **បើគិតមកដល់ពេលនេះ គឺជិត៥ឆ្នាំហើយ តើសម្តីរបស់ សម រង្ស៊ី ពិតដែរឬទេ?**

- មួយថ្ងៃមុនថ្ងៃបោះឆ្នោត ដែលជាថ្ងៃស្ងប់ស្ងាត់ COMFREL បានបញ្ចេញព័ត៌មានបំផ្លើសថា ទឹកខ្មៅសម្រាប់ជ្រលក់ម្រាមដៃសម្គាល់អ្នកបោះឆ្នោតរួច គឺជាទឹកខ្មៅដែលអាចលាងសម្អាតចេញបានក្នុងរយៈពេលតែប៉ុន្មាននាទីប៉ុណ្ណោះ។ នេះជាលើកទីមួយហើយ ដែលបញ្ហាទឹកខ្មៅត្រូវបានលើកឡើងនៅមុនពេលបោះឆ្នោតឆ្នាំ២០១៣។ ការអះអាងនេះត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដោយមានចេតនាធ្វើឱ្យមហាជនយល់ច្រឡំ និងសង្ស័យថាអ្នកបោះឆ្នោតម្នាក់អាចបោះឆ្នោតបានច្រើនដង។ នេះគឺជាការវាយប្រហារផ្នែកចិត្តសាស្ត្រ ដែលជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់អ្នកបោះឆ្នោតឱ្យមានសមានចិត្តនិងងាកមកបោះឆ្នោតឱ្យគណបក្សប្រឆាំងវិញ ឬធ្វើឱ្យមហាជនមានមន្ទិលសង្ស័យ ចំពោះដំណើរការនិងលទ្ធផលនៃការបោះឆ្នោត ពីព្រោះពួកគេអាចជឿថា គណបក្សប្រជាជនប្រើល្បិចបន្លំសន្លឹកឆ្នោត។ កលល្បិចនេះ គឺជាផែនការរៀបចំទុកជាមុន ហើយធ្វើឡើងតែមួយថ្ងៃមុនថ្ងៃ

បោះឆ្នោត ដើម្បីជួយគណបក្សប្រឆាំងឱ្យទទួលបានជ័យជំនះនៅថ្ងៃបោះឆ្នោត ឬអាចទុកប្រើប្រាស់ជាលេស ដើម្បីតវ៉ាប្រឆាំងនឹងលទ្ធផលបោះឆ្នោត នៅពេលចាញ់ឆ្នោត។ តាមពិតទឹកខ្មៅនេះ ត្រូវបានទទួលស្គាល់គុណភាពនិងប្រើប្រាស់សម្រាប់សម្គាល់អ្នកបោះឆ្នោតរួច ដោយប្រទេសជាច្រើន ដូចជា ឥណ្ឌា អាហ្វហ្គានីស្ថាន សិង្ហបុរី ថៃ ម៉ាឡេស៊ី អាហ្វ្រិកខាងត្បូង នីហ្សេរីយ៉ា ជាដើម។

- នៅក្នុងដំណើរការឆ្ពោះទៅកាន់ការបោះឆ្នោត ថ្នាក់ដឹកនាំគណបក្សប្រឆាំងតែងតែប្រើល្បិចកល ដោយលើកឡើងម្តងហើយម្តងទៀតថា ការបោះឆ្នោតនេះមិនមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ហើយខ្លួនបដិសេធចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត និងមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ប៉ុន្តែទីបញ្ចប់ គណបក្សនេះ នៅតែចូលរួមដដែល។ នៅពេលជួបជាមួយអ្នកសង្កេតការណ៍អន្តរជាតិ សម រង្ស៊ី និង កឹម សុខា បានប្រកាសថា មិនទទួលស្គាល់ គ.ជ.ប. ហើយនឹងបដិសេធលទ្ធផលនៃការបោះឆ្នោត ប៉ុន្តែបែរជា បញ្ជាក់ថា គណបក្សសង្គ្រោះជាតិអាចនឹងឈ្នះ។ អ្នកសង្កេតការណ៍អន្តរជាតិ ដែលជាឥស្សរជននយោបាយជាន់ខ្ពស់មួយរូបនៃអង្គការ ICAPP បានសួរ សម រង្ស៊ី ថា «**បើលោកមិនទទួលស្គាល់ គ.ជ.ប. និងលទ្ធផលបោះឆ្នោត តើគណបក្សរបស់លោកចូលរួមបោះឆ្នោតដើម្បីអ្វី? ហើយចុះបើគណបក្សរបស់លោកឈ្នះវិញ តើលោកនៅតែបដិសេធលទ្ធផលបោះឆ្នោតដែរឬទេ?**» ចំពោះសំណួរទាំងនេះ សម រង្ស៊ី និង កឹម សុខា ពុំបានឆ្លើយតបទេ ហើយបែរជាបង្វែរការពិភាក្សាទៅរកប្រធានបទផ្សេងវិញ។ ឥរិយាបថបែបនេះបង្ហាញយ៉ាងច្បាស់ថា គណបក្សសង្គ្រោះជាតិនឹងទទួលយកលទ្ធផលបោះឆ្នោត តែក្នុងករណីដែលគណបក្សខ្លួនឈ្នះប៉ុណ្ណោះ ប៉ុន្តែពិតជានឹងបដិសេធលទ្ធផលបោះឆ្នោត នៅពេលគណបក្សខ្លួនចាញ់។

នៅមានសកម្មភាពជាច្រើនទៀត ដែលគណបក្សប្រឆាំងបានធ្វើយុទ្ធនាការតាមរូបភាពផ្សេងៗ ដើម្បីធ្វើឱ្យមហាជនបាត់បង់ជំនឿទុកចិត្តមកលើរាជរដ្ឋាភិបាល ក្នុងគោលបំណងស្វែងរកជ័យជំនះក្នុងពេលបោះឆ្នោត។ ជាមួយគ្នានេះដែរ គណបក្សសង្គ្រោះជាតិបានប្រើប្រាស់ទឡ្ហីករណ៍ផ្សេងៗ ដើម្បីចោទ គ.ជ.ប. និងគណបក្សប្រជាជនកម្ពុជា មុនពេលបោះឆ្នោត ដើម្បីជាលេសបដិសេធលទ្ធផលនៃការបោះឆ្នោត។

### ៤.២.២. ស្ថានការណ៍នៅថ្ងៃបោះឆ្នោត

**ដំណើរការក្នុងការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត៖** ដោយមានបទពិសោធអស់រយៈពេលជាច្រើនឆ្នាំមក គ.ជ.ប. បានរៀបចំការបោះឆ្នោតដោយរលូននិងប្រកបដោយវិជ្ជាជីវៈខ្ពស់ នៅតាមការិយាល័យបោះឆ្នោត ទោះបីជាមានការរំខាននៅក្រៅការិយាល័យជាច្រើន ពីសំណាក់សកម្មជនគណបក្សប្រឆាំងក៏ដោយ។ ក្រុមប្រឆាំងរិះរកមធ្យោបាយគ្រប់បែបយ៉ាងក្នុងគោលបំណងដើម្បីឱ្យសកម្មជននិងអ្នកគាំទ្រខ្លួន បាត់បង់ជំនឿលើ គ.ជ.ប. ហើយធ្វើឱ្យពួកគេយល់ឃើញថា គណបក្សសង្គ្រោះជាតិចាញ់ គឺដោយសារ គ.ជ.ប. លួចបន្លំសន្លឹកឆ្នោត។

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ តាមនីតិវិធី នៅមុនម៉ោង៧ព្រឹក មន្ត្រីការិយាល័យបោះឆ្នោតរួមទាំង ប្រធានមានចំនួន៦នាក់ ភ្នាក់ងារគណបក្សប្រជាជនកម្ពុជាចំនួន២នាក់ គណបក្សសង្គ្រោះជាតិចំនួន២នាក់។ ចំណែកឯគណបក្សហ៊្វុនស៊ិនប៉ិច គណបក្ស សម រង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សនរោត្តម រណឫទ្ធិ និងអ្នកសង្កេតការណ៍ COMFREL បានប្រមូលផ្តុំគ្នានៅការិយាល័យបោះឆ្នោត។ ដូច្នេះ នៅក្នុងការិយាល័យបោះឆ្នោតនីមួយៗ ភ្នាក់ងារគណបក្សប្រជាជនកម្ពុជាមានចំនួន២នាក់ប៉ុណ្ណោះ ធៀបនឹងភ្នាក់ងារគណបក្សដទៃទៀត ដែលមានគ្នារហូតដល់៥ឬ៦នាក់ ក្នុងនោះមានភ្នាក់ងារ

គណបក្សសង្គ្រោះជាតិមានចំនួន២នាក់ និងភ្នាក់ងារគណបក្សដទៃទៀត ព្រមទាំងអ្នកសង្កេតការណ៍របស់ COMFREL ផងដែរ។

ភ្នាក់ងារគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសង្កេតការណ៍បានធ្វើជាសាក្សី នៅគ្រប់ដំណាក់កាលនៅថ្ងៃបោះឆ្នោត ចាប់តាំងពីការត្រួតពិនិត្យហិបឆ្នោត ការបោះឆ្នោត ការបើកនិងបិទហិបឆ្នោត ការរាប់សន្លឹកឆ្នោត និងការដឹកជញ្ជូនហិបឆ្នោត ទៅកាន់ទីស្នាក់ការគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត និង គ.ជ.ប.។ ភ្នាក់ងារគណបក្សនយោបាយដែលបានចូលរួមទាំងនោះ សុទ្ធតែបានចុះហត្ថលេខាលើទម្រង់បែបបទពាក់ព័ន្ធនឹងការបោះឆ្នោតទាំងអស់ នៅតាមការិយាល័យបោះឆ្នោតនីមួយៗ នៅពេលប្រគល់ ទទួលរបាយការណ៍នៅឃុំ សង្កាត់ រាជធានី ខេត្ត និង គ.ជ.ប.។ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ បានទទួលព័ត៌មានអំពីលទ្ធផលបោះឆ្នោត តាមរយៈទម្រង់បែបបទលេខ១១០៤ ដែលប្រគល់ជូននៅគ្រប់ការិយាល័យបោះឆ្នោតទាំង១៩ ០០៩។ ទោះបីជា ភ្នាក់ងារគណបក្សសង្គ្រោះជាតិ និងអ្នកសង្កេតការណ៍បានចុះហត្ថលេខាលើទម្រង់បែបបទពាក់ព័ន្ធនានា នៅគ្រប់ការិយាល័យបោះឆ្នោត គឃ/សប គជ/ខប និង គ.ជ.ប. ក៏ដោយ ក៏គណបក្សនេះនៅតែបដិសេធលទ្ធផលបោះឆ្នោតដដែល ហើយចោទទាំងងងើលថា ការបោះឆ្នោតនេះមានភាពមិនប្រក្រតី។ ប្រសិនបើដូចការចោទប្រកាន់នេះមែន មានន័យថា ទាំងភ្នាក់ងារគណបក្សសង្គ្រោះជាតិ ភ្នាក់ងារគណបក្សផ្សេងៗ និងអ្នកសង្កេតការណ៍ សុទ្ធតែបានចូលរួមលួចបន្លំសន្លឹកឆ្នោតនៅទូទាំងប្រទេស។

ប្រសិនបើមានភាពមិនប្រក្រតីណាមួយ ភ្នាក់ងារគណបក្សនយោបាយអាចជំទាស់ដោយផ្ទាល់មាត់ភ្លាម ទៅកាន់ប្រធានការិយាល័យបោះឆ្នោត។ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយ មិនសុខចិត្តនឹងដំណោះស្រាយ

របស់ប្រធានទេ ភ្នាក់ងារនោះអាចសុំទម្រង់១២០២ មកបំពេញពាក្យប្តឹង និងដាក់ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) មុនម៉ោង១១:៣០នាទី នៅថ្ងៃបន្ទាប់។ ប៉ុន្តែជាក់ស្តែងពុំមានបណ្តឹងតវ៉ាណាមួយថា ភ្នាក់ងារគណបក្សសង្គ្រោះជាតិ មិនបានយល់ព្រមចុះហត្ថលេខាលើទម្រង់ពាក់ព័ន្ធ ដែលតម្រូវដោយ គ.ជ.ប. នៅការិយាល័យបោះឆ្នោតណាមួយឡើយ។

ទង្វើនេះគ្មានអ្វីដែលថ្មីនោះទេ ពីព្រោះនៅរៀងរាល់ពេលបោះឆ្នោត គណបក្សដែលដឹកនាំដោយ សម រង្ស៊ី តែងតែបដិសេធលទ្ធផលនៃការបោះឆ្នោត។ ចំណែក COMFREL វិញ ដែលតាំងខ្លួនថាជាយន្តការសង្កេតការណ៍ដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នោះ ហេតុអ្វីបានជាមានជំហរលម្អៀងទៅតាមគណបក្សប្រឆាំងទៅវិញថា ការបោះឆ្នោតនេះមានភាពមិនប្រក្រតី នៅពេលដែលអ្នកសង្កេតការណ៍របស់ខ្លួនបានចូលរួមក្នុងគ្រប់ដំណើរការនៅថ្ងៃបោះឆ្នោតរួមទាំងការរាប់សន្លឹកឆ្នោត ហើយថែមទាំងបានគណនាឃើញលទ្ធផលរួចហើយផងដែរ។

តាមរយៈភ្នាក់ងាររបស់ខ្លួន គណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល អាចគណនាលទ្ធផល នៃការបោះឆ្នោតដោយខ្លួនឯងចេញពីទម្រង់បែបបទលេខ១១០២ ដែលបិទនៅការិយាល័យបោះឆ្នោត ឬទម្រង់បែបបទលេខ១១០៤ ដែលផ្តល់ជូនដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់នៅតាមការិយាល័យបោះឆ្នោត។ ទម្រង់បែបបទលេខ១១០៤ គឺសម្រាប់តែផ្តល់ព័ត៌មានអំពីលទ្ធផលបឋមដល់គណបក្សនយោបាយតែប៉ុណ្ណោះ។ ដោយផ្អែកលើទម្រង់បែបបទលេខ១១០៤ នៃការិយាល័យបោះឆ្នោតនីមួយៗ ដែលបានបញ្ជូនមកតាមរយៈ គឃ/សប និង គជ/ខប គ.ជ.ប. នៅល្ងាចថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ គ.ជ.ប. បានប្រកាសលទ្ធផលបឋម នៃការបោះឆ្នោត។

**ស្ថានការណ៍ក្រៅការិយាល័យបោះឆ្នោត៖** គណបក្សសង្គ្រោះជាតិបានរៀបចំក្រុមយុវជនជាច្រើនក្រុម ដើរអុកឡុកនៅតាមការិយាល័យបោះឆ្នោត ដើម្បីប្រឌិតរឿងនិងបំផុសបញ្ហាផ្សេងៗ ដែលជាចិត្តសាស្ត្រទាក់ទាញអ្នកបោះឆ្នោត ទោះបីជាទង្វើនេះផ្ទុយនឹងច្បាប់ក៏ដោយ។

- នៅការិយាល័យបោះឆ្នោតមួយក្នុងសង្កាត់បឹងទំពុន តាំងពីម៉ោង៧ព្រឹក ដល់ម៉ោង៦ល្ងាច សកម្មជនមួយក្រុមប្រហែល១០០នាក់ របស់គណបក្សប្រឆាំង ក្នុងនោះមានតែ៤-៥នាក់ទេ ដែលមានទីលំនៅក្នុងសង្កាត់នេះ បានប្រមូលផ្តុំគ្នាស្រែកឡូឡារំខានដល់អ្នកបោះឆ្នោត និងបង្កចលាចលថា បាត់ឈ្មោះ គ្មានឈ្មោះ ទឹកខ្មៅលុបជ្រះ និងស្រែកថា «លេខ៧ៗ»។ ក្រុមនេះបានគំរាមមន្ត្រីការិយាល័យបោះឆ្នោតដោយប្រើពាក្យថា «ចេញពីការិយាល័យ [...] នឹងសម្លាប់ចោល» ជាដើម។ ក្រុមនេះមានទូរស័ព្ទទំនើបគ្រប់គ្នាដែលអាចថតរូបភាព និងវីដេអូបាននៅក្នុងការិយាល័យបោះឆ្នោតនេះ។ តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សកម្មភាពទាំងនេះត្រូវបានហាមឃាត់នៅក្នុងការិយាល័យបោះឆ្នោត។ នៅម៉ោង១០ព្រឹក សម រង្ស៊ី បានទៅដល់ទីនោះ ប៉ុន្តែត្រូវបានហាមឃាត់មិនឱ្យចូលវិញ។

- នៅការិយាល័យមួយទៀត ជនខិលខូចមួយក្រុមបានចោទអនុប្រធានការិយាល័យបោះឆ្នោតថា បានលួចបន្លំសន្លឹកឆ្នោត ដោយយកសន្លឹកឆ្នោតមិនបានការទៅទុកនៅក្នុងថតតុចំនួន៤សន្លឹក រួចបន្ទាប់មកថែម៣សន្លឹកទៀត នៅចំពោះមុខមន្ត្រីការិយាល័យបោះឆ្នោត ភ្នាក់ងារគណបក្ស និងអ្នកសង្កេតការណ៍។ ការដាក់សន្លឹកឆ្នោតមិនបានការនៅក្នុងថតតុនេះ ពីព្រោះតែចៀសវាងកុំឱ្យច្រឡំនឹងសន្លឹកឆ្នោតបានការ។ ទង្វើបែបនេះ គឺពុំផ្ទុយនឹងបទបញ្ញានិងនីតិវិធីនៃការបោះឆ្នោតទេ។ ជាងនេះទៀត ភ្នាក់ងារគណបក្សសង្គ្រោះជាតិក៏បានទទួលស្គាល់ដែរថា ពួកគេបានដឹងឮអំពីការដាក់សន្លឹក

ឆ្នោតទាំងនេះដែរ និងបញ្ជាក់ថាគ្មានការបន្លំទេ តែជនខិលខូចទាំងនោះ នៅតែគំរាមថា ប្រសិនបើមិនលុតជង្គង់សំពះសុំទោសនោះ នៅពេលដែលលោកអនុប្រធានការិយាល័យ ចេញពីការិយាល័យបោះឆ្នោតនឹងសម្លាប់ចោល។ ដោយសារភ័យខ្លាចអំពីសុវត្ថិភាពផ្ទាល់ខ្លួន លោកអនុប្រធានការិយាល័យបានលុតជង្គង់សំពះ ហើយក្រុមជនខិលខូចនេះ បានថតរូបរួចបង្ហោះក្នុង Facebook ថា «ចាប់បានចោរ ឥឡូវនេះចោរសំពះសុំទោសរួចហើយ»។ តាមពិត មន្ត្រីការិយាល័យ ភ្នាក់ងារពីគ្រប់គណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមានក្នុងការិយាល័យនោះ បានចុះហត្ថលេខាលើរបាយការណ៍និងទម្រង់បែបបទទាំងអស់ ដោយមិនមានការតវ៉ាអំពីភាពមិនប្រក្រតីក្នុងការិយាល័យនេះទេ។

- នៅការិយាល័យមួយនៅខេត្តកណ្តាល ក្រុមសកម្មជនគណបក្សសង្គ្រោះជាតិបានចូលទៅអុកឡុកនៅការិយាល័យបោះឆ្នោត ហើយបានហាមឃាត់អ្នកបោះឆ្នោតមិនឱ្យចូលបោះឆ្នោត ដោយចោទថា ជាយួន។ ជាក់ស្តែង ប្រជាពលរដ្ឋទាំងនេះជាអ្នកភូមិនៅការិយាល័យបោះឆ្នោតនោះដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតត្រឹមត្រូវ ទីលំនៅពិតប្រាកដ និងអត្តសញ្ញាណបណ្ណច្បាស់លាស់។ ទង្វើបង្កដោយក្រុមគណបក្សប្រឆាំងបែបនេះគឺផ្ទុយទាំងស្រុងនឹងច្បាប់ ដែលជាបទល្មើសព្រហ្មទណ្ឌ។

- នៅតាមការិយាល័យជាច្រើន ក្នុងខេត្តកណ្តាល ព្រៃវែង កំពង់ចាម តាកែវ កំពង់ធំ និងរាជធានីភ្នំពេញ ជាដើម សកម្មជនគណបក្សប្រឆាំងបានធ្វើសកម្មភាព តាមរូបភាពផ្សេងៗ ដូចជាចូលស្រែកឡូឡាអុកឡុក និងប្រើចិត្តសាស្ត្រលើអ្នកបោះឆ្នោតថា គណបក្សសង្គ្រោះជាតិឈ្នះ យួនបោះឆ្នោត មន្ត្រីការិយាល័យបោះឆ្នោតលួចបន្លំសន្លឹកឆ្នោត បញ្ឆោះប្រជាជនបោះឆ្នោតឱ្យ

លេខ៧ (គណបក្សសង្គ្រោះជាតិ) ឬនៅពេលឃើញអ្នកឈរតម្រង់ជួរមានសម្បុរស ស្រែកថា យួន ជាដើម។

- នៅពេលរាប់សន្លឹកឆ្នោត សកម្មជនគណបក្សសង្គ្រោះជាតិឈរមើលការរាប់សន្លឹកឆ្នោតនៅមុខការិយាល័យ ដោយបង្កភាពអនាធិបតេយ្យដូចជាស្រែកហ៊ោកញ្ជ្រៀវ នៅពេលឮមន្ត្រីការិយាល័យអានសន្លឹកឆ្នោត លេខ៧ (គណបក្សសង្គ្រោះជាតិ) ប៉ុន្តែធ្វើការតិះដៀលនិងចោលដបទឹកសុទ្ធ នៅពេលឮមន្ត្រីការិយាល័យអានសន្លឹកឆ្នោតលេខ៤ (គណបក្សប្រជាជនកម្ពុជា) ជាដើម។

- អំពើហិង្សាបានកើតឡើង នៅការិយាល័យបោះឆ្នោតមួយនៅស្ទឹងមានជ័យ បង្កឡើងដោយសកម្មជនគណបក្សប្រឆាំងធ្វើការអុកឡុក និងបានញុះញង់ឱ្យអ្នកគាំទ្រគណបក្សខ្លួន តតាំងជាមួយអាជ្ញាធរមានសមត្ថកិច្ចក្រោមលេសជាការតវ៉ាចំពោះភាពមិនប្រក្រតី នៅការិយាល័យបោះឆ្នោត។ អំពើហិង្សានេះ បានឈានដល់អំពើប្រទូស្តរ៉ាយជាមួយអាជ្ញាធរមានសមត្ថកិច្ច និងឈានដល់ការដុតបំផ្លាញរថយន្តរបស់កងរាជអាវុធហត្ថ ចំនួន២គ្រឿង។





*រូបភាពទី៧៖ អំពើហិង្សាដោយក្រុមបាតុករនៅស្ទឹងមានជ័យថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០១៣*

សកម្មភាពនេះគឺជាចំណុចចាប់ផ្តើមមួយនៃផែនការគ្រោងទុកជាមុន ដើម្បីជាលេសចោទថា មានភាពមិនប្រក្រតីនៃការបោះឆ្នោត និងឈានទៅដល់ការបដិសេធលទ្ធផលនៃការបោះឆ្នោត។

- នៅល្ងាចថ្ងៃបោះឆ្នោត សម រង្ស៊ី បានប្រកាសថា ខ្លួនបានឈ្នះឆ្នោតហើយ ប៉ុន្តែភ្លាមៗនោះ បុគ្គលរូបនេះ ក៏បានប្រកាសដកពាក្យនេះវិញ។

- គណបក្សសង្គ្រោះជាតិបានប្រើឧបាយកលទុច្ចរិត បង្កចលាចល និងបង្កើតឱ្យមានអស្ថិរភាពនយោបាយ ដោយប្រឌិតរឿងតាមរយៈការបញ្ចេញសារជាសំឡេងរបស់សកម្មជនខ្លួនថា សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត បានរត់គេចខ្លួនចេញទៅក្រៅប្រទេស។ ទង្វើនេះបានធ្វើឱ្យប្រជាពលរដ្ឋកម្ពុជា មានការភ័យខ្លាចចំពោះដំណឹងអំពីអវត្តមានរបស់សម្តេចតេជោ ពីក្នុងប្រទេស ហើយបាននាំគ្នាចាក់សាំងឡាន ទិញស្បៀងអាហារបម្រុងទុក និងមានការគិតគូរជម្រើសផ្សេងៗ ដើម្បីត្រៀមសុវត្ថិភាពក្នុងករណីប្រទេសធ្លាក់ចូលក្នុងស្ថានភាពសង្គ្រាម ដោយសារពួកគាត់ធ្លាប់ឆ្លងកាត់ជីវិតជូរចត់ជាច្រើនទសវត្សរ៍នៃសង្គ្រាមរ៉ាំរ៉ៃនៅកម្ពុជា។

- គណបក្សប្រជាជនកម្ពុជា ដែលគ្រប់គ្រងអំណាចបានហាមប្រាមជាដាច់ខាតមិនឱ្យមន្ត្រីសមត្ថកិច្ចចាត់វិធានការ ចៀសវាងភាពប្រទូស្តរ៉ាយនៅថ្ងៃបោះឆ្នោត ដែលអាចបង្កឱ្យមានអំពើហិង្សា ដែលជាឱកាសរបស់គណបក្សប្រឆាំងបង្កើតជាលេសចោទរាជរដ្ឋាភិបាលបាន។

### ៤.២.៣. ស្ថានការណ៍ក្រោយថ្ងៃបោះឆ្នោត

- ក្រោយថ្ងៃបោះឆ្នោតមួយថ្ងៃ គណបក្សសង្គ្រោះជាតិបានប្រឌិតព័ត៌មានដោយបំផ្លើសថា មានភាពមិនប្រក្រតីជាច្រើនក្នុងដំណើរការបោះឆ្នោតហើយបានស្នើសុំបង្កើតយន្តការថ្មីមួយហៅថា «គណៈកម្មការចម្រុះ» ឬ

«គណៈកម្មការពិសេស» ក្រោមការដឹកនាំរបស់អង្គការសហប្រជាជាតិ ឬអង្គការមិនមែនរដ្ឋាភិបាលមួយ ដើម្បីស៊ើបអង្កេតលើអ្វីដែលគណបក្សសង្គ្រោះជាតិហៅថាភាពមិនប្រក្រតី ដោយ គ.ជ.ប. មានតួនាទីត្រឹមតែជាអ្នកសម្របសម្រួលប៉ុណ្ណោះ។ សំណើនេះផ្ទុយនឹងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងរដ្ឋធម្មនុញ្ញដែលមានចែងអំពីសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ គ.ជ.ប. និងក្រុមប្រឹក្សាធម្មនុញ្ញ។

- បន្ទាប់មក នៅថ្ងៃដដែលនេះ COMFREL បានប្រកាសថាខ្លួនបានគណនាឃើញថា គណបក្សប្រជាជនកម្ពុជាទទួលបានសំឡេង៤៩,៤៩% នៃសំឡេងឆ្នោតសរុប ហើយគណបក្សសង្គ្រោះជាតិទទួលបានសំឡេង៤៣,០៥% ដែលធ្វើឱ្យគណបក្សប្រជាជនកម្ពុជា ទទួលបាន៦៧អាសនៈនិងគណបក្សសង្គ្រោះជាតិទទួលបាន៥៦អាសនៈ។ ការគណនាខុសគ្នា០១អាសនៈរបស់ COMFREL គឺដោយសារមានការគណនាខុសនៅខេត្តក្រចេះ។ COMFREL អាចគណនាចំនួនអាសនៈសរុបទូទាំងប្រទេសរបស់គណបក្សនីមួយៗ តាមទម្រង់បែបបទ១១០៤ ដែលអ្នកសង្កេតការណ៍ខ្លួនបានទទួលពីការិយាល័យបោះឆ្នោត ឬតាមទម្រង់បែបបទ១១០២ ដែលបានបិទនៅតាមការិយាល័យបោះឆ្នោត។ COMFREL បានប្រកាសលទ្ធផលបោះឆ្នោត ដែលផ្ទុយនឹងផែនការបដិសេធលទ្ធផល នៃការបោះឆ្នោតដែលបានគ្រោងទុក។ ភ្លាមៗនោះ COMFREL ក៏បានដកតួលេខផ្សព្វផ្សាយនេះ ចេញពីគេហទំព័ររបស់ខ្លួនវិញ ដើម្បីគាំទ្រការប្រឌិតលទ្ធផល នៃការបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិ។ ទោះជាយ៉ាងនេះក្ដី ក៏ព័ត៌មាននេះត្រូវបានចែកផ្សាយលើគេហទំព័រផ្សេងៗ ហើយកាសែតខេមបូឌាដេលី ក៏បានចុះផ្សាយរួចហើយដែរ។

- នៅថ្ងៃទី៤ ខែសីហា កឹម សុខា បានប្រកាសថា «នៅម៉ោង៥ រាប់ទៅឃើញគណបក្សសង្គ្រោះជាតិ ឡើងដល់៧៦កៅអី។ គេ (មិនដឹងនរណាទេ)

រាយការណ៍ប្រាប់អង្គទូតថា យើងឈ្នះហើយ ស្រាប់តែឈប់រាប់តែម្តង។ គេ (គណបក្សប្រជាជនកម្ពុជា) ប្រកាសថា គេឈ្នះវិញ គឺគេមានល្បិចលួចយើងហើយ។ ... អង្គការអន្តរជាតិ ទូតនៅប្រទេសប្រជាធិបតេយ្យ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ គេដឹងច្បាស់ថា គណបក្សសង្គ្រោះជាតិជាអ្នកឈ្នះហើយ»។

- នៅថ្ងៃទី៤ ខែសីហាដដែល សម រង្ស៊ី បានលើកឡើងថា «គណបក្សប្រជាជនកម្ពុជាបានអះអាងថា ខ្លួនមានសមាជិកពី៦ទៅ៧លាននាក់ ដល់បោះឆ្នោតបានតែ៣លាន មិនដឹងថាទៅណាអស់។ បាន៣លាននាក់ គឺភាគច្រើនបានពីសំឡេងសម្លុត សំឡេងលួច សំឡេងបន្លំ សំឡេងទិញ សំឡេងឈ្មោះខ្មោច សំឡេងយួន និងសំឡេងខ្យល់»។ ប្រសិនបើសម្តីរបស់ សម រង្ស៊ី ពិតមែននោះ មានន័យថាគណបក្សប្រជាជនកម្ពុជាស្ទើរតែគ្មានអ្នកគាំទ្រ។

- នៅថ្ងៃទី៦ ខែសីហា កឹម សុខា បាននិយាយប្រាប់សកម្មជននិងក្រុមបាតុករថា «ខ្ញុំអត់ប្រាប់ថាបានពីបរទេសណាទេ ខ្ញុំជាមួយឯកឧត្តម សម រង្ស៊ី នៅថ្ងៃបោះឆ្នោត ម៉ោង៥-៦ល្ងាច ទទួលបានព័ត៌មានច្បាស់ណាស់ គេប្រាប់ថាយើងបាន៧៦កៅអី ស្រាប់តែមួយម៉ោងក្រោយមក ក្រឡាប់ចាក់ទៅអញ្ចេះវិញ»។

- នៅលើទំព័រ Facebook របស់ សម រង្ស៊ី នៅថ្ងៃទី៨ ខែសីហា បានសរសេរថា៖ «ខ្ញុំដឹងថាសកម្មភាពចល័តកម្លាំងប្រដាប់អាវុធ កើតឡើងតាមការបញ្ជារបស់បុគ្គលកាន់អំណាចម្នាក់ប៉ុណ្ណោះ ហើយខ្ញុំក៏ដឹងទៀតថា បងប្អូនកូនក្មួយ ពលទាហាន ប៉ូលីស និងកងកម្លាំងប្រដាប់អាវុធទាំងអស់ កំពុងទន្ទឹងរង់ចាំរដ្ឋាភិបាលថ្មី ដែលនឹងផ្តល់ប្រាក់ខែជូនយ៉ាងតិច១លានរៀលក្នុងមួយខែ។ នៅពេលនេះ ជាឱកាសមាសរបស់បងប្អូនរួមគ្នាក្រោកឡើង ជាមួយ

ប្រជាពលរដ្ឋ និងជាមួយយុវជនសង្គ្រោះជាតិ ដើម្បីទាមទារឱ្យមានការផ្លាស់ប្តូរឆ្ពោះទៅរកការបង្កើតរដ្ឋាភិបាលថ្មី ក្នុងឆ្នាំ២០១៣នេះឱ្យទាល់តែបាន»។

- នៅថ្ងៃទី១២ ខែសីហា កឹម សុខា បានប្រកាសទៀតថា «គណបក្សខ្លួនបានទទួលយ៉ាងតិច ៦៣អាសនៈ» ផ្ទុយពីការប្រកាសនៅថ្ងៃទី៤ និងថ្ងៃទី៦ ខែសីហា ដែលប្រកាសថា «គណបក្សសង្គ្រោះជាតិទទួលបាន៧៦អាសនៈ»។ ការពោលអះអាងនេះ គ្រាន់តែជាការប្រឌិត ដើម្បីភូតកុហកប្រជាពលរដ្ឋ និងសាធារណមតិអន្តរជាតិតែប៉ុណ្ណោះ ហើយអ្នកដែលរាយការណ៍ទៅអង្គទូតនោះគឺគ្មាននរណាក្រៅពី កឹម សុខា ខ្លួនឯងនោះទេ ឬក៏ជាការប្រឌិតរឿងទាំងស្រុងដោយយកឈ្មោះស្ថានទូតប្រើតែប៉ុណ្ណោះ។

**សំណួរសួរថា៖**

១- តើអង្គការអន្តរជាតិ ទូតប្រទេសប្រជាធិបតេយ្យ និងអង្គការមិនមែនរដ្ឋាភិបាលណាមួយ ដែលបានដឹងនិងប្រាប់ កឹម សុខា និង សម រង្ស៊ី ថា គណបក្សសង្គ្រោះជាតិបានទទួល៧៦ឬ៦៣អាសនៈ?

២- តើតួលេខក្នុងទម្រង់បែបបទ១១០៤ ដែលភ្នាក់ងារគណបក្សសង្គ្រោះជាតិ ទទួលបាននៅគ្រប់ការិយាល័យបោះឆ្នោតនៅឯណា?

រហូតដល់ថ្ងៃចាប់ខ្លួន កឹម សុខា ពុំមានស្ថានទូតណាមួយ ដែលបានអះអាងថា ខ្លួនជាអ្នកផ្តល់ព័ត៌មាន ឬ កឹម សុខា ប្រាប់ថា ស្ថានទូតណាមួយជាអ្នកផ្តល់ព័ត៌មាននោះទេ។

- សម រង្ស៊ី ក៏បានញុះញង់ឱ្យប្រជាពលរដ្ឋនៅតាមខេត្តជុំវិញរាជធានីភ្នំពេញ «ចូលរួមមហាបាតុកម្មមួយដ៏ធំក្នុងប្រវត្តិសាស្រ្ត... ឱ្យញ័រផែនដី... ដើម្បីរំដោះប្រទេសជាតិយើង... ឱ្យទាល់តែបាន បើយើងបណ្តោយឱ្យពួកផ្តាច់ការ ពួកដែលសម្លាប់ជាតិឯង ពួកពុករលួយដល់ឆ្អឹង ពួកឱ្យយួនខ្ចីដៃ

សម្លាប់ជាតិឯង។ បើយើងបណ្តោយឱ្យតែបួន ប្រាំឆ្នាំទៀត ជាតិយើងរលាយហើយ ដូច្នេះយើងអត់សុខចិត្តទេ ត្រៀមខ្លួនទាំងអស់គ្នា សង្គ្រោះជាតិយើងឱ្យទាល់តែបាន»។

- នៅស្ទើរគ្រប់វេទិកាសាធារណៈ គណបក្សប្រឆាំងបានប្រើប្រាស់ទិន្នន័យប្រឌិតរបស់ COMFREL ដែលថា គ.ជ.ប. បានលុបឈ្មោះ១,២៥លាននាក់ និង NDI ដែលថា គ.ជ.ប. បានលុបឈ្មោះ១,០៤លាននាក់ ចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ដើម្បីចោទថា គឺជាមូលហេតុនៃការចាញ់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិ។ មេដឹកនាំគណបក្សប្រឆាំងបានបំផ្លើសការពិតនៃលទ្ធផលបោះឆ្នោតថា គណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោត ដោយសារការលួចបន្លំ ហើយតាំងខ្លួនជាអ្នករកយុត្តិធម៌ជូនម្ចាស់ឆ្នោត។ គណបក្សនេះក៏បានញុះញង់ និងកៀរគរប្រជាពលរដ្ឋឱ្យចូលរួមបាតុកម្មមួយ ដែលគេហៅថា «មហាបាតុកម្មសម្តែងឆន្ទៈរបស់ម្ចាស់ឆ្នោត»។

- នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ នៅក្បាលថ្នល់ មេដឹកនាំគណបក្សសង្គ្រោះជាតិបានញុះញង់ប្រមូលកម្លាំងប្រព្រឹត្តអំពើហិង្សា និងបង្កអសន្តិសុខនៅតំបន់នោះ ហើយប្រើល្បិចកលរុញក្រុមបាតុករ ឱ្យប្រឈមនិងប៉ះទង្គិចជាមួយកម្លាំងសមត្ថកិច្ចរក្សាសន្តិសុខក្នុងរាជធានី ដែលបណ្តាលឱ្យមានមនុស្សរងរបួសនិងបាត់បង់ជីវិត។ មេដឹកនាំគណបក្សប្រឆាំងបានអនុវត្តផែនការទាមទារដង្ហែរសាកសព ទៅកាន់ទីលានប្រជាធិបតេយ្យ ដែលជាទីកន្លែងប្រមូលផ្តុំបាតុករ និងជាទីលានសម្រាប់ធ្វើយុទ្ធនាការ និងចាត់តាំងសកម្មភាពចល័តកម្លាំង។ សកម្មភាពបែបនេះ គឺស្រដៀងគ្នាទៅនឹងអ្វីដែលធ្លាប់កើតមានឡើង ក្នុងប្រទេសមួយចំនួន ដែលកើតមានចលនាបដិវត្តន៍ពណ៌នាពេលកន្លងមក។

- ពីរឬបីថ្ងៃក្រោយថ្ងៃបោះឆ្នោត គណបក្សប្រឆាំងបានចាប់ផ្ដើមកៀរគរកម្លាំងរបស់ខ្លួន ធ្វើបាតុកម្មតាមដងផ្លូវក្នុងមួយសប្ដាហ៍ម្ដង ហើយបានប្រែក្លាយទៅជាការធ្វើបាតុកម្មជារៀងរាល់ថ្ងៃ និងប្រកាសធ្វើបាតុកម្មជាប់ជានិច្ច រហូតរដ្ឋអំណាចស្របច្បាប់ដួលរលំ ដោយចាប់ផ្ដើមពីបាតុកម្មអហិង្សា បន្ទាប់មកជំរុញចលនានេះឱ្យក្លាយជាការងើបឡើងធ្វើកូដកម្ម កុបកម្ម និងការបះបោរដោយហិង្សា ពីប្រជាពលរដ្ឋ កម្មករ យុវជនមួយចំនួនតូច និងមជ្ឈដ្ឋានអមិត្តដែលត្រូវបានគណបក្សប្រឆាំងតែងតែអះអាងថា ជាធន្ទះរបស់រាស្ត្រ ដោយមានការជួយជ្រោមជ្រែង និងឧបត្ថម្ភមធ្យោបាយហិរញ្ញវត្ថុ និងបច្ចេកទេស ពីអង្គការមិនមែនរដ្ឋាភិបាលបរទេសមួយចំនួន ដែលតាំងខ្លួនជាសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (Electoral Reform Alliance – ERA) ជាពិសេសវិទ្យាស្ថាន NDI។

ដើម្បីសម្រេចបានមហិច្ឆតានេះ គណបក្សសង្គ្រោះជាតិបានប្រើល្បិចកិចកលជាច្រើន ប្រើពាក្យសម្ដីអសុរោះនិងញុះញង់ដោយគ្មានការទទួលខុសត្រូវ ដើម្បីបណ្ដុះផ្នត់គំនិតអ្នកគាំទ្រខ្លួន ឱ្យស្អប់ខ្ពើមនិងមាក់ងាយគណបក្សប្រជាជនកម្ពុជា និងថ្នាក់ដឹកនាំរាជរដ្ឋាភិបាល។ សកម្មភាពទាំងនេះស្ដែងចេញជាបន្តបន្ទាប់ ទាំងពេលមុននិងក្រោយបោះឆ្នោត នៅពេលធ្វើបាតុកម្មនិងដង្ហែរក្បួនតាមផ្លូវ ដូចជា៖

- គណបក្សសង្គ្រោះជាតិបានស្រែកដៀលសមាជិក និងថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាថា «ពួកអាយ៉ងយួន» «ពួកអាក្បាលយួនខ្លួនខ្មែរ» «ពួកក្បត់ជាតិ» «ពួកលក់ជាតិ» ។ល។
- គណបក្សប្រឆាំង បានប្រើអំពើទុច្ចរិតទាមទារឱ្យថ្នាក់ដឹកនាំកំពូលរាជរដ្ឋាភិបាល ចុះចេញពីតំណែង ដើម្បីរៀបចំការបោះឆ្នោតឡើងវិញ ដូចជាបានស្រែកថា «ហ៊ុន សែន អើយ ចុះចេញទៅ»។

គណបក្សប្រឆាំងបានយកឆន្ទៈមនុស្សមួយចំនួនតូច ធៀបនឹងប្រជាពលរដ្ឋជាង១៥លាននាក់ ធ្វើអាជីវកម្មនយោបាយ។ ក្រុមនេះបានសន្យា ផ្ដល់ប្រាក់ខែជូនគ្រូបង្រៀននិងមន្ត្រីរាជការ២៥០ ដុល្លារអាមេរិកក្នុង១ខែ ដើម្បីជានុយទាក់ទាញពួកគេមកធ្វើបាតុកម្ម អុជអាលឱ្យមានកំហឹងវណ្ណៈ និងការប្រកាន់ពូជសាសន៍ ក្នុងគោលដៅកៀរគរចំនួនអ្នកចូលរួមធ្វើបាតុកម្ម ឱ្យបានកាន់តែច្រើនថែមទៀត។ នៅឆ្នាំ២០១៣ ក្នុងពេលបាតុកម្មម្ដងៗ ក្រុមប្រឆាំងតែងតែបំផ្លើសថា មានអ្នកគាំទ្រដង្ហែក្បួនបាតុកម្ម១លាន ឬ២លាននាក់ តែតាមការពិត ក្នុងកំលុងយុទ្ធនាការបោះឆ្នោតឆ្នាំ២០១៧ សម្ដេចតេជោ **ហ៊ុន សែន** បានដឹកនាំដង្ហែក្បួនឃោសនា ដែលក្បាលក្បួននៅគល់ស្ពានជ្រោយចង្វារ ចំណែកកន្ទុយក្បួននៅផ្លូវ៦០ម៉ែត្រ (ក្បាលថ្នល់) ដោយមានអ្នកចូលរួមតែប្រមាណ២៥០ ០០០នាក់តែប៉ុណ្ណោះ។ តាមរយៈតួលេខនេះ គឺបញ្ជាក់ច្បាស់ថា គណបក្សប្រឆាំងហ៊ានធ្វើអ្វីគ្រប់យ៉ាងទាំងអស់ សូម្បីតែតួលេខនៃចំនួនបាតុករក៏បំប៉ោងដែរ ដើម្បីធ្វើជាលេសទាក់ទាញមហាជន និងបំភ័ន្តថា មានបាតុករមួយលាន ឬពីរលាននាក់ ដែលសម្ដែងឆន្ទៈចង់ផ្ដួលរំលំរដ្ឋអំណាច។

- ក្នុងគោលដៅជំរុញនិងញុះញង់ឱ្យមានបាតុកម្ម និងកូដកម្ម នៅថ្ងៃទី២៣ ខែធ្នូ សម រង្ស៊ី និង កឹម សុខា បានកុហក និងប្រឌិតប្រាប់ក្រុមបាតុករថា «ម្សិលមិញនេះ ខ្ញុំ (កឹម សុខា) ដឹងដំណឹងមានអ្នកនៅជិតគាត់ (សម្ដេចតេជោ **ហ៊ុន សែន**) ឱ្យព័ត៌មានមកថា នៅមិនបានទេយើង បើស៊ូប៉ុណ្ណឹងនៅមិនបានទេ។ ម្សិលមិញនេះគាត់ (សម្ដេចតេជោ **ហ៊ុន សែន**) ប្រុងចុះហើយ ប៉ុន្តែឥឡូវគេ

(វៀតណាម) កោះហៅភ្លាមតែម្ដង...។ ...ខ្ញុំខ្លាចគេ (វៀតណាម) យកទៅដាក់ថ្នាំ ស្រាប់តែមកវិញលែងចុះ...។» «...ម្សិលមិញនេះ ប្រុងតែចុះនៅថ្ងៃស្អែកហ្នឹងហើយ ហើយកម្លាំងម្សិលមិញនេះរៀបចំទៅសុំសារភាពជាមួយប្រជារាស្ត្រហើយ...។»

- សម រង្ស៊ី និង កឹម សុខា បានចុះទៅដល់រោងចក្រមួយចំនួន ដូចជា រោងចក្រកាត់ដេរអេសអិល រោងចក្រកាត់ដេរយ៉ាក់ជិន និងតំបន់សេដ្ឋកិច្ចពិសេសបាវិត ដើម្បីញុះញង់ឱ្យកម្មករឈប់ធ្វើការ និងសន្យាដំឡើងប្រាក់ខែ១៦០ដុល្លារក្នុងមួយខែ ចំណែកសកម្មជនពាលរបស់គណបក្សនេះ បានទៅសំឡុតគំរាមកំហែងកម្មករមិនឱ្យចូលធ្វើការ បង្កការខូចខាត ឬដុតបំផ្លាញទ្រព្យសម្បត្តិរោងចក្រជាដើម។ ទន្ទឹមនឹងនេះ លោក វន់ ពៅ ប្រធានសមាគមសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលគាំទ្រគណបក្សប្រឆាំង បានដឹកនាំកម្មករធ្វើការប្រមូលផ្ដុំតវ៉ានៅមុខក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងនៅមុខទីស្ដីការគណៈរដ្ឋមន្ត្រី។ ក្រុមបាតុករបានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និងឯកជនមួយចំនួន ដូចជា នៅហាងកែសម្ផស្សលុច្ស នៅមុខសាលារាជធានីភ្នំពេញ និងនៅទីលានប្រជាធិបតេយ្យ។
- នៅពេលតែមួយ សម រង្ស៊ី និង កឹម សុខា ប្រកាសចរចាជាមួយគណបក្សប្រជាជនកម្ពុជា តែបែរជារៀបចំផែនការដឹកជញ្ជូន ដុំថ្ម គ្រាប់បែកដបសាំង (molotov cocktail) ដំបង ជំពាមកៅស៊ូដែលប្រើគ្រាប់ឃ្លីដែក ដាវ កាំភ្លើង និងកង់ឡានទៅស្ដុកទុកនៅកន្លែងបាតុកម្ម ដើម្បីជំរុញជនអនាធិបតេយ្យប្រព្រឹត្តអំពើហិង្សា និងបទឧក្រិដ្ឋ ប្រើអាវុធនិងដាវប្រឆាំងនឹងសមត្ថកិច្ច បំផ្លាញទ្រព្យសម្បត្តិរោងចក្រ ទ្រព្យសម្បត្តិរដ្ឋនិងឯកជន និងបង្កភាពវឹកវរ

យ៉ាងធ្ងន់ធ្ងរនៅតាមដងផ្លូវវែងស្រែង នៅថ្ងៃទី២និងទី៣ ខែមករា ឆ្នាំ២០១៤។ សកម្មភាពនេះបង្ហាញឱ្យឃើញថា បុគ្គលទាំងពីរនេះ ប្រកាសថានឹងចរចាជាមួយគណបក្សប្រជាជនកម្ពុជា គឺគ្រាន់តែ ដើម្បីកេងពេលវេលា និងបិទបាំងគម្រោងការធ្វើបាតុកម្មហិង្សា របស់ខ្លួនប៉ុណ្ណោះ។ គោលបំណងរបស់មេដឹកនាំគណបក្សនេះ គឺធ្វើ យ៉ាងណាឱ្យមានការបង្ហូរឈាម ដើម្បីទម្លាក់កំហុសមកលើរាជរដ្ឋា ភិបាល និងឈានដល់ផែនការគ្រោងទុកចុងក្រោយ គឺដណ្តើម អំណាច ដូចដែល កឹម សុខា និយាយថាយកគំរូតាមប្រទេស យូហ្គោស្លាវី។

ដោយដឹងអំពីគម្រោងការនេះ ស្ថានទូតសាធារណរដ្ឋកូរ៉េ ជប៉ុន និងចិន បានស្នើសុំឱ្យសមត្ថកិច្ចកម្ពុជា ជួយការពារជនជាតិនិងក្រុមហ៊ុន របស់ខ្លួន។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការ ដើម្បីទប់ស្កាត់អំពើហិង្សា ដែលមានលក្ខណៈជាចលនាបដិវត្តន៍ពណ៌នេះ។ ក្នុងការឆ្លើយតបនឹងការ ចោទថា ស្ថានទូតសាធារណរដ្ឋកូរ៉េនៅពីក្រោយយោធា ដើម្បីប្រើអំពើហិង្សា លើបាតុករ ក្រសួងការបរទេសនៃសាធារណរដ្ឋកូរ៉េបានផ្ញើលិខិតមួយជូន សារព័ត៌មាន Global Post ដោយមានខ្លឹមសារថា ស្ថានទូតសាធារណរដ្ឋកូរ៉េ បានស្នើឱ្យមានការការពារដល់ជនជាតិនិងក្រុមហ៊ុនកូរ៉េ។ ដោយសារគម្រោង ការបាតុកម្មនេះ អាចឈានទៅដល់ការបង្ហូរឈាម ដែលគំរាមកំហែងយ៉ាង ធ្ងន់ធ្ងរ ដល់សុវត្ថិភាពរបស់ជនជាតិនិងក្រុមហ៊ុនកូរ៉េនោះ ស្ថានទូតសាធារណរដ្ឋ កូរ៉េបានស្នើថា ការការពារចំពោះជនជាតិនិងក្រុមហ៊ុនកូរ៉េត្រូវតែយកចិត្ត ទុកដាក់ខ្ពស់។

បាតុកម្មហិង្សា និងបង្ហូរឈាមនៅផ្លូវវែងស្រែង ពិតជាបានកើតមាន ឡើងដូចព័ត៌មានចារកម្មដែលស្ថានទូតប្រទេសទាំងបីខាងលើ បានផ្តល់ជូនដល់

រាជរដ្ឋាភិបាលជាមុនមែន។ គណបក្សប្រឆាំងបានទទួលផលប្រយោជន៍ពីបាតុកម្មហិង្សានេះ ហើយប្រទេសមួយចំនួនអាចបានដឹង ឬមិនបានដឹងអំពីផែនការគ្រោងទុកជាមុននេះ ជាពិសេស ប្រទេសដែលបានជួយរៀបចំផែនការនេះ បែរជាគាំទ្រទង្វើខុសច្បាប់របស់គណបក្សសង្គ្រោះជាតិ ហើយទិតៀនរាជរដ្ឋាភិបាលថាបានប្រើប្រាស់កម្លាំងបង្ក្រាបបាតុករអហិង្សា បំបិទសិទ្ធិសេរីភាព និងមិនគោរពសិទ្ធិមនុស្សទៅវិញ។



*រូបភាពទី៨៖ ក្រុមបាតុករនៃបដិវត្តន៍ពណ៌បង្កអំពើហិង្សានៅផ្លូវវេងស្រេង ថ្ងៃទី ២-៣ ខែមករា ឆ្នាំ២០១៤*

កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ សម រង្ស៊ី បាននិយាយថា «នេះហើយជាការប្ដេជ្ញាចិត្តរបស់គណបក្សសង្គ្រោះជាតិ ដែលមាន សម រង្ស៊ី និង កឹម សុខា សូមប្រកាសចំពោះកម្មករ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣នេះ សូមប្រកាសសាជាថ្មីម្ដងទៀតថា គណបក្សសង្គ្រោះជាតិនឹងរៀបចំរដ្ឋាភិបាលថ្មី រៀបចំប្រទេសឡើងវិញ ហើយជាពិសេស ថ្ងៃអាទិត្យទី២៩ ខែធ្នូ ផ្តាច់ព្រ័តហើយ»។ ការអំពាវនាវបែបនេះ គឺបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា នេះគឺជា

ចលនាបដិវត្តន៍ពណ៌ផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ និងជំរុញឱ្យមានការប្រមូលផ្តុំកម្លាំងមហាជន ធ្វើកុបកម្ម។

នៅក្នុងពេលបោះឆ្នោតឆ្នាំ២០១៣ គណបក្សប្រឆាំង ប្រព័ន្ធឃោសនាប្រឆាំង និងអង្គការមិនមែនរដ្ឋាភិបាលដែលជាសម្ព័ន្ធមិត្ត បានធ្វើយុទ្ធនាការឃោសនាទាំងក្នុងនិងក្រៅប្រទេស ដើម្បីធ្វើឱ្យមហាជននិងអ្នកនយោបាយនៃបណ្តាប្រទេសមួយចំនួន ជឿលើការភូតកុហក បំភ្លៃ និងប្រឌិតរឿងរបស់ពួកខ្លួនថា ប្រព័ន្ធរៀបចំការបោះឆ្នោតនៅកម្ពុជា និងយន្តការរៀបចំការបោះឆ្នោត គឺគ្មានយុត្តិធម៌ និងគ្មានតម្លាភាព ហើយថាលទ្ធផលនៃការបោះឆ្នោតត្រូវបានលួចបន្លំ ដោយ គ.ជ.ប. និងគណបក្សប្រជាជនកម្ពុជា ក្នុងគោលដៅដាក់សម្ពាធឱ្យថ្នាក់ដឹកនាំកំពូលរាជរដ្ឋាភិបាលចុះចេញពីតំណែង និងរៀបចំការបោះឆ្នោតឡើងវិញ ឬផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ តាមរយៈការប្រើប្រាស់កម្លាំងមហាជន និងបញ្ចុះបញ្ចូលអន្តរជាតិឱ្យដាក់សម្ពាធមកលើរដ្ឋាភិបាលតាមរូបភាពផ្សេងៗ។

ដោយសារបាតុកម្មប្រឆាំងលទ្ធផលបោះឆ្នោត ដែលមានចរិតជាបដិវត្តន៍ពណ៌ ឈានទៅផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ បានអូសបន្លាយអស់រយៈពេលយ៉ាងយូរនិងគ្មានលទ្ធផល ហើយអ្នកចូលរួមបានបាត់បង់ជំនឿនិងថយចំនួនកាន់តែតិចទៅៗ ទើបថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិបានរៀបចំផែនការប្រើអំពើហិង្សា ទៅលើកងកម្លាំងរក្សាសណ្តាប់ធ្នាប់សាធារណៈ ដើម្បីឱ្យមានការបង្ក្រាបពីកម្លាំងសមត្ថកិច្ច ក្នុងគោលបំណងប្រើប្រាស់រឿងនេះធ្វើជាលេស ដើម្បីចូលមកកាន់តុចរចាជាមួយគណបក្សប្រជាជនកម្ពុជា។ អំពើហិង្សានេះ បានធ្វើឱ្យកម្លាំងរក្សាសណ្តាប់ធ្នាប់សាធារណៈរងរបួសធ្ងន់ស្រាលចំនួន៣៩នាក់។ ព្រឹត្តការណ៍នេះមិនមែនជាការប្រទូស្តរ៉ាយ រវាងបាតុករនិងកម្លាំងរក្សាសណ្តាប់ធ្នាប់សាធារណៈដោយចៃដន្យទេ តែជាការគ្រោងទុក

ជាមុន ដោយមានឧបករណ៍ផ្សេងៗសម្រាប់អនុវត្តអំពើហិង្សា ចំណែកឯកម្លាំងរក្សាសណ្តាប់ធ្នាប់សាធារណៈពុំមានអ្វីការពារខ្លួន ដូច្នេះទើបត្រូវរបួស ផ្ទុយទៅវិញ ភាគីបាតុករពុំមានរងរបួសម្នាក់ឡើយ។

### ៤.២.៤. ដំណោះស្រាយបណ្តឹងតវ៉ា

**ការដោះស្រាយបណ្តឹងតវ៉ានៅ គ.ជ.ប.៖** នៅម៉ោង៩ព្រឹកនាថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ គ.ជ.ប. បានប្រកាសលទ្ធផលបណ្តោះអាសន្នតាមទូរទស្សន៍ជាតិកម្ពុជា បន្ទាប់ពីបានដោះស្រាយពាក្យប្តឹងចំនួន១៣ និងចេញសេចក្តីសម្រេចលើបណ្តឹងចំនួន៤ ដោយអនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជានិងនីតិវិធី។ សេចក្តីសម្រេចរបស់ គ.ជ.ប. ធ្វើឡើងគឺផ្អែកលើការចោទសួរដើមបណ្តឹងផ្ទាល់មាត់ និងពិនិត្យលើភស្តុតាងដែលផ្តល់ដោយដើមបណ្តឹង។

**ការដោះស្រាយបណ្តឹងតវ៉ានៅក្រុមប្រឹក្សាធម្មនុញ្ញ៖** គណបក្សសង្គ្រោះជាតិដាក់ពាក្យបណ្តឹងចំនួន១៥ ជំទាស់នឹងសេចក្តីសម្រេចរបស់ គ.ជ.ប. ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព «ក» សរុបចំនួន៤១ កញ្ចប់ ក្នុងខេត្តចំនួន៤ គឺ ក្រចេះ សៀមរាប បាត់ដំបង និងកណ្តាល។ គ.ជ.ប. បានបើកកញ្ចប់សុវត្ថិភាព «ក» ទៅតាមដីកាបង្គាប់របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដោយមានតំណាងឬភ្នាក់ងារ ដូចជា ក្រុមប្រឹក្សាធម្មនុញ្ញ គ.ជ.ប. ស្ថានទូត គណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ គណបក្សហ៊្វុនស៊ីនប៉ិច អ្នកសារព័ត៌មាន រួមទាំងអ្នកសង្កេតការណ៍មកពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ។

បន្ទាប់ពីទទួលបានលទ្ធផល នៃការបើកកញ្ចប់សុវត្ថិភាពនៅតាមខេត្តនីមួយៗ តាមពាក្យបណ្តឹងរបស់គណបក្សសង្គ្រោះជាតិ ក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្តីសម្រេចចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៣៖

- តម្កល់សេចក្តីសម្រេចរបស់ គ.ជ.ប. ទុកជាបានការពេញទាំងស្រុង
- សេចក្តីសម្រេចនេះជាសេចក្តីសម្រេចស្ថាពរ និងបិទផ្លូវតវ៉ា ហើយមានអនុភាពទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច។

ទោះបីជាក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចរួចហើយក្តី ហើយលទ្ធផលបោះឆ្នោតផ្លូវការត្រូវបានប្រកាសនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៣ក៏ដោយ ក៏គណបក្សប្រឆាំងនៅតែបំពានលើច្បាប់ ដោយមិនគោរពតាមការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។ ច្បាប់ចែងថា ការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញគឺជាការសម្រេចបិទផ្លូវតវ៉ា ហើយជនណាបំពាននឹងសេចក្តីសម្រេចនេះ ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ ពី១ខែទៅ១ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១០ម៉ឺនរៀល ដល់៦០ម៉ឺនរៀល ឬផ្តន្ទាទោសណាមួយក្នុងចំណោមទោសទាំងពីរ។

### ៤.២.៥. ការបញ្ចប់ពហិការរបស់គណបក្សប្រឆាំង

ក្រោយពី គ.ជ.ប. បានប្រកាសលទ្ធផលនៃការបោះឆ្នោតផ្លូវការ គណបក្សសង្គ្រោះជាតិពុំព្រមទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត និងបានធ្វើពហិកាចូលសួថកាន់តំណែង។ ពួកគេបានធ្វើឱ្យសភាពការណ៍នយោបាយរបស់ប្រទេសធ្លាក់ចូលក្នុងស្ថានភាពអាប់អួរ ដើម្បីទាញយកផលចំណេញពីស្ថានភាពបែបនេះ ដោយបែរទៅរកផែនការគ្រោងទុកជាមុន ដើម្បីបដិសេធលទ្ធផលបោះឆ្នោត និងដណ្តើមអំណាចតាមវិធីនៃការធ្វើបដិវត្តន៍ពណ៌ ដោយចាប់ផ្តើមពីការធ្វើបាតុកម្មអហិង្សា ទៅជាបាតុកម្មហិង្សាជាបណ្តើរៗ ដែលមានមេខ្លោងជាតំណាងរាស្ត្រជាប់ឆ្នោត និងជនដៃដល់មួយចំនួន។

បន្ទាប់ពីប្រើអំពើហិង្សាលើកម្លាំងរក្សាសណ្តាប់ធ្នាប់សាធារណៈ នៅស្ពាននាគ ការថយចុះនៃចំនួនអ្នកចូលរួមបាតុកម្ម និងកង្វះខាតមធ្យោបាយ

ហិរញ្ញវត្ថុផង និងដោយដឹងយ៉ាងច្បាស់ថា ចលនាបដិវត្តន៍ពណ៌ដើម្បីផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ មិនអាចទទួលបានជោគជ័យ តាមផែនការដែលបានគ្រោងទុកនោះ គណបក្សសង្គ្រោះជាតិ បានសុំចរចាជាមួយគណបក្សប្រជាជនកម្ពុជា។ ក្នុងស្មារតីបង្រួបបង្រួមជាតិ តម្កល់ផលប្រយោជន៍ជាតិជាធំ និងដើម្បីចៀសវាងការបែកបាក់ផ្ទៃក្នុងជាតិ គណបក្សប្រជាជនកម្ពុជា បានទទួលយកសំណើសុំចរចារបស់គណបក្សនេះ។ ជាលទ្ធផល គណបក្សសង្គ្រោះជាតិបានយល់ព្រមទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ទទួលយកអាសនៈក្នុងរដ្ឋសភា និងទទួលយកតំណែងអនុប្រធានរដ្ឋសភាទី១ និងប្រធានគណៈកម្មការចំនួន៥ ក្នុងចំណោមគណៈកម្មការទាំង១០ របស់រដ្ឋសភា។

គណបក្សទាំងពីរបានឯកភាពបង្កើតឡើងនូវ **«វប្បធម៌សន្ទនា»** សំដៅបង្កើតឱ្យមានភាពសុខដុមក្នុងចំណោមអ្នកនយោបាយ ហើយ **«វប្បធម៌សន្ទនា»** នេះ ផ្តើមចេញពីការជួបគ្នារវាងសម្តេចតេជោនាយករដ្ឋមន្ត្រី និង សម រង្ស៊ី រួមទាំងការជួបជុំពិសាបាយសាមគ្គី ជាគ្រួសារផងដែរ។ ប៉ុន្តែ មិនយូរប៉ុន្មាន **«វប្បធម៌សន្ទនា»** នេះ ត្រូវបានរលាយបាត់ទៅវិញ ដោយសារភាពមិនស្មោះត្រង់របស់ សម រង្ស៊ី រួមទាំងថ្នាក់ដឹកនាំរបស់គណបក្សសង្គ្រោះជាតិ។

ទាំងនៅក្នុងនិងក្រៅរដ្ឋសភា ដើម្បីទាញយកប្រជាប្រិយភាព គណបក្សសង្គ្រោះជាតិតែងតែប្រើប្រាស់វេទិកាសភា និងវេទិកាក្នុងស្រុកនិងក្រៅស្រុក ធ្វើការវាយប្រហារដោយមិនត្រឹមត្រូវ លើគណបក្សប្រជាជនកម្ពុជា រាជរដ្ឋាភិបាលនិងសម្តេចតេជោ **ហ៊ុន សែន** ជាពិសេស ពួកគេបានពន្យុះឱ្យសកម្មជនរបស់ខ្លួន ប្រឌិតរឿងនិងបង្កាច់បង្ខូចសម្តេចតេជោ **ហ៊ុន សែន** តាមរបៀបផ្សេងៗ ហើយខ្លួនធ្វើព្រងើយកន្តើយហាក់ដូចមិនបានដឹងឬពាក់ព័ន្ធឡើយ។ ជារឿយៗ ក្រុមសមាជិកសភារបស់គណបក្សនេះ បានបដិសេធចូលរួមប្រជុំ និងពិភាក្សាលើសេចក្តីព្រាងច្បាប់នានា ហើយតែងតែបញ្ចេញឥរិយាបថផ្ទុយ

នឹងកាតព្វកិច្ច ជាសមាជិកសភាដែលត្រូវបម្រើផលប្រយោជន៍ប្រជាជាតិនិងប្រជាជន។ ទោះជាយ៉ាងណាក៏ដោយ គណបក្សប្រជាជនកម្ពុជានៅតែបន្តធ្វើការនិងសហការជាមួយគណបក្សសង្គ្រោះជាតិ ដោយឈរលើផលប្រយោជន៍ជាតិនិងប្រជាពលរដ្ឋជាធំ។

គណបក្សសង្គ្រោះជាតិនៅតែចិញ្ចឹមចិត្តបន្តអនុវត្តផែនការ ឧបាយកល និងសកម្មភាពបដិវត្តន៍ពណ៌ ដូចជាការបង្ហាញអំពីអត្តសញ្ញាណនៃចលនាបដិវត្តន៍ពណ៌ខ្មៅជាដើម ក្នុងគោលបំណងត្រៀមផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ នៅមុនពេលឬក្រោយពេលបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៨ ជាដើម ហើយការបែកធ្លាយនូវអំនួតរបស់ កឹម សុខា ដែលពាក់ព័ន្ធនឹងអំពើក្បត់ជាតិ បាននាំទៅដល់ការចាប់ខ្លួន និងការរំលាយគណបក្សសង្គ្រោះជាតិ។

### ៤.៣. បរាជ័យនៃបដិវត្តន៍ពណ៌នៅកម្ពុជា

បដិវត្តន៍ពណ៌បានកើតមានឡើងនៅកម្ពុជាពិតប្រាកដ តាមរយៈផែនការគ្រោងទុក សកម្មភាពនានា សេចក្តីថ្លែងការណ៍ ទង្វើខុសច្បាប់។ល។ គម្រោងការរៀបចំធ្វើបដិវត្តន៍ពណ៌ផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ បានកើតឡើងអស់រយៈពេលជាច្រើនឆ្នាំមកហើយ ដោយសាររាជរដ្ឋាភិបាលបានដឹកនាំប្រទេស ដោយឯករាជ្យនិងមិនបម្រើនយោបាយរបស់បរទេស តែឈរលើគោលការណ៍ស្មើភាពនិងផលប្រយោជន៍ទៅវិញទៅមក។ ជាមួយគ្នានេះដែរ ការប្រកួតប្រជែងរបស់គណបក្សប្រឆាំង ដើម្បីឡើងដឹកនាំប្រទេសតាមរយៈការបោះឆ្នោត ទទួលបរាជ័យជាបន្តបន្ទាប់ ដោយហេតុថារាជរដ្ឋាភិបាលដឹកនាំប្រទេសតាមទិសដៅត្រឹមត្រូវ និងមានការអភិវឌ្ឍដោយគិតគូរផលប្រយោជន៍ជាតិនិងប្រជាជនជាធំ។ នេះគឺជាមូលហេតុដែលធ្វើឱ្យមេដឹកនាំគណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី ត្រូវបង្ខំចិត្តច្របាច់បញ្ចូលគ្នា ដើម្បីចូលរួមប្រយុទ្ធក្នុងសមរភូមិតែមួយ ក្រោមការរៀបចំរបស់មហាអំណាច

បស្ចិមប្រទេសនិងសម្ព័ន្ធមិត្តរបស់ខ្លួន បើទោះបីជាមេដឹកនាំគណបក្សទាំងពីរ មិនចុះសម្រុងគ្នានិងធ្លាប់វាយប្រហារគ្នាជារឿយៗក៏ដោយ។

ដើម្បីបញ្ជ្រាបមនោគមវិជ្ជា មហាអំណាចបស្ចិមប្រទេសនិងសម្ព័ន្ធមិត្ត បានផ្សព្វផ្សាយទ្រឹស្ដីនៃបដិវត្តន៍ពណ៌ និងវិធីសាស្ត្រនៃការធ្វើបដិវត្តន៍ពណ៌ផ្តួលរំលំរដ្ឋអំណាច។ សៀវភៅស្ដីអំពីបដិវត្តន៍ពណ៌ដែលរៀបរាងដោយអ្នកនិពន្ធដ៏ល្បីល្បាញម្នាក់ ត្រូវបានបកប្រែជាភាសាខ្មែរ និងចែកចាយយ៉ាងទូលំទូលាយនៅទូទាំងប្រទេស ដើម្បីបញ្ជ្រាបការយល់ដឹងអំពីបដិវត្តន៍នេះ ដល់ស្រទាប់មហាជន។

ការបណ្តុះបណ្តាលកម្លាំង សម្រាប់អនុវត្តគម្រោងការបដិវត្តន៍ពណ៌ ត្រូវបានធ្វើឡើងដូចនៅប្រទេសផ្សេងៗ ហើយសង្គមស៊ីវិលនិងអង្គការមិនមែនរដ្ឋាភិបាល ដែលទទួលហិរញ្ញវត្ថុពីប្រទេសមហាអំណាចនិងសម្ព័ន្ធមិត្ត បានធ្វើសកម្មភាពដោយចំហ ក្រោមលេសជំរុញលទ្ធិប្រជាធិបតេយ្យនិងលើកកម្ពស់សិទ្ធិមនុស្ស តែជាតុពិតសកម្មភាពទាំងនេះ គឺជាការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជា តាមរយៈការជួយជ្រោមជ្រែងដល់គណបក្សប្រឆាំងក្នុងការរៀបចំកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រ និងផ្តល់មធ្យោបាយហិរញ្ញវត្ថុ ដើម្បីឈានទៅផ្តួលរំលំរដ្ឋអំណាចស្របច្បាប់។ អង្គការទាំងនេះបានសហការយ៉ាងជិតស្និទ្ធជាមួយថ្នាក់ដឹកនាំគណបក្សប្រឆាំង និងសកម្មជនដែលបានទទួលការបណ្តុះបណ្តាល ដើម្បីអនុវត្តគម្រោងការនេះ ឱ្យបានរលូននិងស៊ីសង្វាក់។ ជាក់ស្តែង នៅក្នុងកំលុងពេលបាតុកម្មឆ្នាំ២០១៣-២០១៤ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានដឹកនាំបញ្ជាកម្លាំងបាតុកម្មនៅក្បែរទីលានប្រជាធិបតេយ្យ ពិនិត្យ វិភាគស្ថានការណ៍បាតុកម្មនិងរិះរកមធ្យោបាយឱ្យបាតុកម្មទទួលបានជោគជ័យ។




*រូបភាពទី៩៖ ក្រុមយុវជនអតីតគណបក្សសង្គ្រោះជាតិទៅបណ្តុះបណ្តាលនៅឥណ្ឌូណេស៊ី ដោយ CANVAS*

មុនបាតុកម្មទ្រង់ទ្រាយធំថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៣ ថ្នាក់ដឹកនាំនិងសកម្មជនគណបក្សប្រឆាំង ធ្លាប់ទទួលបានការបណ្តុះបណ្តាលពី CANVAS អំពីយុទ្ធសាស្ត្រ និងយុទ្ធវិធីធ្វើបាតុកម្ម និងកុបកម្ម។ នៅដើមខែមករា ឆ្នាំ២០១៥ CANVAS បានជួយបណ្តុះបណ្តាលយុវជនជាសកម្មជនគណបក្សប្រឆាំង ១៥នាក់ នៅប្រទេសឥណ្ឌូណេស៊ី ដើម្បីរៀបចំធ្វើបាតុកម្មជាបន្តបន្ទាប់ និងគម្រោងធ្វើបាតុកម្មឆ្នាំ២០១៨។

គណបក្សសង្គ្រោះជាតិ បានរៀបចំបណ្តុះបណ្តាលយុវជន ដែលមានចរិតនិងឥរិយាបថជ្រុលនិយមដើម្បីវាយប្រហាររាជរដ្ឋាភិបាល ប្រើសម្តីអសីលធម៌លើថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា និងត្រៀមអុកឡុកនៅថ្ងៃបោះឆ្នោត និងក្រោយថ្ងៃបោះឆ្នោត។ យុវជនទាំងនេះបានទទួលការបណ្តុះបណ្តាលពីជំនាញការបរទេស ដែលមានបទពិសោធធ្វើបដិវត្តន៍ពណ៌នៅតំបន់មួយចំនួនដូចជា អឺរ៉ុបខាងកើត មជ្ឈិមបូព៌ា និងអាស៊ី ដើម្បីឱ្យពួកគេដឹកនាំធ្វើសកម្មភាពប្រឆាំងនឹងរាជរដ្ឋាភិបាល ដោយកៀរគរយុវជន កម្មករ និងសកម្មជនចូលរួមធ្វើបាតុកម្មដោយអហិង្សា និងឈានទៅរកអំពើហិង្សាជាបន្តបន្ទាប់។ យុវជនខ្លះមានចរិតច្រឡោងខាម និងប្រើពាក្យសម្តីអសុរោះ ជៀលត្មេះថ្នាក់ដឹកនាំ ហើយស្រែកដេរថា ផ្តាច់ការ គ្មានលទ្ធិប្រជាធិបតេយ្យ និងគ្មានការ

គោរពសិទ្ធិមនុស្ស នៅតាមទីសាធារណៈនិងលើបណ្ដាញសារព័ត៌មានសង្គម ដោយចេញមុខ។ **ប្រសិនបើកម្ពុជាផ្ដាច់ការ គ្មានការគោរពសិទ្ធិមនុស្ស និងគ្មានលទ្ធិប្រជាធិបតេយ្យមែន តើក្រុមយុវជនពាលទាំងនេះអាចប្រើពាក្យសម្ដីអសីលធម៌ និងប្រមាថមាក់ងាយថ្នាក់ដឹកនាំ ដែលត្រូវបានប្រជាពលរដ្ឋភាគច្រើនគោរពស្រឡាញ់បានដោយសេរី និងចំហបែបនេះ បានដែរឬទេ?** ទង្វើទាំងនេះកើតចេញពីមនោគមវិជ្ជារបស់មេដឹកនាំគណបក្សប្រឆាំង ដែលប្រកាន់យកនូវការភូតកុហក បំផ្លើសនិងបំភ្លៃការពិត ឈានទៅញុះញង់ឱ្យមានទំនាស់ផ្ទៃក្នុងជាតិសាសន៍ និងការប្រកាន់ពូជសាសន៍ ប៉ុន្ដែអំពើទាំងនោះ ក៏ត្រូវបានរាជរដ្ឋាភិបាលចាត់វិធានការទប់ស្កាត់បានជាបន្តបន្ទាប់ ដើម្បីពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។

ជារឿយៗ មេដឹកនាំគណបក្សប្រឆាំងតែងតែលើកឡើង ឬបញ្ចេញសារនយោបាយ អំពីជោគជ័យនៃការធ្វើបដិវត្តន៍ពណ៌ នៅប្រទេសនេះឬនៅប្រទេសនោះ ទាំងមុននិងក្រោយពេលបោះឆ្នោត។ ជាក់ស្ដែង សម រង្ស៊ី និយាយអំពីបដិវត្តន៍ពណ៌ នៅទុយណេស៊ី ហ្វីលីពីន លីប៊ី យេម៉ែន អេហ្ស៊ីប ស៊ីរី ជាដើម ចំណែក កឹម សុខា និយាយអំពីការយកគំរូតាមបដិវត្តន៍ពណ៌នៅយូហ្គោស្លាវី។ សារនយោបាយទាំងនេះ គឺជាផែនការបញ្ជ្រាបការយល់ដឹងអំពីព្រឹត្តិការណ៍ដែលកើតមាននៅប្រទេសទាំងនោះ និងដើម្បីបន្សាំសភាពការណ៍ ឱ្យសកម្មជននិងអ្នកគាំទ្រខ្លួន ត្រៀមយកគំរូតាមចលនានេះអនុវត្តនៅកម្ពុជា ក្នុងក្ដីសង្ឃឹមថា បុព្វហេតុរបស់ពួកគេនឹងទទួលបានជោគជ័យ។

ដោយមានផែនការច្បាស់លាស់ ហេតុដូច្នេះទើបគណបក្សប្រឆាំង បានឃុបឃិតជាមួយវិទ្យាស្ថាន NDI និងអង្គការ COMFREL ដើម្បីប្រឌិតទិន្នន័យថា អ្នកបោះឆ្នោតជាង១លាននាក់ពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ចំណែកគណបក្សប្រឆាំង បានបដិសេធមិនព្រមចូលរួមសង្កេតការណ៍ ក្នុង

ដំណើរការចុះឈ្មោះអ្នកបោះឆ្នោត សម្រាប់ការបោះឆ្នោតឆ្នាំ២០១៣ ទេ ដែលជាឧបាយកលព្រមគ្នានិងមានភាពស៊ីសង្វាក់គ្នា។ ទោះបីជាពេលវេលា នៃការបោះឆ្នោតមិនទាន់មកដល់ក៏ដោយ ក៏មេដឹកនាំគណបក្សប្រឆាំងតែងតែ ប្រកាសថា គ.ជ.ប. មិនមានតម្លាភាព និងលម្អៀងទៅគណបក្សប្រជាជនកម្ពុជា ហើយការបោះឆ្នោតពុំមានលក្ខណៈសេរី យុត្តិធម៌ និងត្រឹមត្រូវ ដូច្នេះខ្លួននឹង មិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតទេ។ ការថ្លែងរបស់មេដឹកនាំប្រឆាំង នៅពេលមិនទាន់បានដឹងអំពីលទ្ធផលនៃការបោះឆ្នោតនៅឡើយផងនោះ គឺ មានគោលបំណងតែមួយគត់ ដើម្បីបង្កើតលេសថា លទ្ធផលនៃការបោះឆ្នោត នេះមិនមានយុត្តិធម៌និងមានការលួចបន្លំ នៅពេលដែលគណបក្សខ្លួនចាញ់ឆ្នោត។

ចលនាបដិវត្តន៍ពណ៌បានវាយប្រហារព្រមៗគ្នា លើគ្រប់បញ្ហាសង្គម ដែលមានលក្ខណៈរសើប ដូចជាបញ្ហាដីធ្លីជាដើម។ ករណីដីធ្លីក្នុងតំបន់បឹងកក់ ត្រូវបានក្រុមបាតុករពី២០ទៅ៣០នាក់ តាំងខ្លួនជាជនរងគ្រោះដែលភាគច្រើន មិនមែនជាម្ចាស់លំនៅដ្ឋាននៅតំបន់បឹងកក់នេះទេ ប៉ុន្តែជាតុពិត ពួកគេ ជាសកម្មជន ឬជាអ្នកដែលមានការពាក់ព័ន្ធនឹងគណបក្សប្រឆាំង ដែលតាំង ខ្លួនថាជាអ្នកការពារសិទ្ធិមនុស្សនៅតំបន់បឹងកក់។ ជាក់ស្តែង ករណីលោកស្រី យ៉ោម បុប្ផា ដែលជាសកម្មជនដីធ្លីនៅតំបន់បឹងកក់ម្នាក់នៅក្នុងចំណោម សកម្មជនទាំងនោះ ជាស្រីកំណាន់របស់អតីតតំណាងរាស្ត្រគណបក្សប្រឆាំង រៀល ខេមរិន្ទ្រ។ ទណ្ឌិត ទេព វន្នី ត្រូវបានបំពាក់មេដាយថ្នាក់ដឹកនាំសកល ដើម្បីលើកទឹកចិត្តឱ្យក្លាហានថែមទៀត ក្នុងការរៀបចំក្បួនបាតុកម្ម ដើម្បីតវ៉ា ប្រឆាំងរាជរដ្ឋាភិបាល មិនគ្រាន់តែលើបញ្ហាដីធ្លីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង រាលដាលដល់បញ្ហាផ្សេងៗទៀត ក្រោមលេសសិទ្ធិមនុស្ស។ នៅពេលធ្វើ បាតុកម្មថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ ទណ្ឌិត ទេព វន្នី និងសហការីបាន ដង្ហែរក្បួនបាតុកម្មដោយសម្រុកចូលសាលារាជធានីភ្នំពេញ ហើយបានដេរ

ប្រមាថមន្ត្រីរាជការ និងបង្កអំពើហិង្សាលើមន្ត្រីសាលារាជធានីភ្នំពេញ២នាក់ រហូតដល់បែកក្បាលហូរឈាម។

សារព័ត៌មានគាំទ្រគណបក្សប្រឆាំងទាំងក្នុងនិងក្រៅប្រទេស ត្រូវបាន រៀបចំប្រមូលផ្តុំគ្នាជាបណ្តាញ និងធ្វើការផ្សព្វផ្សាយព័ត៌មានប្រឌិតបំផ្លើស និងវាយប្រហារប្រព័ន្ធបោះឆ្នោត និង គ.ជ.ប. ដោយបញ្ជ្រាបព័ត៌មានមិនពិត ដល់មហាជន តាមរយៈបណ្តាញព័ត៌មានសង្គមនិងឧបករណ៍បំប៉ោងសំឡេង ដែលមាននិន្នាការប្រឆាំង។ សារព័ត៌មានទាំងនេះបានធ្វើយុទ្ធនាការឃោសនា យ៉ាងសកម្ម និងទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីប្រទេសមហាអំណាច ដើម្បីឱ្យមហាជនយល់ច្រឡំថា ជ័យជំនះរបស់គណបក្សប្រជាជនកម្ពុជា បានមកដោយសារការលួចបន្លំសន្លឹកឆ្នោត។



*រូបភាពទី១០៖ អំពើហិង្សានៅស្ពានអាកាលក្បាលថ្នល់*

ប្រព័ន្ធផ្សព្វផ្សាយទាំងនេះ បានធ្វើសកម្មភាពឃោសនាក្រោមរូបភាព លទ្ធិប្រជាធិបតេយ្យ សេរីភាពនៃសារព័ត៌មាន និងសេរីភាពក្នុងការបញ្ចេញមតិ យោបល់ ដោយធ្វើការផ្សព្វផ្សាយព័ត៌មានមិនពិតនិងប្រឌិត ក្នុងចេតនាបញ្ឆេះ

កំហឹងប្រជាពលរដ្ឋឱ្យស្អប់របបគ្រប់គ្រង ជំរុញបាតុករហ៊ានប្រឆាំងតទល់យ៉ាងមោះមុតជាមួយរដ្ឋអំណាច និងបន្សាបអំណាចរបស់រដ្ឋ។

បន្ទាប់ពីបានដឹងលទ្ធផលបោះឆ្នោត មេដឹកនាំគណបក្សប្រឆាំងបានអំពាវនាវឱ្យសកម្មជនរបស់ខ្លួនធ្វើមហាបាតុកម្មអហិង្សា ដូចផែនការដែលពួកគេបានរៀបចំ ដើម្បីតវ៉ាចំពោះលទ្ធផលនៃការបោះឆ្នោត ដោយចោទថា គ.ជ.ប. និងគណបក្សប្រជាជនកម្ពុជា លួចបន្លំសន្លឹកឆ្នោត។ ការកៀរគរកម្លាំងសកម្មជនដើម្បីរៀបចំព្រឹត្តិការណ៍បាតុកម្មទ្រង់ទ្រាយធំ បានចាប់ផ្តើមចេញពីចំណុចអហិង្សា ហើយឈានទៅដល់ការបិទផ្លូវ ការស្រែកតិះដៀលដល់រដ្ឋអំណាច ការរើសអើងជាតិសាសន៍ និងការទាមទាររកយុត្តិធម៌សង្គមដែលបាននាំទៅដល់អំពើហិង្សានៅគល់ស្ពានក្បាលថ្នល់ និងរោងកុនលុច្ស ជាពិសេស នៅសួនឧស្សាហកម្មកាណាឌីយ៉ា និងនៅក្បែរស្ពាននាគ។ ជាជំហានៗ បាតុកម្មមួយសប្តាហ៍ម្តងបានប្រែក្លាយទៅជាបាតុកម្មរាល់ថ្ងៃ ដែលធ្វើឱ្យមានភាពវឹកវរ ការភ័យខ្លាច អស្ថិរភាពនយោបាយ រំខានដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ សារនយោបាយខ្លីៗរបស់គណបក្សប្រឆាំង ដែលពង្វក់បាតុករគឺ «ដូរមិនដូរ? ដូរ!» «ពួកអាក្បាលយួន ខ្លួនខ្មែរ» «គណបក្សប្រជាជនកម្ពុជាឈ្នះក៏ចាញ់ ចាញ់ក៏ចាញ់» «ហ៊ុន សែន អើយ ចុះចេញទៅ!»។ល។

គណបក្សប្រឆាំងបានបោះទីតាំង និងកាន់កាប់ជាប្រចាំនៅទីលានប្រជាធិបតេយ្យ ដើម្បីងាយស្រួលក្នុងការប្រមូលនិងចល័តកម្លាំង ដើរហែរជាក្បួនធ្វើបាតុកម្មតាមដងផ្លូវ និងបញ្ជូនកម្លាំងទៅតាមគោលដៅដែលបានគ្រោងធ្វើបាតុកម្ម។ មេដឹកនាំគណបក្សប្រឆាំងបានអំពាវនាវដល់ប្រជាពលរដ្ឋ មន្ត្រីរាជការ កម្មករ កម្មការិនី កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ម្តងហើយម្តងទៀតឱ្យក្រោកឈរឡើងបះបោរប្រឆាំងនឹងរាជរដ្ឋាភិបាល ដោយសន្យាថានឹងផ្តល់ប្រាក់បៀវត្សក្នុងកម្រិតមួយដ៏ខ្ពស់ហួសហេតុ។ ក្រុមនេះក៏បានប្រឌិតរឿង

កុហក ដូចជា «ប្រសិនបើលោក **ហ៊ុន សែន** នៅបន្តកាន់អំណាច៤-៥ឆ្នាំទៀត ទឹកដីកម្ពុជានឹងក្លាយជាផ្នែកមួយរបស់វៀតណាមហើយ។ លោក **ហ៊ុន សែន** គ្រោងនឹងចុះចេញពីតំណែងនៅថ្ងៃស្អែក ប៉ុន្តែយួនដឹងទាន់ ហៅទៅចាក់ថ្នាំ ហើយពេលត្រឡប់មកវិញ ស្រាប់តែឈប់លាលែងពីនាយករដ្ឋមន្ត្រី» ជាដើម។

អង្គការសង្គមស៊ីវិល ដែលមាននិន្នាការប្រឆាំង និងឃុបឃិតជាមួយគណបក្សសង្គ្រោះជាតិ ក្នុងការរៀបចំចលនាបដិវត្តន៍ពណ៌ បានចងក្រងគ្នាជាបណ្ដាញប្រទាក់ក្រឡា ដើម្បីធ្វើសកម្មភាពដោយសម្ងាត់ឬចំហព្រមៗគ្នាវាយប្រហារដោយប្រយោលឬផ្ទាល់លើរាជរដ្ឋាភិបាល។ ដើម្បីក្ដាប់បាននូវសភាពការណ៍ សម្របសម្រួលការងារជាមួយមេដឹកនាំនិងសកម្មជនគណបក្សប្រឆាំង និងរៀបចំផែនការនិងយុទ្ធសាស្ត្រងាយស្រួល ក្រុមអង្គការទាំងនេះបង្កើតអង្គការចាត់តាំងមួយ ដែលជាទីបញ្ជាការ ដោយដាក់ឈ្មោះថា «**បន្ទប់ស្ថានការណ៍កម្ពុជា**»។ **តើអង្គការទាំងនេះបង្កើតបន្ទប់ស្ថានការណ៍កម្ពុជាដើម្បីអ្វី? តើទង្វើនេះមានពាក់ព័ន្ធនឹងនយោបាយឬទេ?**

គម្រោងការមួយរបស់ក្រុមប្រឆាំង គឺជំរុញឱ្យក្រុមបាតុករចូលវាយកម្ទេចតូបលក់មាសនិងតូបលក់របស់មានតម្លៃផ្សេងៗ នៅតាមផ្សារ ដើម្បីអុកឡុក បង្កចលាចល និងលួចទ្រព្យសម្បត្តិនិងទំនិញរបស់ប្រជាពលរដ្ឋក្នុងគោលដៅរុញច្រានប្រទេសឱ្យធ្លាក់ចូលក្នុងស្ថានភាពវឹកវរ អនាធិបតេយ្យ និងមានការបង្ហូរឈាម ប្រសិនបើរាជរដ្ឋាភិបាលមិនអាចទប់ស្កាត់បានទាន់ពេលវេលា។

គណបក្សប្រឆាំង បានបង្កអុកឡុកនិងបង្កើតឱ្យមានភាពអនាធិបតេយ្យតាមរូបភាពផ្សេងៗ ដែលធ្វើឱ្យប៉ះពាល់ដល់ការបំពេញភារកិច្ចនិងការអនុវត្តច្បាប់របស់សមត្ថកិច្ច យកកម្លាំងមហាជនដើម្បីតទល់នឹងសមត្ថកិច្ច ក៏ដូចជាញុះញង់ឱ្យបាតុករមានទស្សនៈថា ពួកគេរស់នៅដោយគ្មានយុត្តិធម៌និង

ក្រោមអំណាចផ្តាច់ការ ក្នុងគោលដៅបន្សាបអំណាចរដ្ឋ និងមិនឱ្យអនុវត្ត ប្រកបដោយប្រសិទ្ធភាព។ សកម្មភាពរបស់គណបក្សប្រឆាំងមានលក្ខណៈ ប្រទាក់ក្រឡានិងស៊ីសង្វាក់គ្នា ជាមួយអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដោយមានការរៀបចំសម្របសម្រួល និងមានក្បាលម៉ាស៊ីនដឹកនាំអនុវត្ត ច្បាស់លាស់ មានមធ្យោបាយហិរញ្ញវត្ថុគ្រប់គ្រាន់ និងមានការជួយជ្រោមជ្រែង ពីបរទេស។

ទោះបីជាចលនាបដិវត្តន៍ពណ៌បានបរាជ័យ ហើយក្រុមសមាជិកសភា គណបក្សប្រឆាំងបានចូលរដ្ឋសភាក៏ដោយ ក៏បដិវត្តន៍ពណ៌មិនទាន់បាន បញ្ចប់នៅឡើយទេ ពីព្រោះក្រុមប្រឆាំងនិងសកម្មជនទាំងនេះ នៅតែចិញ្ចឹម មហិច្ឆតាបន្តធ្វើបដិវត្តន៍ពណ៌តទៅទៀត តាមរូបភាពផ្សេងៗ។ ដើម្បីបន្ត អនុវត្តផែនការផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ នៅពេលបោះឆ្នោតឆ្នាំ២០១៨ ខាងមុខ គណបក្សប្រឆាំងបានធ្វើសកម្មភាពនិងរៀបចំយុទ្ធសាស្ត្រមួយ ចំនួន ដូចជា (១) បណ្តុះបណ្តាលយុវជនអំពីវិធីសាស្ត្រផ្តួលរំលំរដ្ឋអំណាច ស្របច្បាប់ (២) ឃុបឃិតជាមួយអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បន្ត រៀបចំយុទ្ធសាស្ត្រផ្តួលរំលំរបបដឹកនាំ (៣) ពន្យុះនិងពង្វក់យុវជនឱ្យដេរ ប្រមាថថ្នាក់ដឹកនាំ ដើម្បីបន្សាបកិត្តិយស ប្រជាប្រិយភាព និងបាត់បង់ការ គោរពពីប្រជាពលរដ្ឋមួយចំនួន (៤) បន្តឃោសនារើសអើងពូជសាសន៍ (៥) បន្តវាយប្រហារតាមបណ្តាញទំនាក់ទំនងសង្គម ដោយប្រឌិតព័ត៌មាន អវិជ្ជមានផ្សេងៗ (៦) រៀបចំផែនការផ្ញើសារទៅអ្នកបោះឆ្នោត នៅថ្ងៃជិត បោះឆ្នោតថា «គណបក្សសង្គ្រោះជាតិឈ្នះការបោះឆ្នោតឆ្នាំ២០១៨» និង ថា «គណបក្សប្រជាជនកម្ពុជាលួចសន្លឹកឆ្នោត» ក្នុងករណីដែលគណបក្ស ប្រឆាំងចាញ់ឆ្នោត (៧) ការផ្សព្វផ្សាយព័ត៌មានប្រឌិត តាមបណ្តាញទំនាក់ ទំនងសង្គម ថាមានជនជាតិវៀតណាមចាប់ក្មេងវះយកគ្រលៀន ដែលធ្វើឱ្យ

ប្រជាជនភ័យជ្រួលច្របល់ទូទាំងប្រទេស (៨) អនុវត្តចលនាបដិវត្តន៍ពណ៌ជាបន្តបន្ទាប់តាមរូបភាពផ្សេងៗ ដូចជា បដិវត្តន៍ផ្កាឈូក បដិវត្តន៍បៃតង យុទ្ធនាការ ថ្ងៃច័ន្ទពណ៌ខ្មៅ និងយុទ្ធនាការថ្ងៃអាទិត្យពណ៌ស ជាដើម។




*រូបភាពទី១១៖ ទម្រង់នៃការធ្វើបដិវត្តន៍ពណ៌របស់ក្រុមប្រឆាំង*

ផែនការនិងចលនានៃបដិវត្តន៍ពណ៌ ត្រូវបានទទួលបរាជ័យ ហើយកម្ពុជាបានចៀសផុតពីការបង្ហូរឈាម ដោយសារកត្តាមួយចំនួន (១) ក្បាលម៉ាស៊ីនដឹកនាំរបស់គណបក្សប្រជាជនកម្ពុជានិងរាជរដ្ឋាភិបាល មានសាមគ្គីភាពរឹងមាំ និងមានការទទួលខុសត្រូវរួមគ្នាចំពោះជោគវាសនារបស់ប្រទេសជាតិនិងប្រជាជន (២) មានការគាំទ្រយ៉ាងទូលំទូលាយពីប្រជាពលរដ្ឋ ទោះបីជាប្រជាពលរដ្ឋមួយចំនួន មិនបានបោះឆ្នោតឱ្យគណបក្សប្រជាជនកម្ពុជាក៏ដោយ ប៉ុន្តែពួកគេមិនគាំទ្រនូវទង្វើបំផ្លិចបំផ្លាញជាតិ របស់គណបក្សសង្គ្រោះជាតិនោះទេ (៣) កងកម្លាំងប្រដាប់អាវុធបានគាំទ្ររាជរដ្ឋាភិបាល ហើយបានក្លាយជាកម្លាំងស្នូលនៃការការពាររដ្ឋធម្មនុញ្ញ និងរាជរដ្ឋាភិបាល ព្រមទាំងការពាររាល់សមិទ្ធផលរបស់រាជរដ្ឋាភិបាល (៤) រាជរដ្ឋាភិបាលមាន

សមត្ថភាពគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងស្ថានភាពម៉ាក្រូសេដ្ឋកិច្ចបានល្អប្រសើរ ទោះបីជាក្នុងស្ថានភាពដ៏លំបាកនៅក្នុងពេលមានបាតុកម្មអូសបន្លាយរយៈពេលយូរ ដែលមានចរិតលក្ខណៈចលនាបដិវត្តន៍ពណ៌ក៏ដោយ (៥) ព្រះមហាក្សត្រ អនុវត្តតាមព្រះរាជតួនាទី ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់ឱកាសឱ្យរាជរដ្ឋាភិបាល ទប់ទល់បាននូវរាល់ទង្វើ ដែលមានចរិតបំផ្លិចបំផ្លាញជាតិ និងសកម្មភាពបង្ហូរឈាម ដែលជាផលវិបាកនៃចលនាបដិវត្តន៍ពណ៌។

ដើម្បីទប់ស្កាត់មហិច្ឆតារបស់ក្រុមគណបក្សប្រឆាំង ក្នុងការកំណត់យកឆ្នាំ២០១៨ គឺជាគោលដៅផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ រាជរដ្ឋាភិបាលបានចាត់វិធានការផ្លូវច្បាប់ ចំពោះក្រុមគណបក្សប្រឆាំងនេះនៅឆ្នាំ២០១៧ ដែលជាវិធានការដ៏ត្រឹមត្រូវក្នុងការទប់ស្កាត់ចលនាបដិវត្តន៍ពណ៌ និងបញ្ចៀសបាននូវការបង្ហូរឈាម។ បច្ចុប្បន្ន ចលនាបដិវត្តន៍ពណ៌នេះនៅមាននៅឡើយ ហើយរាជរដ្ឋាភិបាលកំពុងតាមដានយ៉ាងយកចិត្តទុកដាក់ ដើម្បីចាត់វិធានការផ្លូវច្បាប់និងមិនអនុញ្ញាតឱ្យចលនានេះ កកើតឡើងវិញជាដាច់ខាត។

## ៥. ការពង្រឹងនីតិរដ្ឋ និងការធានាសណ្តាប់ធ្នាប់សង្គម

រាជរដ្ឋាភិបាលធានាឱ្យបាននូវសន្តិសុខ សុវត្ថិភាពសង្គម និងបរិយាកាសល្អសម្រាប់ការអភិវឌ្ឍជាតិ តាមរយៈការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព និងការលើកតម្កើងតម្លៃនៃអំណាចរដ្ឋ។ ដូច្នេះ រាល់អំពើទាំងឡាយណា ដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរ ដល់សន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម សន្តិសុខជាតិ និងទំនាក់ទំនងការទូត ព្រមទាំងញុះញង់ឱ្យមានការរើសអើងជាតិសាសន៍ និងបញ្ឆេះកំហឹងមហាជន គឺត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។ កន្លងមក មេដឹកនាំគណបក្សប្រឆាំង សកម្មជន និងតួអង្គពាក់ព័ន្ធមួយចំនួន

បានប្រព្រឹត្តសកម្មភាពរំលោភច្បាប់ ដែលជាការបង្កគ្រោះមហន្តរាយធ្ងន់ធ្ងរដល់សង្គមជាតិទាំងមូល ដូចជា៖

- សម រង្ស៊ី បានប្រព្រឹត្តអំពើល្មើសច្បាប់ រួមមាន (១) ការដកតម្រុយបង្គោលព្រំដែនលេខ១៨៥ រវាងកម្ពុជានិងវៀតណាម (២)ការក្លែងបន្លំខ្លឹមសារនៃឯកសារសាធារណៈ (៣) ការចោទឯកឧត្តម ហោ ណាំហុង ថា ជាប្រធានគុកបឹងត្របែក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (៤) ការសមគំនិតដោយអនុញ្ញាតឱ្យឈ្មោះ ហុង សុខហួរ ប្រើគណនី Facebook ផ្លូវការរបស់ សម រង្ស៊ី ដើម្បីបង្ហោះខ្លឹមសារក្លែងក្លាយនៃកិច្ចព្រមព្រៀងព្រំដែន រវាងរដ្ឋាភិបាលកម្ពុជានិងវៀតណាម ឆ្នាំ១៩៧៩ (៥) ការប្រឌិតរឿងថា តុលាការរដ្ឋកម្ពុជាបានកាត់ទោសប្រហារជីវិត **សម្តេចព្រះនរោត្តម សីហនុ** ជាជនក្បត់ជាតិ (៦) ការចោទថាការបាញ់សម្លាប់លោក កែម ឡី គឺជាអំពើឃាតកម្មរៀបចំដោយរដ្ឋអំណាច (៧) ការញុះញង់ឱ្យប្រជាពលរដ្ឋនិងកងកម្លាំងប្រដាប់អាវុធបះបោរប្រឆាំងនឹងរបបគ្រប់គ្រង និង (៨) ការញុះញង់ឱ្យមានការរើសអើងជាតិសាសន៍។ល។

- ទណ្ឌិត មាជ សុវណ្ណារ៉ា និងគូកន បានប្រព្រឹត្តអំពើហិង្សានៅក្បែរស្ពាននាគ ដែលបណ្តាលឱ្យកម្លាំង រក្សាសណ្តាប់ធ្នាប់សាធារណៈទទួលរងរបួសចំនួន៣៩នាក់។

- លោក អ៊ុំ សំអាន បានបង្ហោះផ្សព្វផ្សាយផែនទីក្លែងក្លាយព្រំដែនកម្ពុជា-វៀតណាមជាសាធារណៈ នៅលើ Facebook Page ឈ្មោះ UM SAM AN និងចោទរាជរដ្ឋាភិបាលថា បានប្រើប្រាស់ផែនទីក្លែងក្លាយ ព្រមទាំងបានញុះញង់ឱ្យមានការរើសអើងជាតិសាសន៍។

- ក្រៅពីករណីដូចមានរៀបរាប់ខាងលើនេះ មេដឹកនាំ និងសកម្មជនគណបក្សប្រឆាំង បានប្រព្រឹត្តអំពើល្មើសច្បាប់ មានដូចជា ការជេរប្រមាថ និងការបង្កប្លួសស្នាមលើមន្ត្រីសាធារណៈ ការសូកប៉ាន់សាក្សី និងការបរិហារកេរ្តិ៍លើថ្នាក់ដឹកនាំរាជរដ្ឋាភិបាល។ល។

ពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញនិងគោរពច្បាប់។ លទ្ធិប្រជាធិបតេយ្យអាចកើតមាននៅពេលដែលប្រទេសមានស្ថិរភាពនយោបាយ សន្តិភាព និងមានការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព ចំណែកប្រជាពលរដ្ឋត្រូវមានការយល់ដឹងអំពីច្បាប់និងគោរពច្បាប់។ ទង្វើរបស់មេដឹកនាំនិងសកម្មជនរបស់គណបក្សប្រឆាំង ដូចមានរៀបរាប់ខាងលើ គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ លើច្បាប់និងរដ្ឋធម្មនុញ្ញ ដែលតម្រូវឱ្យរាជរដ្ឋាភិបាលចាំបាច់ត្រូវចាត់វិធានការតាមផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ ដើម្បីទប់ស្កាត់រាល់សកម្មភាពដែលអាចបង្កឱ្យមានភាពវឹកវរ និងមហន្តរាយដល់សង្គមជាតិ។ ដើម្បីពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ការអនុវត្តច្បាប់គឺជាជម្រើសតែមួយគត់។

## ៦. សកម្មភាពក្រុមប្រឆាំងក្រៅច្បាប់

ដើម្បីសម្រេចបាននូវមហិច្ឆតាឆ្លោះទៅដណ្តើមអំណាច នៅខាងក្រៅប្រទេស ក្រុមប្រឆាំងក្រៅច្បាប់ នៅតែបន្តធ្វើសេចក្តីថ្លែងការណ៍ ដែលមានចរិតជាការប្រឌិតរឿង ការញុះញង់ និងការបំផ្លើស ដោយចោទរាជរដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជា លើបញ្ហាផ្សេងៗ ផ្ទុយពីការពិត។

សម រង្ស៊ី បាននិយាយថា «**ថ្ងៃ ៧ មករា ១៩៧៩ គឺជាឆាកល្ខោនដែលយួនបានរៀបចំទាំងអស់**... យើងត្រូវចងចាំជានិច្ចថា យួនបង្កប់បានញុះញង់ឱ្យខ្មែរកាប់សម្លាប់ខ្មែរគ្នាឯង ក្រោមរបបខ្មែរក្រហម (១៩៧៥-១៩៧៩)...

លោក **ហ៊ុន សែន** បានធ្វើឱ្យប្រទេសកម្ពុជាបាត់បង់ទឹកដីជាច្រើន ដោយសារការចុះហត្ថលេខាលើសន្ធិសញ្ញាព្រំដែនដ៏អាក្រក់ ជាមួយប្រទេសវៀតណាមក្នុងទសវត្សរ៍៨០»។ «នៅស្រុកខ្មែរសុទ្ធតែយួន អ្នកបោះឆ្នោតសុទ្ធតែយួន យួនឈ្លានពានទឹកដីកម្ពុជាមួយថ្ងៃមួយគីឡូម៉ែត្រ»។ ដោយឡែក កឹម សុខា ក៏បាននិយាយដែរថា គុកទួលស្លែងជាកន្លែងសិប្បនិម្មិតដែលបង្កើតឡើងដោយវៀតណាម។ មេដឹកនាំទាំងពីរបានញុះញង់ឱ្យសកម្មជនរបស់បក្សខ្លួនរើសអើងជាតិសាសន៍ និងបញ្ឆេះកំហឹងមហាជនជាមួយជនជាតិវៀតណាម។ **តើសេចក្តីថ្លែងការណ៍របស់មេដឹកនាំគណបក្សប្រឆាំងខាងលើនេះ បានបង្កើតឱ្យមានទំនាក់ទំនងល្អ រវាងកម្ពុជានិងវៀតណាម ដែរឬទេ? តើការរើសអើង ជាតិសាសន៍បែបនេះ បើកើតមានឡើងនៅបស្ចិមប្រទេសមានទោសព្រហ្មទណ្ឌដែរឬទេ? តើបស្ចិមប្រទេសគួរគាំទ្ររាជរដ្ឋាភិបាលកម្ពុជា ក្នុងការទប់ស្កាត់មហន្តរាយបែបនេះ ឬគាំទ្រ សម រង្ស៊ី និង កឹម សុខា ឱ្យបន្តអរិយភាពនយោបាយជាមួយប្រទេសជិតខាង?**

ប្រទេសជាមិត្តនានា បានទទួលស្គាល់និងផ្តល់យុត្តិធម៌ចំពោះការតស៊ូរបស់ប្រជាជនកម្ពុជា ដែលបានរំដោះប្រទេសជាតិពីរបបប្រល័យពូជសាសន៍នាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដែលប្រជាជាតិយើងចាត់ទុកជាថ្ងៃកំណើតទីពីរ។ ប៉ុន្តែដើម្បីអំណាចនិងផលប្រយោជន៍របស់ក្រុមខ្លួន មេដឹកនាំគណបក្សប្រឆាំងហ៊ានធ្វើអ្វីគ្រប់បែបយ៉ាង បំផ្លើស បំភ្លៃការពិត និងប្រឌិតព្រឹត្តិការណ៍ផ្សេងៗ ដើម្បីបញ្ឆេះកំហឹងប្រជាពលរដ្ឋឱ្យប្រឆាំងនឹងស្មារតីថ្ងៃ៧មករា១៩៧៩។ **តើជនបែបនេះសមនឹងក្លាយជាមេដឹកនាំរបស់ប្រទេសមួយដែរឬទេ?**

ទោះបីជាដឹងថាខ្លួនបានប្រព្រឹត្តអំពើផ្ទុយនឹងច្បាប់ក៏ដោយ ក៏ សម រង្ស៊ី នៅតែបន្តអំពាវនាវ ឱ្យកងកម្លាំងប្រដាប់អាវុធក្រោកឈរបែរចុងអាវុធប្រឆាំងនឹងរាជរដ្ឋាភិបាលតាមគណនី Facebook ឈ្មោះ Sam Rainsy ដែល

ព័ត៌មាននេះបានជ្រួតជ្រាបទៅដល់មហាជន និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ។ នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជាចាត់វិធានការផ្លូវច្បាប់ប្រឆាំងនឹងមេដឹកនាំបែបនេះ បែរជាអ្នកនយោបាយខ្មែរនិងបរទេសមួយចំនួនរិះគន់ថា ជាការបំបិទសិទ្ធិសេរីភាពអ្នកនយោបាយ និងប្រើប្រព័ន្ធយុត្តិធម៌ដើម្បីកម្ចាត់អ្នកប្រឆាំង។ **តើនៅបស្ចិមប្រទេស អ្នកនយោបាយអាចធ្វើការអំពាវនាវបែបនេះបានដែរឬទេ?**

ថ្នាក់ដឹកនាំក្រុមប្រឆាំងក្រៅច្បាប់ មិនគ្រាន់តែមិនបានគិតគូរអំពីផលប្រយោជន៍ទូទៅរបស់ប្រជាជន និងប្រទេសជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានអំពាវនាវឱ្យអន្តរជាតិដាក់ទណ្ឌកម្មលើប្រទេសរបស់ខ្លួន ក្នុងពេលដែលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ កំពុងតែត្រូវបានលើកកម្ពស់ជាបណ្ដើរៗ។ ការអំពាវនាវមិនឱ្យមានការដាក់ទុនវិនិយោគពីបរទេស និងឱ្យមានការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ការផ្អាកជំនួយ ការដកភាពអនុគ្រោះពន្ធ ឬការរឹតត្បិតផ្សេងៗ គឺជាទង្វើបំផ្លិចបំផ្លាញជាតិ និងក្បត់ផលប្រយោជន៍ប្រជាជន។

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ កញ្ញា កឹម មនោវិទ្យា បានអំពាវនាវឱ្យតំណាងប្រទេសនៅអង្គការសហប្រជាជាតិ ស្នើទៅអគ្គលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ ដើម្បីបញ្ជូនបេសកកម្មមួយមកកម្ពុជា និងឱ្យគិតគូរឡើងវិញ អំពីសមាជិកភាពរបស់កម្ពុជានៅអង្គការសហប្រជាជាតិ។ នៅក្នុងប្រទេស ក្រុមមេដឹកនាំប្រឆាំងបានបំពានច្បាប់ ភូតកុហក និងប្រឌិតរឿងផ្សេងៗ ហើយនៅលើឆាកអន្តរជាតិក្រុមនេះក៏បានធ្វើដូចគ្នានេះដែរ ដែលធ្វើឱ្យខូចមុខមាត់ប្រទេសជាតិ បន្ទុះបង្អាប់រាជរដ្ឋាភិបាល និងបង្កបរិយាកាសនយោបាយអាប់អួរ។ ការព្យួរឬការបណ្ដេញចេញនៃសមាជិកភាពរបស់កម្ពុជានៅអង្គការសហប្រជាជាតិ អាចធ្វើទៅបានលុះត្រាតែកម្ពុជា បានរំលោភយ៉ាងធ្ងន់ធ្ងរ លើធម្មនុញ្ញអង្គការសហប្រជាជាតិត្រង់មាត្រា៤ ដែល

ចែងអំពីការព្យួរសមាជិកភាព និងត្រង់មាត្រា៥ ដែលចែងអំពីការបណ្ដេញចេញនៃសមាជិកភាព ដែលរំលោភលើគោលការណ៍ណាមួយក្នុងចំណោមគោលការណ៍ទាំង៧នៃមាត្រា២។ ក្នុងនាមជាសមាជិករបស់អង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលកម្ពុជាបានដឹកនាំប្រទេសលើផ្លូវដ៏ត្រឹមត្រូវ ដោយគោរពតាមច្បាប់និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាធម្មនុញ្ញនៃអង្គការសហប្រជាជាតិ។ ដូច្នេះ គ្មានហេតុផលណាមួយដែល កញ្ញា កឹម មនោវិទ្យា ស្នើទៅអង្គការសហប្រជាជាតិ ឱ្យមានការព្យួរឬការបណ្ដេញកម្ពុជាចេញពីសមាជិកភាពរបស់អង្គការសហប្រជាជាតិ។ ទង្វើដ៏អាម៉ាស់បែបនេះគ្រាន់តែជាការបំភ័ន្តសាធារណមតិជាតិនិងអន្តរជាតិ និងបង្ខូចកេរ្តិ៍ឈ្មោះរាជរដ្ឋាភិបាលកម្ពុជាពីសំណាក់ក្រុមប្រឆាំង ដោយមានការឃុបឃិតជាមួយសម្ព័ន្ធមិត្តបរទេស ដែលមិនយល់ឬមិនខ្វល់អំពីគោលការណ៍ច្បាប់ ដែលនេះគឺជាភស្តុតាងយ៉ាងច្បាស់ថា ក្រុមបរទេសទាំងនេះនៅពីក្រោយខ្នងគណបក្សប្រឆាំង ហើយបន្តគាំទ្រក្រុមប្រឆាំងក្រៅច្បាប់នេះ តទៅទៀត។

ថ្មីៗនេះ លោក អេង ឆៃអ៊ាង បានប្រកាសអំពីការបង្កើតចលនាសង្គ្រោះជាតិ ហើយព្រលយពាក្យចលនានេះនឹងទាក់ទងជាសម្ងាត់ជាមួយកងកម្លាំងប្រដាប់អាវុធ។ ទង្វើនេះបញ្ជាក់ថា ក្រុមប្រឆាំងបន្តធ្វើសកម្មភាពសម្ងាត់ ដើម្បីផ្ដួលរំលំរដ្ឋអំណាចស្របច្បាប់។ ជាប្រទេសមានអធិបតេយ្យភាព កម្ពុជាសោកស្ដាយចំពោះប្រទេសមួយចំនួន ដែលបានបន្តគាំទ្រនិងបង្កលក្ខណៈឱ្យក្រុមប្រឆាំងក្រៅច្បាប់នេះធ្វើសកម្មភាពនានា ដើម្បីប្រឆាំងរាជរដ្ឋាភិបាលស្របច្បាប់ ផ្ទុយនឹងគោលការណ៍នៃការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃ ដែលជាគោលការណ៍សំខាន់នៃការអនុវត្តជាអន្តរជាតិ។ ប្រសិនបើគ្មានការលើកទឹកចិត្តពីបរទេសទេ នោះក្រុមបក្សប្រឆាំងក្រៅច្បាប់ទាំងនេះមិនហ៊ានដើរហួសពីខ្សែបន្ទាត់ព្រំដែននៃច្បាប់ទេ។

## ៧. ធម្មានុរូបភាពនៃចំណាត់ការនិងជំហររបស់រាជរដ្ឋាភិបាល

បើទោះបីជាកម្ពុជា ទទួលបានសន្តិភាពពេញលេញក្នុងរយៈពេលជិត២០ឆ្នាំចុងក្រោយនេះក៏ដោយ ក៏ភាពមិនស៊ីសង្វាក់គ្នារវាងគណបក្សនយោបាយនៅកើតមានឡើងជាបន្តបន្ទាប់ ដែលរាជរដ្ឋាភិបាលពុំអាចប្រមូលផ្តុំកម្លាំងសរុបដើម្បីអភិវឌ្ឍប្រទេស ជាពិសេសគឺនៅចន្លោះឆ្នាំ២០១៣-២០១៤ ដែលបង្កឡើងដោយក្រុមប្រឆាំង។ ប្រជាពលរដ្ឋក៏ដូចជាអ្នកវិនិយោគក្នុងស្រុក និងបរទេស ចង់បានកម្ពុជាមួយមានសន្តិភាពនិងស្ថិរភាពនយោបាយពេញលេញ ដែលជាកត្តាចាំបាច់បំផុតក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

ផ្តើមចេញពីការរំលាយគណបក្សសង្គ្រោះជាតិ និងការចោទប្រកាន់ កឹម សុខា អំពីទង្វើក្បត់ជាតិ ដែលបច្ចុប្បន្នករណីនេះកំពុងស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការនោះ បណ្តាប្រទេសនៅអាស៊ីនិងប្រទេសមួយចំនួន នៅអឺរ៉ុបបានប្រកាន់យកជំហរអព្យាក្រឹតនិងមិនលម្អៀង ដោយហេតុថាប្រទេសទាំងនេះបានយល់ដឹងច្បាស់អំពីសភាពការណ៍កម្ពុជា លើកលែងតែសហរដ្ឋអាមេរិក និងសភាអឺរ៉ុបដែលមិនខ្វល់ចំពោះបញ្ហាដែលបានកើតឡើង ហើយបែរជាមានប្រតិកម្មចំពោះការវិវត្តនយោបាយនៅកម្ពុជា។ ប្រតិកម្មនេះ មិនមែនធ្វើឡើងដើម្បីឆ្លើយតបទៅនឹងស្ថានការណ៍ពិតនៅកម្ពុជាទេ ប៉ុន្តែធ្វើឡើងដើម្បីគាំទ្រគណបក្សប្រឆាំងរបស់អ្នកនយោបាយអាមេរិកមួយចំនួន ដោយប្រកាន់ខ្ជាប់នូវជំហរលម្អៀងនិងតែងតែវាយប្រហារលើរាជរដ្ឋាភិបាល អស់រយៈពេលជាច្រើនឆ្នាំមកហើយ។

រាជរដ្ឋាភិបាលកម្ពុជាសង្ឃឹមថា អ្នកនយោបាយបរទេសពាក់ព័ន្ធនានាគួរស្វែងរកព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយពីភាគីពាក់ព័ន្ធ ដើម្បីចៀសវាងផ្អែកលើព័ត៌មានលម្អៀងពីភាគីតែម្ខាង មុននឹងប្រកាន់ជំហរ ឬធ្វើការសម្រេច

ចិត្តណាមួយ លើបញ្ហាកម្ពុជា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាមានការសោកស្ដាយចំពោះការយល់ខុសរបស់បុគ្គល ជាអ្នកនយោបាយអាមេរិកនិងសភាអឺរ៉ុបអំពីដំណើរការលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា ហើយសភាពការណ៍ពិតនៅកម្ពុជា មានដូចខាងក្រោម៖

**៧.១. លទ្ធិប្រជាធិបតេយ្យ**

ការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ត្រូវបានរៀបចំឡើងតាមពេលកំណត់ ហើយប្រជាពលរដ្ឋមានសិទ្ធិពេញលេញក្នុងការបោះឆ្នោតជ្រើសរើសមេដឹកនាំនិងគណបក្សដែលខ្លួនពេញចិត្ត។ រាជរដ្ឋាភិបាលដឹកនាំប្រទេសតាមឆន្ទៈរបស់ប្រជាពលរដ្ឋ ស្ដាប់យោបល់ប្រជាពលរដ្ឋ និងឆ្លើយតបសេចក្ដីត្រូវការរបស់ពួកគាត់។ ប្រជាពលរដ្ឋកម្ពុជាមានសិទ្ធិក្នុងការជ្រើសរើសជំនឿសាសនា ការបញ្ចេញមតិ សិទ្ធិបង្កើតសមាគម អង្គការ រួមទាំងសហជីព និងសិទ្ធិក្នុងការជួបជុំសម្ដែងមតិ តែប្រជាពលរដ្ឋត្រូវមានកាតព្វកិច្ចអនុវត្តសិទ្ធិរបស់ខ្លួនដោយសន្តិវិធី គោរពច្បាប់ និងគោរពសិទ្ធិរបស់អ្នកដទៃ។

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ កម្ពុជាសម្រេចបាននូវសមិទ្ធផលវិជ្ជមានជាច្រើន គួរឱ្យកត់សម្គាល់ រួមទាំងការកសាងនិងពង្រឹងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងការគោរពសិទ្ធិមនុស្ស ដែលបាននិងកំពុងបន្តដំណើរវិវត្តទៅមុខ។ ដើម្បីសម្រេចបាននូវគោលដៅនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់បន្តរៀបចំក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងពង្រឹងការអនុវត្តច្បាប់ជាជំហានៗ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានបើកទូលាយសិទ្ធិសេរីភាព ក្នុងការបញ្ចេញមតិយោបល់និងសិទ្ធិក្នុងការចូលរួមសកម្មភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញ។

កម្ពុជា បានអនុវត្តតាមគោលការណ៍ជាសាកលនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដោយខិតខំលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ ដែល

ជាម្ចាស់ឆ្នោត អំពីការដឹកនាំរដ្ឋនិងសិទ្ធិចូលរួមបោះឆ្នោត ដើម្បីជ្រើសរើសគណបក្សនយោបាយនិងមេដឹកនាំ ដែលខ្លួនពេញចិត្ត ប៉ុន្តែដំណើរការលទ្ធិប្រជាធិបតេយ្យនេះត្រូវផ្សារភ្ជាប់នឹងតថភាពជាក់ស្តែង នៃសង្គមនិងប្រវត្តិសាស្ត្រក៏ដូចជាមរតកនៃសង្គ្រាម។ ក្នុងពេលជាមួយគ្នានេះដែរ អ្នកនយោបាយត្រូវធ្វើជាគំរូសម្រាប់ប្រជាពលរដ្ឋទូទៅ មានសីលធម៌រស់នៅល្អ មានស្មារតីស្នេហាជាតិ និងតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវភូតកុហកនិងបោកប្រាស់ប្រជាពលរដ្ឋ ដើម្បីសម្រេចនូវមហិច្ឆតាចង់បានអំណាចតែប៉ុណ្ណោះនោះទេ។ មេដឹកនាំគណបក្សប្រឆាំង បានប្រើមធ្យោបាយទុច្ចរិតគ្រប់បែបយ៉ាង ដោយជ្រកក្រោមស្លាកលទ្ធិប្រជាធិបតេយ្យ ដើម្បីឈ្នះឆ្នោត ប៉ុន្តែក្នុងពេលទទួលបរាជ័យក្នុងការបោះឆ្នោត ពួកគេបែរទៅអនុវត្តផែនការគ្រោងទុកនៃការផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ តាមបែបបដិវត្តន៍ពណ៌ ដោយបំផ្លាញនូវលទ្ធិប្រជាធិបតេយ្យពិត ដែលកំពុងរីកដុះដាលនៅក្នុងសង្គមកម្ពុជា។ ការញុះញង់ប្រជាពលរដ្ឋឱ្យធ្វើបាតុកម្ម ដោយកុហកថាមានការលួចសន្លឹកឆ្នោត ការបញ្ឆេះកំហឹងប្រជាពលរដ្ឋ ឱ្យស្អប់រាជរដ្ឋាភិបាល ការអំពាវនាវឱ្យប្រជាពលរដ្ឋនិងកងកម្លាំងប្រដាប់អាវុធក្រោកឈរប្រឆាំងរាជរដ្ឋាភិបាល ការបណ្តុះបណ្តាលយុវជនឱ្យដើរប្រមាថថ្នាក់ដឹកនាំ និងការអុចអាលរើសអើងជាតិសាសន៍ ដែលបង្កឡើងដោយគណបក្សសង្គ្រោះជាតិ គឺជាការបំផ្លិចបំផ្លាញលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ផ្ទុយនឹងសេរីភាពនៃការបញ្ចេញមតិ និងការធ្វើសកម្មភាពនយោបាយ។ **តើនេះជាតម្លៃនៃប្រជាធិបតេយ្យដែលបស្ចិមប្រទេសចង់បាននៅកម្ពុជាឬ?**

រាជរដ្ឋាភិបាលកម្ពុជា បន្តកិច្ចខិតខំប្រឹងប្រែងកសាងក្របខ័ណ្ឌច្បាប់ផ្សព្វផ្សាយខ្លឹមសារច្បាប់ និងការអនុវត្តច្បាប់ ឱ្យកាន់តែល្អប្រសើរ ដើម្បីធានាការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ឱ្យបានដល់កម្រិត

ដូចប្រទេសកំពុងអភិវឌ្ឍនានា។ កម្ពុជាត្រូវការពេលវេលាសមស្របមួយ ដើម្បីឱ្យប្រជាពលរដ្ឋ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អ្នកនយោបាយ និងតួអង្គពាក់ព័ន្ធនានាយល់ដឹងអំពីលទ្ធិប្រជាធិបតេយ្យ កាន់តែទូលំទូលាយ។ លទ្ធិប្រជាធិតេយ្យនៅកម្ពុជា មានស្ថានភាពសមស្របទៅនឹងបរិបទដោយឡែករបស់ខ្លួន ដែលជាប្រទេសទើបរួចផុតពីសង្គ្រាម និងការបែកបាក់ផ្ទៃក្នុង ព្រមទាំងមានការវិវត្តទៅមុខប្រសើរជាងប្រទេសមួយចំនួនក្នុងតំបន់ទៀតផង។

## ៧.២. សិទ្ធិមនុស្ស

យោងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ រាជរដ្ឋាភិបាលប្តេជ្ញាគោរពនិងអនុវត្តតាមរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ជាតិ។ រូបវន្តបុគ្គលឬនីតិបុគ្គលទាំងឡាយណា ដែលប្រព្រឹត្តផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញ និងច្បាប់នានា រាជរដ្ឋាភិបាលត្រូវតែចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ដើម្បីធានាឱ្យបាននូវនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។

ក្នុងប្រវត្តិសាស្ត្រ៥០ឆ្នាំចុងក្រោយនេះ ប្រជាជនកម្ពុជាបានឆ្លងកាត់ដំណាក់កាលដ៏ឈឺចាប់ជាច្រើន។ នៅក្នុងកំលុងឆ្នាំ១៩៧០ដល់១៩៧៥ សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកសម្លាប់ប្រជាជនខ្មែរស្លូតត្រង់ប្រមាណ ៥០ម៉ឺននាក់ ដែលពុំមានបស្ចិមប្រទេសណាមួយបានថ្កោលទោស ចំពោះទង្វើរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនេះ និងជួយរកយុត្តិធម៌ជូនអ្នកដែលបានស្លាប់បាត់បង់ជីវិតនិងគ្រួសាររបស់ពួកគេទេ។ លើសពីនេះទៀត ក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ប្រជាពលរដ្ឋកម្ពុជាបានទទួលរងទារុណកម្ម និងការកាប់សម្លាប់អស់ជាង៣លាននាក់។ សម្តេចតេជោ **ហ៊ុន សែន** និងថ្នាក់

ដឹកនាំគណបក្សប្រជាជនកម្ពុជា ដែលបានរំដោះប្រជាជន ឱ្យរួចផុតពីរបប ប្រល័យពូជសាសន៍ ប៉ុល ពត គឺជាអ្នកការពារសិទ្ធិមនុស្សពិតប្រាកដ ផ្ទុយពី បស្ចិមប្រទេសមួយចំនួន ដែលនៅតែគាំទ្រក្រុមឃាតកខ្មែរក្រហម ដើម្បីបន្ត កាប់សម្លាប់ប្រជាជនខ្មែរនៅតាមតំបន់មួយចំនួន ប្រឆាំងនឹងការរស់រានមាន ជីវិតឡើងវិញតាមរយៈការដាក់ទណ្ឌកម្មសេដ្ឋកិច្ចនិងនយោបាយ ធ្វើឱ្យកម្ពុ ជាស្ថិតក្នុងស្ថានភាពឯកោនៅលើឆាកអន្តរជាតិ និងគាំទ្រឱ្យខ្មែរក្រហមឈរ ជាតំណាងកម្ពុជានៅអង្គការសហប្រជាជាតិ ទោះបីជាប្រទេសទាំងនោះមាន ទិន្នន័យដោយឡែកថា ក្រុមនេះបានសម្លាប់ប្រជាជនអស់ជិត២លាននាក់ (ជាក់ស្តែងតួលេខរបស់រដ្ឋកម្ពុជាមានជាង៣លាននាក់) ក៏ដោយ ប៉ុន្តែពួកនេះ នៅតែជាឃាតកដដែល។

**តើនរណាគិតគូរពីបញ្ហាសិទ្ធិរបស់ប្រជាជនកម្ពុជា ដែលបានបាត់បង់ ជីវិត ដោយសារការទម្លាក់គ្រាប់បែករបស់អាមេរិក និងការបាត់បង់ជីវិតក្នុង របបខ្មែរក្រហម និងអ្នកដែលរស់រានមានជីវិតបន្ទាប់ពីរបបខ្មែរក្រហម?**

នៅក្នុងប្រទេស កឹម សុខា និង សម រង្ស៊ី តែងតែយកបញ្ហាព្រំដែន និងជនជាតិវៀតណាម មកធ្វើជាប្រធានបទក្នុងការវាយប្រហាររាជរដ្ឋាភិបាល និងញុះញង់ បញ្ឆេះកំហឹងឱ្យប្រជាពលរដ្ឋរើសអើងជាតិសាសន៍ និងស្អប់ជនជាតិ វៀតណាម ប៉ុន្តែនៅពេលដែលអ្នកទាំងពីរនេះស្ថិតនៅក្នុងបស្ចិមប្រទេស វិញ សេចក្តីថ្លែងការណ៍របស់គេមានការប្រុងប្រយ័ត្ន ដោយចៀសវាងការរើស អើងជាតិសាសន៍ ដោយហេតុថាបញ្ហានេះជារឿងរសើបបំផុត និងជាទង្វើមិន អាចទទួលយកបានទេ នៅក្នុងប្រទេសអភិវឌ្ឍន៍។ នៅពេលយុទ្ធនាការបោះ ឆ្នោតម្តងៗ ក្រុមគណបក្សប្រឆាំងបានប្រើពាក្យសម្តីអសុរោះ ជេរ និងមាក់ងាយ អ្នកគាំទ្រ សមាជិក និងថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា ថាជាយួន ឬ អាយ៉ងយួន ជាដើម។ ដើម្បីកេងចំណេញផ្នែកនយោបាយ កឹម សុខា បាន

ប្រឌិតរឿងថា ទួលស្លែងគឺជាកន្លែងសិប្បនិម្មិតដែលបង្កើតឡើងដោយវៀតណាម ទោះបីជាខ្លួនបានដឹងយ៉ាងច្បាស់ថា ទីនេះគឺជាកន្លែងប្រមូលផ្តុំបញ្ញវន្តជាង ២ម៉ឺននាក់នៅទូទាំងប្រទេស ដាក់គុក ធ្វើទារុណកម្ម និងសួរចម្លើយមុនពេលយកទៅសម្លាប់។ ការថ្លែងបែបនេះបញ្ជាក់យ៉ាងច្បាស់អំពីការភូតកុហក ការរើសអើងជាតិសាសន៍ និងការជំរុញឱ្យមានភាពប្រទូស្តរ៉ាយជាមួយប្រជាជាតិជិតខាង ដែលជាប្រភពនាំឱ្យកើតសង្គ្រាម។ ដូច្នេះ **តើប្រជាពលរដ្ឋដែលបានទៅបោះឆ្នោតឱ្យគណបក្សប្រជាជនកម្ពុជារាប់លាននាក់នោះ គឺជាយួនមែនទេ? ហើយការដែលគណបក្សសង្គ្រោះជាតិបណ្តុះឱ្យប្រជាពលរដ្ឋរើសអើងជាតិសាសន៍បែបនេះ គឺជារឿងត្រឹមត្រូវដែរឬទេ? តើនេះគឺជាការពង្រឹងលទ្ធិប្រជាធិបតេយ្យ ឬការការពារសិទ្ធិមនុស្ស នៅកម្ពុជា ដែរឬទេ?**

សូម្បីតែ កឹម សុខា ខ្លួនឯង ក៏ធ្លាប់បានសារភាពដែរថា យុទ្ធនាការឃោសនានៃការរើសអើងជាតិសាសន៍ ជាមួយវៀតណាម ពុំបានទទួលជោគជ័យក្នុងការបោះឆ្នោត នាពេលកន្លងមកនោះទេ តែនេះជាយុទ្ធសាស្ត្រនយោបាយរបស់ខ្លួន។ ឥរិយាបថរបស់គណបក្សប្រឆាំងជុំវិញការរើសអើងពូជសាសន៍ និងការបណ្តុះគំនិតញុះញង់ឱ្យមានគំនុំជាតិសាសន៍ គឺជាការបំពានយ៉ាងធ្ងន់ធ្ងរ ដល់សិទ្ធិមនុស្សនិងសិទ្ធិសេរីភាពជាមូលដ្ឋាន ផ្ទុយនឹងអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ក្រមព្រហ្មទណ្ឌ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃទៀត។ **ហេតុអ្វីបានជាសហរដ្ឋអាមេរិក សភាអឺរ៉ុប និងអង្គការដែលអះអាងថាជាអ្នកការពារសិទ្ធិមនុស្ស ជាពិសេស អង្គការឃ្លាំមើលសិទ្ធិមនុស្ស និងអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា មិនដែលថ្កោលទោសជាសាធារណៈ ចំពោះអំពើរំលោភសិទ្ធិមនុស្សរបស់គណបក្ស**

**ប្រឆាំង និងទប់ស្កាត់ភាពជ្រុលនិយមរបស់គណបក្សនេះ តែបែរជានៅបន្តគាំទ្រដល់ពួកគេយ៉ាងពេញទំហឹងទៅវិញ ?**

អង្គការសិទ្ធិមនុស្ស ត្រូវមានកាតព្វកិច្ចសហការជាមួយរដ្ឋាភិបាល ជួយបណ្ដុះបណ្ដាលប្រជាពលរដ្ឋ ឱ្យចេះគោរពច្បាប់ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងមិនត្រូវញុះញង់ឱ្យប្រជាពលរដ្ឋដើរចាកពីគន្លងច្បាប់ ដោយយកបញ្ហាសិទ្ធិមនុស្សមកធ្វើជាខែលនោះទេ។ បុគ្គលិកនៃអង្គការសិទ្ធិមនុស្សមិនត្រូវប្រើប្រាស់អភ័យឯកសិទ្ធិខ្លួន ដើម្បីការពារនូវអំពើខុសច្បាប់ ឬឧក្រិដ្ឋជននោះឡើយ។ ឧទាហរណ៍ជាក់ស្ដែង ប្រធានការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំកម្ពុជាបានបញ្ចុះបញ្ចូលកាំង ហ្កេកអ៊ាវ ហៅ ឌុច ជាមេឃាតកដៃដល់ដែលសម្លាប់បញ្ញវន្តខ្មែរក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត និងជាអតីតប្រធានគុកទួលស្លែង ឱ្យសុំការជ្រកកោននៅប្រទេសទីបី មុនត្រូវរាជរដ្ឋាភិបាលកម្ពុជា ចាប់យកមកកាត់ទោស។ បុគ្គលិកម្នាក់នៃការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានព្យាយាមបញ្ចុះបញ្ចូលជនពាក់ព័ន្ធនឹងស្នេហាលួចលាក់របស់ កឹម សុខា ឱ្យផ្ដល់សក្ខីកម្មក្លែង ដើម្បីសង្គ្រោះ កឹម សុខា ឱ្យរួចផុតពីរឿងអាស្រូវផ្លូវភេទ ដោយធានាថា អង្គការរបស់ខ្លួននឹងផ្ដល់សិទ្ធិជ្រកកោនដល់ជននោះ និងក្រុមគ្រួសារទៅរស់នៅក្រៅប្រទេស។ ទង្វើខាងលើនេះ ផ្ទុយទាំងស្រុងនឹងខ្លឹមសារនៃក្រមប្រតិបត្តិ សម្រាប់មន្ត្រីស៊ីវិលអន្តរជាតិឆ្នាំ ២០១៣ ដែលបានចែងនៅត្រង់វាក្យខណ្ឌទី៣៣ «... មន្ត្រីស៊ីវិលអន្តរជាតិទាំងអស់ត្រូវរក្សាទំនាក់ទំនង ឱ្យបានល្អបំផុតជាមួយរដ្ឋាភិបាល និងចៀសវាងសកម្មភាពណាមួយ ដែលអាចប៉ះពាល់ដល់ទំនាក់ទំនងនេះ ហើយមិនត្រូវជ្រៀតជ្រែកចូលកិច្ចការនយោបាយ និងកិច្ចការរបស់រដ្ឋាភិបាលឡើយ...»។

នៅឆ្នាំ២០១៦ តំណាងការិយាល័យ OHCHR បានធ្វើសេចក្តីថ្លែងការណ៍ថា «ជារឿងមិនសមហេតុសមផល» នៅពេលរាជរដ្ឋាភិបាលហាមមិនឱ្យ សម រង្ស៊ី ចូលស្រុក។ ដោយពុំបានទទួលព័ត៌មានច្បាស់លាស់ និងការពន្យល់ពីរាជរដ្ឋាភិបាលជាមុន តំណាងការិយាល័យនេះបានថ្លែងបញ្ចេញទស្សនៈផ្ទាល់ខ្លួន ហើយទង្វើនេះត្រូវបានចាត់ទុកថា ជាជំហរលម្អៀងទាំងស្រុងប្រឆាំងនឹងរាជរដ្ឋាភិបាល ក៏ដូចជាផ្ទុយនឹងខ្លឹមសារនៃក្រមប្រតិបត្តិ សម្រាប់មន្ត្រីស៊ីវិលអន្តរជាតិឆ្នាំ២០១៣ ដែលបានចែងនៅត្រង់វាក្យខណ្ឌទី៤៨ «... មន្ត្រីស៊ីវិលអន្តរជាតិ ត្រូវចៀសវាងគាំទ្រចំពោះគណបក្សនយោបាយ ឬយុទ្ធនាការនយោបាយ ហើយពួកគេមិនត្រូវទទួលយក ឬអង្គាសមូលនិធិ សរសេរអត្ថបទ ឬធ្វើសុន្ទរកថាជាសាធារណៈ ឬចេញសេចក្តីថ្លែងការណ៍ទៅកាន់សារព័ត៌មានឡើយ»។

**តើសកម្មភាពរបស់អង្គការសិទ្ធិមនុស្សទាំងនេះ ធ្វើឡើងដើម្បីការពារសិទ្ធិមនុស្ស ឬការពារឧក្រិដ្ឋជនរំលោភសិទ្ធិមនុស្ស?**

ជារួម ការយល់ដឹងអំពីសិទ្ធិសេរីភាពរបស់បុគ្គលឱ្យកាន់តែច្បាស់ ការយល់ដឹងអំពីច្បាប់ឱ្យបានទូលំទូលាយ ការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ការលើកកម្ពស់សីលធម៌របស់អ្នកនយោបាយ និងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច គឺជាមូលដ្ឋានគ្រឹះ ក្នុងការសម្រេចបាននូវគោលដៅពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។ ក្នុងន័យនេះ រាជរដ្ឋាភិបាលមិនគ្រាន់តែមានការប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យខាងលើប៉ុណ្ណោះទេ តែថែមទាំងខិតខំទប់ស្កាត់កុំឱ្យមានការញុះញង់ និងរើសអើងជាតិសាសន៍នៅកម្ពុជា ដែលជាបទល្មើសមួយពិភពលោកមានការស្អប់ខ្ពើម និងមានកាតព្វកិច្ចរួមគ្នាក្នុងការប្រយុទ្ធប្រឆាំង តាមរយៈការចូលរួមយ៉ាងសកម្ម ដើម្បី

អនុវត្តអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍។

### ៧.៣. សេរីភាពសារព័ត៌មាន

ការលើកឡើងអំពីការរំលោភលើសេរីភាពបញ្ចេញមតិ គឺជាការបំផ្លើស និងមួលបង្កាច់ទាំងស្រុង ពីព្រោះកម្ពុជាបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ពាក់ព័ន្ធសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិក្នុងការធ្វើបាតុកម្ម សិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី ដូចមានចែងក្នុងមាត្រា៣១ និងមាត្រា៣៧នៃរដ្ឋធម្មនុញ្ញ និងមាត្រា២នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។ នៅកម្ពុជា សេរីភាពក្នុងការបញ្ចេញមតិត្រូវបានលើកកម្ពស់ តាមគ្រប់មធ្យោបាយដោយគ្មានការរឹតត្បិត មិនដូចនៅបណ្តាប្រទេសមួយចំនួននោះទេ។ ផ្អែកតាមនិន្នាការរីកចម្រើននៃបច្ចេកវិទ្យាទំនើប ប្រជាពលរដ្ឋគ្រប់រូបក៏អាចបញ្ចេញមតិយ៉ាងទូលំទូលាយ ដោយគ្មានការត្រួតពិនិត្យតាមដាន លើការសរសេរផ្សព្វផ្សាយព័ត៌មាននិងអត្ថបទផ្សេងៗទៀត ជាពិសេស តាមប្រព័ន្ធអេឡិចត្រូនិច លើកលែងតែការផ្សព្វផ្សាយព័ត៌មានណាដែលរំលោភបំពានច្បាប់។ អ្នកយកការណ៍គ្មានព្រំដែនបានវាយតម្លៃនៅឆ្នាំ២០១៦ថា កម្ពុជាទទួលបានចំណាត់ថ្នាក់លេខ១លើសេរីភាពសារព័ត៌មាននៅអាស៊ាន តែទោះជាមានការលើកសរសើរបែបនេះក្តី សេរីភាពនោះត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់ និងមិនត្រូវបំពានលើកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គលដទៃ ស្ថាប័នជាតិ ឬបង្កអសន្តិសុខនិងចលាចលក្នុងសង្គមឡើយ។

ក្នុងពេលយុទ្ធនាការបោះឆ្នោតម្តងៗ គ.ជ.ប. បានផ្តល់មធ្យោបាយស្មើភាពគ្នា ចំពោះគណបក្សនយោបាយ ដែលបានចូលរួមបោះឆ្នោត សម្រាប់ផ្សព្វផ្សាយព័ត៌មានដល់អ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងអំពីកម្មវិធីនយោបាយរបស់គណបក្សនីមួយៗ ដោយធានាតម្លាភាពនិងសមភាពចំពោះការប្រើប្រាស់

វិទ្យុនិងទូរទស្សន៍រដ្ឋ។ ទន្ទឹមនឹងនេះ គ.ជ.ប. ក៏បានណែនាំដល់វិទ្យុរដ្ឋនិងទូរទស្សន៍ជាតិកម្ពុជា ឱ្យបែងចែកម៉ោងឃោសនាឱ្យបានស្មើៗគ្នា ដល់គ្រប់គណបក្សទាំងអស់ នៅក្នុងកំលុងពេលយុទ្ធនាការឃោសនាបោះឆ្នោត។ ក្រៅពីនេះ ចំពោះបណ្តាញវិទ្យុនិងទូរទស្សន៍ឯកជន និងសារព័ត៌មានក្នុងស្រុក ការផ្សាយសារនយោបាយរបស់គណបក្សណាមួយ គឺយោងទៅតាមការព្រមព្រៀងជាលក្ខណៈឯកជន និងអត្ថប្រយោជន៍ធុរកិច្ចរវាងគណបក្សនិងម្ចាស់ប្រព័ន្ធផ្សព្វផ្សាយ។

ដោយឡែក នៅមានប្រព័ន្ធផ្សព្វផ្សាយជាច្រើន ដែលមាននិន្នាការប្រឆាំងរាជរដ្ឋាភិបាល ហើយផ្សព្វផ្សាយព័ត៌មានគាំទ្រគណបក្សប្រឆាំង ក្នុងនោះមានជាអាទិ៍ វិទ្យុសំបុកឃ្មុំ FM១០៥ និងវិទ្យុសំឡេងស្ត្រី FM១០២ ជាដើម ហើយក្រៅពីនេះ វិទ្យុ VOA វិទ្យុ VOD និងវិទ្យុ RFA បានផ្សាយបន្តផ្ទាល់ចេញពីទីក្រុងវ៉ាស៊ីនតោនមកកាន់ប្រទេសកម្ពុជា។ វិទ្យុទាំងបីដែលទទួលថវិកាពីសហរដ្ឋអាមេរិក ផ្សាយព័ត៌មានលម្អៀង ខុសពីការពិតនៅកម្ពុជា និងជាឧបករណ៍នយោបាយបម្រើឱ្យគណបក្សប្រឆាំងយ៉ាងផ្គាប់មុខ ក្រោមលេសពង្រឹងលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ហើយរហូតមកដល់ពេលនេះ វិទ្យុ VOA និងវិទ្យុ RFA នៅតែបន្តផ្សព្វផ្សាយសកម្មភាពពាក់ព័ន្ធនានា ដែលភាគច្រើនសុទ្ធសឹងជាព័ត៌មានប្រឌិតបំផ្លើស និងមួលបង្កាច់។ កាសែតបរទេសមួយចំនួននិងកាសែតក្នុងស្រុកខ្លះ ក៏បានធ្វើសកម្មភាពបម្រើគោលដៅដូចគ្នានេះដែរ។

រាជរដ្ឋាភិបាលបានកត់សម្គាល់ឃើញថា គណបក្សនយោបាយភាគច្រើនបាននិងកំពុងប្រើប្រាស់សិទ្ធិសេរីភាពពេញលេញ ស្របតាមគោលការណ៍រដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីគណបក្សនយោបាយ ហើយសារព័ត៌មានទាំងនោះ

ក៏កំពុងបំពេញភារកិច្ចរបស់ខ្លួនតាមវិជ្ជាជីវៈ និងសេរីភាពសារព័ត៌មាន ដូចនៅបណ្តាប្រទេសប្រជាធិបតេយ្យនានាដែរ។

បណ្តាញទំនាក់ទំនងសង្គមដូចជា Facebook, Youtube, Twitter និងបណ្តាញព័ត៌មានសង្គមមួយចំនួន ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ដើម្បីផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធនឹងនយោបាយ និងរូបភាពផ្សេងៗ ដែលមានចរិតជាការប្រឌិតបំផ្លើស ការញុះញង់ ឬជាពាក្យចចាមអារ៉ាម ដែលគណបក្សប្រឆាំងនិងអ្នកគាំទ្រ បានបង្កើតឡើងក្នុងគោលដៅបំពុលបរិយាកាសសង្គម កេងចំណេញផ្នែកនយោបាយ ឬញុះញង់ប៉ុនប៉ងបំបែកបំបាក់ផ្ទៃក្នុងជាតិ និងការរើសអើងជាតិសាសន៍ជាដើម។

ថ្មីៗនេះ ការឈប់ចេញផ្សាយរបស់កាសែត The Cambodia Daily គឺដោយសារកាសែតនេះ មិនបានបង់ពន្ធតាមច្បាប់ស្តីពីរបបសារពើពន្ធកម្ពុជា។ ការអនុវត្តនេះ មិនសំដៅតែទៅលើកាសែត The Cambodia Daily មួយប៉ុណ្ណោះទេ ពីព្រោះសមត្ថកិច្ចពន្ធដារបានធ្វើសវនកម្មទូទាំងប្រទេស និងបានស្នើឱ្យក្រុមហ៊ុន ដែលជំពាក់ពន្ធទាំងអស់ត្រូវបង់ពន្ធតាមការកំណត់។ ដោយឡែក មានក្រុមហ៊ុនមួយចំនួនតូចមិនបានបំពេញកាតព្វកិច្ចពន្ធដារ និងបានបិទអាជីវកម្មដោយខ្លួនឯង ហើយក្នុងនោះរួមទាំងកាសែត The Cambodia Daily ក៏មិនបានបំពេញកាតព្វកិច្ចពន្ធដារដែរ ខណៈដែលកាសែតនេះបានប្រតិបត្តិការ អស់រយៈពេលជាង២០ឆ្នាំនៅកម្ពុជា។

ចំណែកឯវិទ្យុ RFA និងវិទ្យុ VOA ដែលត្រូវបានបង្កើតឡើង ដោយមានជំនួយផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាលអាមេរិក និងមានទីតាំងនៅសហរដ្ឋអាមេរិក បានបើកការិយាល័យនិងធ្វើការផ្សាយបន្តនៅទូទាំងប្រទេសកម្ពុជា អស់រយៈពេលជាច្រើនឆ្នាំកន្លងមក ដោយពុំបានស្នើសុំការអនុញ្ញាតពីក្រសួងព័ត៌មាន និងធ្វើការចុះបញ្ជីឱ្យបានត្រឹមត្រូវនោះទេ។ លើសពីនេះទៀត វិទ្យុ

ទាំងពីរក៏មិនបានបំពេញកាតព្វកិច្ចពន្ធដារដែរ។ នេះហើយជាមូលហេតុនៃការសម្រេចបិទការិយាល័យនៅភ្នំពេញ ដោយខ្លួនឯង ប៉ុន្តែវិទ្យុទាំងនេះនៅតែផ្សាយបន្តផ្ទាល់ពីសហរដ្ឋអាមេរិកដដែល។ វិទ្យុជាភាសាខ្មែរទាំងពីរនេះតែងតែផ្សព្វផ្សាយព័ត៌មានលម្អៀង បំភ្លៃ និងបំប៉ោង ហើយជាឧបករណ៍នយោបាយដាច់ថ្លៃសម្រាប់ផ្សព្វផ្សាយមនោគមវិជ្ជា ប្រឆាំងនឹងរាជរដ្ឋាភិបាល ដោយមិនបានបំពេញតួនាទីជាមជ្ឈមណ្ឌលព័ត៌មានអព្យាក្រឹត ដែលបម្រើឱ្យសង្គមនិងប្រជាពលរដ្ឋកម្ពុជាទូទៅទេ។

កម្ពុជាមានក្របខ័ណ្ឌច្បាប់ ដើម្បីការពារនិងលើកតម្កើងការអនុវត្តសិទ្ធិសេរីភាពនៃការបញ្ចេញមតិឱ្យបានត្រឹមត្រូវ ដូចជា រដ្ឋធម្មនុញ្ញ ច្បាប់ស្ដីពីរបបសារព័ត៌មាន ក្រមព្រហ្មទណ្ឌ ច្បាប់ព្រហ្មទណ្ឌពិសេស និងច្បាប់ជាតិព្រមទាំងលិខិតូបករណ៍គតិយុត្តអន្តរជាតិពាក់ព័ន្ធមួយចំនួន ដែលកម្ពុជាបានផ្ដល់សច្ចាប័ន។ កន្លងមក អ្នកសារព័ត៌មាន សកម្មជនសិទ្ធិមនុស្ស និងសកម្មជនសង្គមស៊ីវិលមួយចំនួន ត្រូវបានតុលាការផ្ដន្ទាទោស ដោយសារពួកគេបានប្រព្រឹត្តហួសព្រំដែននៃសិទ្ធិសេរីភាព ផ្ទុយនឹងក្រមវិជ្ជាជីវៈ និងរំលោភបំពានលើសិទ្ធិសេរីភាពអ្នកដទៃ។ ការអនុវត្តច្បាប់ចំពោះជនដែលប្រព្រឹត្តល្មើស គឺជាមធ្យោបាយតែមួយគត់ ដើម្បីការពារសិទ្ធិមនុស្ស ថែរក្សាសណ្ដាប់ធ្នាប់ សន្តិសុខសង្គម និងស្ថិរភាពនយោបាយ ដូចបណ្ដាប្រទេសប្រជាធិបតេយ្យនានា ដែលប្រកាន់យកជម្រើសបែបនេះដែរ។ ក្រមព្រហ្មទណ្ឌកម្ពុជា នៅត្រង់មាត្រា៣០៥ និងមាត្រា៣០៦ បានកំណត់ថា អំពើដែលប៉ះពាល់ដល់កិត្តិយសឬកិត្តិស័ព្ទនៃបុគ្គលឬស្ថាប័ន ដោយអសុទ្ធចិត្តជាសាធារណៈ ឬតាមសារព័ត៌មាន គឺជាបទល្មើសព្រហ្មទណ្ឌ តែការអនុវត្តច្បាប់និងការផ្ដន្ទាទោសចំពោះបទបរិហាកេរ្តិ៍នេះ គឺមានតែទោសពិន័យជាប្រាក់តែប៉ុណ្ណោះ មិនមានការអនុវត្តទោសដាក់ពន្ធនាគារឡើយ។

ការបើកទូលាយសេរីភាពសារព័ត៌មាននៅកម្ពុជា បានធ្វើឱ្យវិស័យនេះមានការរីកចម្រើនយ៉ាងឆាប់រហ័ស។ បច្ចុប្បន្ន កម្ពុជាមានអង្គភាពព័ត៌មានចំនួន៥៣០ ក្នុងនោះមានកាសែតផ្សាយជាភាសាបរទេសចំនួន៤៣អង្គភាព ស្ថានីយវិទ្យុ២២១ វិទ្យុទូរទស្សន៍ផ្សាយផ្ទាល់និងផ្សាយបន្តចំនួន១៣៤ស្ថានីយ វិទ្យុអនឡាញនិងវិទ្យុទូរទស្សន៍ហ្វេសប៊ុក ដែលកំពុងធ្វើអាជីវកម្មដោយសេរីទាំងចុះបញ្ជិកាស្របច្បាប់ និងពុំទាន់ចុះបញ្ជិកាចំនួនជាង១០០អង្គភាព ទូរទស្សន៍ឌីជីថល(Pay-TV)៥ស្ថានីយ ទូរទស្សន៍អនឡាញ៥៨អង្គភាព ព្រមទាំងការិយាល័យតំណាងទីភ្នាក់ងារសារព័ត៌មានបរទេស និងការិយាល័យតំណាងវិទ្យុ ទូរទស្សន៍បរទេសប្រចាំការអចិន្ត្រៃយ៍២១អង្គភាព។

**តើសហរដ្ឋអាមេរិកនិងសភាអឺរ៉ុប អនុញ្ញាតឱ្យក្រុមហ៊ុនដែលមិនបានបំពេញកាតព្វកិច្ចពន្ធដារ អាចប្រតិបត្តិការនៅក្នុងប្រទេសខ្លួនបានដែរឬទេ? តើសហរដ្ឋអាមេរិកនិងសភាអឺរ៉ុប កំពុងតែគាំទ្រដល់សារព័ត៌មានដែលល្មើសច្បាប់ឬយ៉ាងណា? ហើយចំនួនសារព័ត៌មានដូចរៀបរាប់ខាងលើ គឺជាសញ្ញាណនៃការរឹតត្បិតផ្នែកសារព័ត៌មានដែរឬទេ?**

ដើម្បីលើកកម្ពស់វិស័យព័ត៌មាន សម្តេចតេជោ **ហ៊ុន សែន** បានកំណត់យកការជួបពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយអ្នកកាសែតម្តងក្នុងមួយឆ្នាំ ហើយក្នុងខែមករា ឆ្នាំ២០១៨នេះ គឺជាការជួបលើកទី២ និងពិសាអាហារសាមគ្គីជាមួយអ្នកកាសែតចំនួនប្រមាណ២ ០០០នាក់ ដោយមិនគិតអំពីនិន្នាការនយោបាយ។ សកម្មភាពបែបនេះ បញ្ជាក់ឱ្យឃើញថា រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការបើកទូលាយ ដល់វិស័យព័ត៌មានក្នុងនាមជាដៃគូពិតប្រាកដ ដែលបានរួមចំណែកដល់ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការលើកកម្ពស់សិទ្ធិមនុស្ស សេរីភាពនៃសារព័ត៌មាន និងការបញ្ចេញមតិ។

## ៧.៤. អង្គការសង្គមស៊ីវិល

ប្រទេសកម្ពុជាត្រូវបានចាត់ទុកថា ជាឋានសួគ៌របស់សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល។ រាជរដ្ឋាភិបាលតែងចាត់ទុកថា សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលអព្យាក្រឹត ជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់របស់ខ្លួន។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស ដែលមាននិន្នាការលម្អៀងខាងគណបក្សប្រឆាំង បានរិះរកគ្រប់មធ្យោបាយ ដើម្បីមួលបង្កាច់រាជរដ្ឋាភិបាល និងជួយជ្រោមជ្រែងគណបក្សប្រឆាំងទាំងហិរញ្ញវត្ថុនិងបច្ចេកទេស សំដៅបំពុលបរិយាកាសនយោបាយនៅកម្ពុជា ក្នុងគោលដៅផ្តួលរំលំរដ្ឋអំណាចស្របច្បាប់។ អង្គការទាំងនេះមានដូចជា៖ វិទ្យាស្ថាន NDI (National Democratic Institute), COMFREL (Committee for Free and Fair Elections in Cambodia), LICADHO (Cambodian League for the Promotion and Defense of Human Rights), ADHOC (Cambodian Human Rights and Development Association), CISA (Coalition for Integrity and Social Accountability), NICFEC (Neutral and Impartial Committee for Free and Fair Elections in Cambodia), TIC (Transparency International Cambodia) និង PDP (People Center for Development and Peace) ជាដើម។ សកម្មភាពរបស់អង្គការទាំងនេះ មានទំនាក់ទំនងប្រទាក់ក្រឡានិងផ្សារភ្ជាប់គ្នា ជាមួយគណបក្សប្រឆាំង។ ពួកគេជាអ្នកចូលរួមរៀបចំយុទ្ធសាស្ត្រនយោបាយ ឱ្យគណបក្សប្រឆាំង និងដើរតួជាឧបករណ៍ក្នុងការបញ្ជ្រាបទស្សនៈអវិជ្ជមានដល់ស្រទាប់មហាជន អំពីរាជរដ្ឋាភិបាលនិងគណបក្សកាន់អំណាច ដើម្បីអូសទាញប្រជាពលរដ្ឋឱ្យគាំទ្រគណបក្សប្រឆាំង។ ជាងនេះទៀត ពួកគេបានរៀបចំកលល្បិចបំភ្លៃការពិត តាមរូបភាពផ្សេងៗ ផ្ទុយនឹងគោលការណ៍នីតិរដ្ឋ ដូចជាការ

ផ្សព្វផ្សាយព័ត៌មានបំភ័ន្តទៅក្រៅប្រទេស ការបញ្ចុះបញ្ចូលបុគ្គលនយោបាយបរទេស និងកៀរគរកម្លាំងខាងក្រៅ ឱ្យមានជំហរប្រឆាំងឬអរិជ្ជមាននឹងរាជរដ្ឋាភិបាល ជាដើម។

ថ្មីៗនេះ ចំពោះករណីដែលមិនអនុញ្ញាតឱ្យវិទ្យាស្ថាន NDI បន្តសកម្មភាពនៅកម្ពុជា គឺជាការអនុវត្តច្បាប់ដ៏ត្រឹមត្រូវ ស្របតាមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដោយសារវិទ្យាស្ថាននេះបានប្រតិបត្តិនៅកម្ពុជាអស់រយៈពេលជាង២០ឆ្នាំ ប៉ុន្តែមិនបានចុះអនុស្សរណៈជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។ ជាក់ស្តែង នៅមុនពេលបោះឆ្នោតឆ្នាំ២០១៣ វិទ្យាស្ថាននេះបានរៀបចំផែនការបំផ្លើសដោយយកមូលហេតុនៃការស្ទង់មតិថា គ.ជ.ប. បានលុបឈ្មោះអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ១,២៥លាននាក់។ **តើមានប្រទេសណាដែលអនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាល ប្រតិបត្តិការដោយគ្មានការចុះបញ្ជីបានដែរឬទេ? តើមានប្រទេសណាដែលអនុញ្ញាតឱ្យរដ្ឋាភិបាលបរទេស ផ្តល់ហិរញ្ញវត្ថុដល់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីប្រឆាំងនឹងរដ្ឋាភិបាល ដែលកំពុងគ្រប់គ្រងអំណាចស្របច្បាប់ដែរឬទេ? ក្នុងពេលដែលមានអង្គការមិនមែនរដ្ឋាភិបាលនិងសមាគមជាង៣ ០០០ បានចុះបញ្ជីស្របច្បាប់ និងកំពុងប្រតិបត្តិការនៅកម្ពុជា ហើយមានអង្គការមិនមែនរដ្ឋាភិបាលមួយ មិនបានចុះបញ្ជីរយៈពេលជាង២០ឆ្នាំ ថែមទាំង មានសកម្មភាពពាក់ព័ន្ធនឹងការផ្តួលរំលំរដ្ឋអំណាចស្របច្បាប់នោះ តើនេះគឺជាការរឹតត្បិតលើអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែរឬទេ?**

អង្គការសង្គមស៊ីវិល ដែលមាននិន្នាការប្រឆាំងរាជរដ្ឋាភិបាលមួយចំនួនធ្វើសកម្មភាពគ្រាន់តែផ្គាប់ចិត្តម្ចាស់ជំនួយតែប៉ុណ្ណោះ ដើម្បីទទួលបានធនធានហិរញ្ញវត្ថុសម្រាប់បន្តនិរន្តរភាពការងាររបស់ខ្លួន។ ប្រសិនបើសមាគមឬអង្គការទាំងនេះ មិនរិះគន់រាជរដ្ឋាភិបាលឬមិនបង្កើតឱ្យមានចលាចលសង្គមនោះទេ

ពួកគេអាចនឹងត្រូវបានចាត់ទុកថាជាអង្គការអព្យាក្រឹត ឬគាំទ្ររាជរដ្ឋាភិបាល ហើយអង្គការទាំងនោះ អាចត្រូវបានផ្អាកឬត្រូវបានកាត់ផ្តាច់ជំនួយ។ ប្រទេសជាច្រើននៅអាស៊ី បានពង្រឹងការអនុវត្តច្បាប់យ៉ាងតឹងរ៉ឹង លើការគ្រប់គ្រងអង្គការសង្គមស៊ីវិល ដើម្បីបង្ការការប្រព្រឹត្តអំពើដែលផ្ទុយនឹងច្បាប់ ដូចជាសកម្មភាពនយោបាយ ឬផ្តល់ហិរញ្ញវត្ថុដល់គណបក្សនយោបាយ ពីព្រោះថាតាមច្បាប់ បេសកកម្មរបស់អង្គការទាំងនេះ គឺត្រូវចូលរួមចំណែកជាមួយរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គម។ ដោយឡែកនៅកម្ពុជា អង្គការមួយចំនួន ជាពិសេសអង្គការដែលមាននិន្នាការប្រឆាំង គឺមានការពាក់ព័ន្ធយ៉ាងស៊ីជម្រៅទៅនឹងសកម្មភាពនយោបាយ ផ្សារភ្ជាប់ជាមួយនឹងគណបក្សប្រឆាំង។ ដូច្នេះ ការអនុវត្តច្បាប់ក្នុងការគ្រប់គ្រងអង្គការសង្គមស៊ីវិលនៅកម្ពុជា មិនមែនជាករណីដោយឡែកនោះឡើយ។

ដោយបំភ្លេចចោលនូវកិច្ចខិតខំប្រឹងប្រែង និងសមិទ្ធផលដ៏ច្រើនលើសលប់ដែលសម្រេចបានក្នុងសង្គម អង្គការទាំងនេះ ផ្តោតតែលើចំណុចខ្វះខាតមួយចំនួនរបស់អាជ្ញាធរមានសមត្ថកិច្ច ឬរាជរដ្ឋាភិបាល ហើយធ្វើការបំប៉ោងឬបំផ្លើសការពិត ធ្វើយ៉ាងណាឱ្យមានការប្រេះឆានិងបែកបាក់ក្នុងសង្គមជាតិ ផ្ទុយនឹងគោលការណ៍នៃការចូលរួមរបស់អង្គការសង្គមស៊ីវិល។ អង្គការមួយចំនួនទៀត បានយកគោលការណ៍និងការអនុវត្តនៃលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ដែលត្រូវបានកសាងឡើងជាជំហានៗ និងចាក់ឫសយ៉ាងជ្រៅក្នុងប្រទេសអភិវឌ្ឍន៍អស់រយៈពេលរាប់រយឆ្នាំហើយនោះ មកអនុវត្តដោយបង្ខំនៅកម្ពុជា ដែលលទ្ធិប្រជាធិបតេយ្យទើបកើតមានក្នុងរយៈពេលពាទសវត្សរ៍ចុងក្រោយប៉ុណ្ណោះ ហើយដែលប្រជាពលរដ្ឋកម្ពុជាមានការយល់ដឹងអំពីគោលការណ៍ជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យនៅមានកម្រិត និងពុំទាន់មានសមត្ថភាពក្នុងការអនុវត្តទស្សនទាននេះ បានទាំងស្រុងនៅឡើយ។

នៅឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានបង្កើតវេទិកាសម្ព័ន្ធសង្គមស៊ីវិល (វ.ស.ស.) ជាយន្តការបំពេញបន្ថែមលើយន្តការដែលមានស្រាប់ ដើម្បីប្រមូលផ្តុំទស្សនៈ មតិយោបល់ពីសំណាក់បញ្ញវន្ត ក្រុមស្រាវជ្រាវ បណ្ឌិតសភាចារ្យ និងសង្គមស៊ីវិល តាមរយៈការពិភាក្សានិងការស្រាវជ្រាវ តាមបែបវិទ្យាសាស្ត្រ សម្រាប់ចូលរួមរៀបចំគោលនយោបាយថ្មីៗ បម្រើផលប្រយោជន៍សាធារណៈ តាមគោលការណ៍ស្ម័គ្រចិត្ត។ វ.ស.ស. ជាវេទិកាសម្រាប់សម្របសម្រួលនិងពង្រឹងកិច្ចសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាលជាមួយអង្គការ សមាគមនានា និងតួអង្គពាក់ព័ន្ធទាំងឡាយ ដើម្បីផ្លាស់ប្តូរមតិយោបល់ឆ្លើយតបទៅនឹងបញ្ហាសំខាន់ៗ ក្នុងប្រទេស តំបន់ និងពិភពលោក។ ទន្ទឹមនឹងនេះ វ.ស.ស. ក៏នឹងក្លាយទៅជាយន្តការមួយ សម្រាប់ផ្តល់តម្លៃនៃគុណភាពនិងបេសកកម្មរបស់សង្គមស៊ីវិល ដែលមានតួនាទីជាកម្លាំងចលករជួយជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម។

## ៧.៥. ការធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ

យើងសង្កេតឃើញថា ជាទូទៅច្បាប់ស្តីពីគណបក្សនយោបាយនៃបណ្តាប្រទេសនានា អាចមានលក្ខណៈផ្សេងៗគ្នា ដែលអាចបែងចែកជា៣ប្រភេទធំៗគឺ៖ (១) មានលក្ខណៈធូររលុង (២) មានលក្ខណៈតឹងតែងបំផុត ឬច្បាប់ឯកបក្ស និង (៣) មានលក្ខណៈកណ្តាល (មិនធូរនិងមិនតឹងពេក) ដូចជា ច្បាប់ស្តីពីគណបក្សនយោបាយកម្ពុជាបច្ចុប្បន្ន និងនៅបណ្តាប្រទេសមួយចំនួនទៀត។

ច្បាប់ស្តីពីគណបក្សនយោបាយ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៧ ដែលនៅពេលនោះ កម្ពុជាពុំទាន់ទទួលបានសន្តិភាពពេញលេញនៅឡើយ ហើយច្បាប់នេះនៅមានលក្ខណៈធូរលុង បើប្រៀបធៀបនឹងច្បាប់នៅប្រទេសជិតខាង តែស្មារតីនៃច្បាប់នេះគឺស្របតាមស្ថានភាពសង្គមនាពេលនោះ។

ការធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយនៅឆ្នាំ២០១៧នេះ គឺដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃស្ថានភាពនយោបាយ សេដ្ឋកិច្ច សង្គម និងសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងការរីកដុះដាល និងការវិវត្តនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា នាពេលបច្ចុប្បន្ន។ ការធ្វើវិសោធនកម្មនេះ គឺបានរួមចំណែកដល់ការលើកកម្ពស់គុណភាព នៃលទ្ធិប្រជាធិបតេយ្យពិតប្រាកដនៅកម្ពុជា។

ច្បាប់វិសោធនកម្មថ្មីនេះ ផ្តល់ឱ្យគណបក្សនយោបាយទាំងអស់ នូវភាពស្មើគ្នាក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន ដោយមិនរើសអើងចំពោះគណបក្សនយោបាយណាមួយឡើយ ហើយខ្លឹមសារនៃច្បាប់នេះ មិនត្រឹមតែរួមបញ្ចូលគោលការណ៍លទ្ធិប្រជាធិបតេយ្យជាមូលដ្ឋាន ដូចមានចែងនៅក្នុងច្បាប់ស្តីពីគណបក្សនយោបាយនៃបណ្តាប្រទេសប្រជាធិបតេយ្យប៉ុណ្ណោះទេ តែថែមទាំងមានលក្ខណៈល្អប្រសើរជាងច្បាប់នៃបណ្តាប្រទេសមួយចំនួនទៀតផង។ ច្បាប់នេះសំដៅការពាររបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ព្រមទាំងទប់ស្កាត់រាល់ការប៉ុនប៉ងផ្តួលរំលំរដ្ឋអំណាចស្របច្បាប់។ ជាក់ស្តែង ក្នុងមាត្រា៦ថ្មី(ពីរ)ចែងថា «**គ្រប់គណបក្សនយោបាយមិនត្រូវធ្វើសកម្មភាពណាមួយដូចខាងក្រោម៖ (១) ធ្វើឱ្យមានអបគមន៍ដែលនាំឱ្យអន្តរាយដល់ឯកភាពជាតិ និងបូរណភាពដែនដី (២) ធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ (៣) ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខរដ្ឋ (៤) បង្កើតកងកម្លាំងប្រដាប់អាវុធ (៥) ធ្វើការញុះញង់ ដែលអាចនាំឱ្យមានការបែកបាក់ជាតិ...**»។ នៅត្រង់មាត្រា២៩ថ្មី ក៏បានចែងថា «**គណបក្សនយោបាយត្រូវបានហាមឃាត់មិនឱ្យទទួលវិភាគទាន ទោះជាតាមរូបភាពណាក៏ដោយ ពីស្ថាប័នរដ្ឋ សមាគមអង្គការមិនមែនរដ្ឋាភិបាល សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ**

**វិទ្យាស្ថានសាធារណៈ លើកលែងករណីដូចមានចែងក្នុងមាត្រា២៨នៃច្បាប់នេះ។ គណបក្សនយោបាយត្រូវបានហាមឃាត់មិនឱ្យទទួលវិភាគទាន ទោះតាមរូបភាពណាក៏ដោយ ពីស្ថាប័នបរទេស ក្រុមហ៊ុនបរទេស ជនបរទេស ឬអង្គការដែលមានប្រភពហិរញ្ញប្បទានពីបរទេស»។** នៅត្រង់មាត្រា៤៤ថ្មី(ពីរ) បានចែងពីប្បញ្ញត្តិអាចផ្អាកសកម្មភាពឬរំលាយគណបក្សនយោបាយ។

បទពិសោធរបស់បណ្តាប្រទេសនានាលើពិភពលោក ពាក់ព័ន្ធនឹងច្បាប់ស្តីពីគណបក្សនយោបាយ បានបង្ហាញថា នៅឆ្នាំ១៩៩៩ គណៈកម្មការទីក្រុងវ៉េនីសនៃប្រទេសអ៊ីតាលី បានអនុម័ត «គោលការណ៍ស្តីពីការហាមឃាត់ និងការរំលោយគណបក្សនយោបាយ និងវិធានការប្រហាក់ប្រហែល»។ នៅបណ្តាប្រទេសជាច្រើន ជាពិសេសនៅអឺរ៉ុប ដូចជាប្រទេសដាណឺម៉ាក បារាំង ព័រទុយហ្គាល់ អង់គ្លេស អាឡឺម៉ង់ តួកគី ក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ពាក់ព័ន្ធ ឬច្បាប់ស្តីពីគណបក្សនយោបាយ មានចែងអំពីការរំលាយ ឬការហាមឃាត់គណបក្សនយោបាយ ប្រសិនបើគណបក្សណាប្រព្រឹត្តអំពើផ្ទុយនឹងគោលការណ៍សំខាន់ៗ ដូចជា (១) ការលើកទឹកចិត្តឱ្យកើតមានអំពើហិង្សា ការរើសអើងសាសនា ឬការប្រកាន់ពូជសាសន៍ (២) ការធ្វើឱ្យប៉ះពាល់ដល់សន្តិសុខជាតិ របៀបរៀបរយសង្គម និងការគាំទ្រសកម្មភាពភេរវកម្ម និង(៣) ការទទួលហិរញ្ញវត្ថុពីភ្នាក់ងារបរទេស។ ដោយឡែក នៅប្រទេសអូស្ត្រាលី សហរដ្ឋអាមេរិក និងកាណាដា ក៏បានហាមឃាត់ការជ្រៀតជ្រែកនិងការទទួលហិរញ្ញវត្ថុពីបរទេសផងដែរ។

ជាក់ស្តែង សហរដ្ឋអាមេរិក ដែលតែងតែលើកតម្កើងខ្លួនថាជាបិតានៃលទ្ធិប្រជាធិបតេយ្យ ក៏នៅតែមិនអនុញ្ញាតឱ្យបរទេសលូកដៃចូលក្នុងដំណើរការនៃការបោះឆ្នោត និងកិច្ចការផ្ទៃក្នុងរបស់ខ្លួនដែរ ដែលក្នុងពេលបច្ចុប្បន្ន សហរដ្ឋអាមេរិកខ្លួនឯង កំពុងតែមានភាពចម្រូងចម្រាស់លើករណីជាច្រើន ដែល

លើកឡើងថា រុស្ស៊ីបានលូកដៃចូលក្នុងការបោះឆ្នោតជ្រើសរើសប្រធានាធិបតីទី៤៥របស់ខ្លួន។

ដោយឡែកនៅអាស៊ី ក៏មានករណីនៃការហាមឃាត់ ឬការរំលាយគណបក្សនយោបាយ ដែលបានប្រព្រឹត្តផ្ទុយនឹងច្បាប់ស្តីគណបក្សនយោបាយ ច្បាប់ពាក់ព័ន្ធ ឬរដ្ឋធម្មនុញ្ញដែរ។ ជាទូទៅ នៅបណ្តាប្រទេសអាស៊ី ច្បាប់មានលក្ខណៈផ្សេងៗគ្នា។ ច្បាប់នៃប្រទេសខ្លះប្រកាន់យកការគ្រប់គ្រងរដ្ឋបែបឯកបក្ស ប្រទេសខ្លះទៀតប្រកាន់យកពាក់កណ្តាលប្រជាធិបតេយ្យ និងប្រទេសខ្លះទៀត អនុវត្តប្រព័ន្ធគ្រប់គ្រងរដ្ឋតាមបែបប្រជាធិបតេយ្យ សេរីពហុបក្ស។ ទោះបីជាខ្លឹមសារនៃច្បាប់នៃប្រទេសនីមួយៗ មានលក្ខណៈខុសៗគ្នាទៅតាមរបបនៃការគ្រប់គ្រងរដ្ឋក៏ដោយ តែគោលការណ៍សំខាន់ៗ គឺមានលក្ខណៈប្រហាក់ប្រហែលគ្នា ពោលគឺ ផ្តល់អំណាចឱ្យតុលាការមានសិទ្ធិរំលាយគណបក្សនយោបាយណា ដែលប្រព្រឹត្តផ្ទុយនឹងគោលការណ៍គ្រឹះ (១) សកម្មភាពផ្ទុយនឹងលទ្ធិប្រជាធិបតេយ្យ ការប្រព្រឹត្តអំពើហិង្សា ការរើសអើងសាសនា ឬការប្រកាន់ពូជសាសន៍ (២) ការធ្វើឱ្យប៉ះពាល់ដល់អធិបតេយ្យភាព សន្តិសុខជាតិ និងរបៀបរៀបរយសង្គម (៣) ការទទួលហិរញ្ញវត្ថុពីភ្នាក់ងារបរទេស។

កម្ពុជាត្រូវបានទទួលរងការរិះគន់ ចំពោះការធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយនាពេលថ្មីៗនេះ។ ប៉ុន្តែមុននឹងធ្វើការវិនិច្ឆ័យអំពីច្បាប់របស់កម្ពុជា រដ្ឋាភិបាលនៃបណ្តាប្រទេសមួយចំនួននិងស្ថាប័នបរទេសដែលបានរិះគន់នោះ គួរតែពិនិត្យមើលប្រព័ន្ធច្បាប់របស់ខ្លួនឡើងវិញ ថាតើមានការអនុញ្ញាតឱ្យគណបក្សនយោបាយ ប្រព្រឹត្តផ្ទុយនឹងគោលការណ៍លទ្ធិប្រជាធិបតេយ្យ សន្តិសុខជាតិ ឬអនុញ្ញាតឱ្យបរទេស ឬអង្គការអន្តរជាតិជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសខ្លួន ឬទទួលហិរញ្ញប្បទានពីបរទេស

ជាពិសេស គឺហិរញ្ញប្បទានក្នុងគោលដៅផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ដែរឬទេ។

ការព្រួយបារម្ភនិងការលើកឡើងរបស់ប្រទេសមួយចំនួនថា កម្ពុជាដើរចាកឆ្ងាយពីគន្លងប្រជាធិបតេយ្យ គឺពិតជាមិនត្រឹមត្រូវទេ។ ដើម្បីឆ្លើយតបនឹងស្ថានការណ៍វិវត្តន៍សេដ្ឋកិច្ច សង្គម និងនយោបាយ កម្ពុជាត្រូវការធ្វើវិសោធនកម្មច្បាប់មួយចំនួន និងធ្វើកំណែទម្រង់ស្ថាប័នពាក់ព័ន្ធ ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ពីព្រោះថាស្ថានភាពសេដ្ឋកិច្ចសង្គមនិងនយោបាយកាលពី២០ឆ្នាំមុន មិនអាចឆ្លើយតបបានទៅនឹងតម្រូវការនៃការអភិវឌ្ឍសង្គមនៅពេលនេះទេ។

### ៧.៦. ការចាប់ខ្លួន កឹម សុខា

កឹម សុខា ជាមេដឹកនាំចលនាបដិវត្តន៍ពណ៌នៅកម្ពុជា ដោយមានការបណ្តុះបណ្តាល និងជួយជ្រោមជ្រែងទាំងមធ្យោបាយ បច្ចេកទេស និងហិរញ្ញវត្ថុពីបរទេស ហើយរាជរដ្ឋាភិបាលបានរកឃើញវីដេអូឃ្លីបដែលបានផ្សព្វផ្សាយជាសាធារណៈដោយបណ្តាញព័ត៌មាន CBN (Cambodian Broadcasting Network) នៅអូស្ត្រាលី ដែលនៅពេលនោះ កឹម សុខា ជាអនុប្រធានគណបក្សសង្គ្រោះជាតិ បាននិយាយនៅចំពោះមុខពលរដ្ឋខ្មែរថា «...តាំងពីឆ្នាំ១៩៩៣ ខ្ញុំជាប់តំណាងរាស្ត្រដំបូង រដ្ឋាភិបាលអាមេរិក ហៅខ្ញុំទៅស្រុកអាមេរិកមុនគេបង្អស់ក្នុងនាមអ្នកនយោបាយខ្មែរមួយឆ្នាំម្តង ដើម្បីឱ្យស្វែងយល់ពីដំណើរការប្រជាធិបតេយ្យ។ អាមេរិកបានសម្រេចចិត្តថា ដើម្បីឱ្យប្រទេសកម្ពុជាមានការផ្លាស់ប្តូរនោះ ខ្ញុំត្រូវដកខ្លួនចេញពីនយោបាយមួយគ្រាសិន។ ខ្ញុំក៏លាឈប់ពីគណបក្សនយោបាយ ដើម្បីបង្កើតអង្គការមួយឈ្មោះហៅថា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។ តើអាមេរិកឱ្យបង្កើតដើម្បីអ្វី? គេថាបើចង់ប្តូរអ្នកដឹកនាំ យើងមិនអាចទៅដល់ឬប្តូរខាងលើបានទេ ដូច្នេះមុននឹង

ប្តូរខាងលើបាន ទាល់តែគាស់អាក្រោមសិន។ ទាល់តែប្តូរពីក្រោមទៅមុន ជាយុទ្ធសាស្ត្រនយោបាយរបស់ប្រទេសប្រជាធិបតេយ្យ ហើយសហរដ្ឋអាមេរិកដែលជួយខ្ញុំ គឺឱ្យយកម៉ូឌែលតាមប្រទេសយូហ្គោស្លាវី នៅស៊ែប៊ី ដែលគេប្តូរមេដឹកនាំផ្តាច់ការ Milosevic បាន។ Milosevic មានរថគ្រោះសម្បើមណាស់បងប្អូន ប៉ុន្តែគេប្តូរបានដោយសារគេធ្វើយុទ្ធសាស្ត្រនេះ ហើយគេយកបទពិសោធនេះមកឱ្យខ្ញុំធ្វើនៅស្រុកខ្មែរ តែអត់មានអ្នកណាដឹងទេ ប៉ុន្តែដោយសារថ្ងៃនេះ យើងឈានដល់មួយដំណាក់ហើយ ដូច្នេះ ខ្ញុំត្រូវតែប្រាប់បងប្អូនឱ្យដឹង។ ជោគជ័យដែលយើងទទួលបាន ខ្ញុំអត់ធ្វើតាមខ្ញុំនឹកឃើញទេ គឺមានអ្នកជំនាញការសាស្ត្រាចារ្យ (Professor) នៅសាកលវិទ្យាល័យ នៅទីក្រុង Washington DC នៅទីក្រុង Montreal ប្រទេសកាណាដា ដែលអាមេរិកកាំងជួលមក ដើម្បីធ្វើការផ្តល់មតិឱ្យខ្ញុំរបៀបជាយុទ្ធសាស្ត្រក្នុងការផ្លាស់ប្តូរមេដឹកនាំ ហើយបើខ្ញុំធ្វើតាមក្បួនប៉ុណ្ណឹង និងយុទ្ធសាស្ត្រប៉ុណ្ណឹង បើមិនជោគជ័យទៀតខ្ញុំមិនដឹងថាយ៉ាងម៉េចទៀតទេ។»

ផ្អែកលើភស្តុតាងក្នុងវីដេអូឃ្លីបដែល កឹម សុខា បានអួតអាងនៅទីក្រុងម៉ែលប៊ិនថា អាមេរិកជួយរៀបចំយុទ្ធសាស្ត្រដើម្បីប្តូរមេដឹកនាំតាមគំរូប្រទេសយូហ្គោស្លាវី និងភស្តុតាងមួយចំនួនទៀត កឹម សុខា ត្រូវបានកម្លាំងនគរបាលយុត្តិធម៌ចាប់ខ្លួន និងត្រូវបានចោទប្រកាន់ពីបទសន្ទិដ្ឋិភាពជាមួយបរទេស ពាក់ព័ន្ធនឹងការរួមគំនិតនិងឃុបឃិតជាមួយបរទេស ក្នុងការអនុវត្តផែនការសម្ងាត់ផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ ដោយយោងតាមមាត្រា៤៤៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា «បទសន្ទិដ្ឋិភាពជាមួយបរទេស គឺជាអំពើត្រូវរ៉ូវគ្នាដោយសម្ងាត់ជាមួយរដ្ឋបរទេស ឬភ្នាក់ងារបរទេស ដើម្បីបង្កើតឱ្យមានអំពើប្រទូស្តរ៉ាយ ឬឱ្យមានអំពើឈ្លានពាន ប្រឆាំងនឹងព្រះរាជាណាចក្រកម្ពុជា។ បទសន្ទិដ្ឋិភាពជាមួយបរទេស ត្រូវផ្តន្ទាទោស

ដាក់ពន្ធនាគារពី១៥ឆ្នាំ ទៅ៣០ឆ្នាំ»។ ក្រៅពីវីដេអូឃ្លីបនេះ នៅមានវីដេអូឃ្លីបមួយចំនួនទៀត ជាភស្តុតាងដ៏រឹងមាំ ដែលបង្ហាញនូវផែនការដ៏ច្បាស់លាស់មិនអាចប្រកែកបានអំពីការឃុបឃិតគ្នាជាសម្ងាត់ជាមួយបរទេស ដើម្បីផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ ដោយបានអនុវត្តរួមគ្នារវាងគណបក្សសង្គ្រោះជាតិ អង្គការមិនមែនរដ្ឋាភិបាល និងភ្នាក់ងារបរទេស ដូចដែលបានកើតឡើងនៅក្នុងប្រទេសមួយចំនួន។ សកម្មភាពបន្តបន្ទាប់គ្នា ជាពិសេសគឺក្នុងកំលុងឆ្នាំ២០១៣ដល់២០១៤ រហូតដល់ថ្ងៃចាប់ខ្លួន កឹម សុខា គឺជាបទល្មើសជាក់ស្តែង។

ករណីរបស់ កឹម សុខា កំពុងស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការធ្វើការស៊ើបអង្កេត និងស្រាវជ្រាវបន្តទៀត មុននឹងវិនិច្ឆ័យទោស។ ទោះជាការដណ្តើមអំណាចតាមមធ្យោបាយណាក៏ដោយ ដែលផ្ទុយនឹងច្បាប់ស្តីពីការបោះឆ្នោត ដោយមានឬគ្មានការជ្រៀតជ្រែកពីបរទេស តាមរយៈមធ្យោបាយ មនោគមវិជ្ជា ឬហិរញ្ញវត្ថុក្តី គឺនៅតែជាការប៉ុនប៉ងផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ ដើម្បីដណ្តើមអំណាចដោយខុសច្បាប់។

ចំពោះការចាប់ខ្លួនអ្នកនយោបាយ សមាជិកសភា ឬព្រឹទ្ធសភាដែលប្រព្រឹត្តខុសច្បាប់ តាមនីតិវិធីច្បាប់ មិនមែនមានន័យថាជាការរំលោភសិទ្ធិមនុស្ស និងសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ឬបំបិទសិទ្ធិធ្វើនយោបាយនោះទេ។ **ការចាប់ខ្លួនអ្នកនយោបាយដែលប្រព្រឹត្តល្មើសច្បាប់ មិនមែនកើតមានឡើងតែនៅកម្ពុជាទេ តែមាននៅស្ទើរគ្រប់ប្រទេស គ្រាន់តែបទចោទប្រកាន់ ឬការប្រព្រឹត្តមានលក្ខណៈខុសៗគ្នា តាមក្របខ័ណ្ឌច្បាប់នៃប្រទេសនីមួយៗ ដូចជានៅប្រទេសថៃ ហ្វីលីពីន ម៉ាឡេស៊ី សាធារណរដ្ឋកូរ៉េ ឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតចិន សហរដ្ឋអាមេរិក រុស្ស៊ី និងនៅប្រទេសមួយចំនួននៅអាមេរិកឡាទីន អាហ្វ្រិក និងអឺរ៉ុប ជាដើម។**

បស្ចិមប្រទេសមួយចំនួនបានអំពាវនាវឱ្យដោះលែង កឹម សុខា ដែលនេះជាការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា និងរំលោភលើសមត្ថកិច្ចរបស់តុលាការ ផ្ទុយនឹងគោលការណ៍នីតិរដ្ឋ និងធម្មនុញ្ញអង្គការសហប្រជាជាតិ និងលិខិតូបករណ៍អន្តរជាតិផ្សេងៗ នៅពេលដែលបណ្តាប្រទេសទាំងនោះតែងតែជំរុញឱ្យកម្ពុជាគោរពនិងអនុវត្តច្បាប់។ អ្នកនយោបាយត្រូវទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដែលបានប្រព្រឹត្តនិងមិនត្រូវធ្វើតាមការបង្គាប់បញ្ជារបស់បរទេស ដើម្បីសម្រេចគោលដៅដណ្តើមអំណាច ដោយប្រើប្រាស់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ជាខែលសម្រាប់បោកប្រាស់ប្រជាពលរដ្ឋនោះទេ។

**រហូតមកដល់ពេលនេះ ស្ថានទូតអាមេរិកពុំបានឆ្លើយតបនឹងសំណួររបស់សម្តេចតេជោ ហ៊ុន សែន ដែលបានចោទសួរថា តើសម្តីរបស់ កឹម សុខា ដែលនិយាយក្នុងវីដេអូឃ្លីបថា អាមេរិកជាអ្នកជួយជ្រោមជ្រែងឱ្យផ្តួលរំលំរដ្ឋាភិបាល តាមគំរូប្រទេសយូហ្គោស្លាវី គឺជាការពិតដែរឬទេ។**

ក្នុងនាមជាប្រទេសដែលបានទទួលរងនូវឥទ្ធិពល នៃចលនាបដិវត្តន៍ពណ៌ កម្ពុជាគាំទ្រទាំងស្រុងចំពោះសេចក្តីថ្លែងការណ៍របស់លោកប្រធានាធិបតីជាប់ឆ្នោតអាមេរិក **ដូណាល់ ត្រាំ** ក្នុងពិធីថ្លែងអំណរគុណដល់អ្នកបោះឆ្នោតគាំទ្រខ្លួន នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៦ ដែលបានលើកឡើងថា «យើងនឹងឈប់ប្រកួតប្រជែងគ្នា ដើម្បីផ្តួលរំលំរដ្ឋាភិបាលបរទេស ដែលយើងមិនស្គាល់ ហើយយើង ក៏មិនត្រូវជាប់ពាក់ព័ន្ធជាមួយនឹងការផ្តួលរំលំរដ្ឋាភិបាលនៃប្រទេសទាំងនោះទេ»។

## ៧.៧. ការរំលាយគណបក្សសង្គ្រោះជាតិ

គណបក្សសង្គ្រោះជាតិ បានប្រព្រឹត្តអំពើផ្ទុយនឹងរដ្ឋធម្មនុញ្ញនិងច្បាប់ជាធរមាន ដូចជា អំពើវិទ្ធង្សនាចំពោះលទ្ធផលនៃការបោះឆ្នោត បង្កឱ្យមាន

អសន្តិសុខនិងចលាចលនៅទូទាំងប្រទេស ធ្វើសកម្មភាពនាំឱ្យមានការរើសអើងពូជសាសន៍និងបែកបាក់ផ្ទៃក្នុងជាតិជាដើម សំដៅប្រើប្រាស់កម្លាំងមហាជនដើម្បីទម្លាក់របបដឹកនាំស្របច្បាប់ ដោយមានការគាំទ្រ ការឃុបឃិតនិងការបង្គាប់បញ្ជាពីបរទេស អស់រយៈពេលជាច្រើនឆ្នាំមកហើយ ជាពិសេសនៅឆ្នាំ២០១៣ ឆ្នាំ២០១៤ រហូតដល់ឆ្នាំ២០១៧។ នៅដើមឆ្នាំ២០១៤ អំពើហិង្សាដែលឈានដល់ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងបាត់បង់អាយុជីវិតមនុស្ស គឺដោយការគ្រោងទុករបស់ថ្នាក់ដឹកនាំនៃគណបក្សសង្គ្រោះជាតិ។ ស្ថានទូតបរទេសចំនួនបី បានផ្តល់ព័ត៌មានដល់រាជរដ្ឋាភិបាលកម្ពុជា អំពីគម្រោងការបាតុកម្មហិង្សានេះជាមុន ដោយមានការរៀបចំដឹកជញ្ជូនដុំថ្មគ្រាប់បែកដបសាំង ដំពាម ដាវ និងឧបករណ៍ផ្សេងទៀត ដាក់នៅកន្លែងមួយសម្រាប់ប្រើប្រាស់នៅថ្ងៃបាតុកម្ម។ **តើនេះជាបាតុកម្មអហិង្សា ហើយបាតុករជាជនស្លូតត្រង់មែនទេ?** បន្ថែមលើនេះទៀត ភស្តុតាងដែលមិនអាចប្រកែកបានគឺ កឹម សុខា បាននិយាយនិងបានទទួលស្គាល់ជាសាធារណៈថា រដ្ឋាភិបាលអាមេរិកជាអ្នកណែនាំ បង្រៀន និងទំនុកបម្រុងដល់ខ្លួន នៅក្នុងការរៀបចំដណ្តើមអំណាចដោយយកគំរូតាមបដិវត្តន៍ពណ៌ទម្លាក់លោក Slobodan Milosevic នៅប្រទេសយូហ្គោស្លាវី។

ផែនការជាបន្តបន្ទាប់ដែលបានរៀបចំនិងអនុវត្តកន្លងមក គឺមានលក្ខណៈជាប្រព័ន្ធ តាំងពីដំណើរការរៀបចំផែនការ រហូតដល់ការអនុវត្តជាក់ស្តែង រួមទាំង ការផ្សព្វផ្សាយ ការញុះញង់ ការចែកចាយព័ត៌មាន ការកៀរគរអ្នកគាំទ្រឱ្យងើបឡើងបះបោរប្រឆាំងនឹងរដ្ឋអំណាច ការបិទផ្លូវ ការធ្វើបាតុកម្ម និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈនិងឯកជន។ មេដឹកនាំនិងសកម្មជននៃគណបក្សសង្គ្រោះជាតិបានធ្វើសកម្មភាពរំលោភ លើរដ្ឋធម្មនុញ្ញនិងច្បាប់ ដើម្បីឡើងកាន់អំណាច។ គណបក្សសង្គ្រោះជាតិបានប្រព្រឹត្តអំពើ

ទុច្ចរិត ដោយមានបរទេសជាអ្នកផ្គត់ផ្គង់ហិរញ្ញវត្ថុ រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនយោបាយ ដែលធ្វើឱ្យប៉ះពាល់ដល់អធិបតេយ្យភាព និងដំណើរការបោះឆ្នោត ដោយសេរីនិងយុត្តិធម៌។

ផ្អែកលើពាក្យបណ្តឹងរបស់គណបក្សហ្វ៊ុនស៊ីនប៉ិច និងគណបក្សយុវជនកម្ពុជា ក្រសួងមហាផ្ទៃបានដាក់ពាក្យបណ្តឹងទៅតុលាការកំពូល ដើម្បីស្នើសុំរំលាយគណបក្សសង្គ្រោះជាតិ នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៧ ដោយយោងលើរដ្ឋធម្មនុញ្ញ ក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីគណបក្សនយោបាយ ព្រមទាំងបានស្នើសុំឱ្យតុលាការកំពូល ហាមឃាត់ការធ្វើសកម្មភាពនយោបាយរបស់ថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិចំនួន១១៨នាក់ ដែលជាមន្ត្រីជាន់ខ្ពស់ ឬបុគ្គលស្ថិតក្នុងរចនាសម្ព័ន្ធដឹកនាំរបស់គណបក្សសង្គ្រោះជាតិ ដែលមានសិទ្ធិអនុម័ត កសាងយុទ្ធសាស្ត្រ គោលនយោបាយ ដាក់ចេញសេចក្តីសម្រេចបទបញ្ជា និងដឹកនាំការអនុវត្ត។

យោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា តុលាការកំពូលបានសម្រេចរំលាយគណបក្សសង្គ្រោះជាតិ ដោយផ្អែកលើអង្គច្បាប់ (មាត្រា៦ថ្មី (ពីរ) និងមាត្រា៧ នៃច្បាប់ស្តីពីគណបក្សនយោបាយ) និងអង្គហេតុដែលមានភស្តុតាងច្បាស់លាស់ ប្រទាក់ក្រឡា និងស៊ីសង្វាក់គ្នា ចាប់ពីការផ្តើមឃុបឃិតជាមួយបរទេស ដើម្បីរៀបចំផែនការធ្វើបដិវត្តន៍ពណ៌ផ្តួលរំលំរាជរដ្ឋាភិបាល រហូតដល់ថ្ងៃរំលាយគណបក្សនេះ។ តាមនីតិវិធីច្បាប់ គណបក្សសង្គ្រោះជាតិមានសិទ្ធិក្នុងការតតាំង និងដាក់ភស្តុតាងជាអំណះអំណាងតទល់នឹងការចោទប្រកាន់ខាងលើ តែគណបក្សនេះពុំមានទឡ្ហីករណ៍ណាឆ្លើយតបនឹងការចោទប្រកាន់នេះទេ។ ក្នុងពេលជាមួយគ្នានេះដែរ ថ្នាក់ដឹកនាំទាំង១១៨នាក់របស់គណបក្សសង្គ្រោះជាតិ ក៏ត្រូវហាមឃាត់ធ្វើសកម្មភាពនយោបាយសម្រាប់រយៈពេល៥ឆ្នាំ។

យោងតាមគោលការណ៍ច្បាប់នៃប្រទេសនានា ការរំលាយគណបក្សនយោបាយគឺជាវិធានការផ្លូវច្បាប់ ដើម្បីបង្ការនិងទប់ស្កាត់គណបក្សនយោបាយដែលធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខជាតិ ដំណើរការលទ្ធិប្រជាធិបតេយ្យ និងអធិបតេយ្យភាពជាតិ ដែលមានការជ្រៀតជ្រែកពីបរទេស តាមរយៈមនោគមវិជ្ជា មធ្យោបាយ ហិរញ្ញវត្ថុ និងការគាំទ្រផ្សេងៗទៀត។ ការរំលាយគណបក្សនយោបាយមិនមែនជារឿងថ្មី ដែលកើតឡើងនៅក្នុងប្រទេសកម្ពុជាទេ តែក៏មានកើតឡើងនៅក្នុងប្រទេសជាច្រើន ដូចជា ប្រទេសថៃ សាធារណរដ្ឋកូរ៉េ តួកគី អេស្ប៉ាញ អាឡឺម៉ង់ បារ៉ែន និងអ៊ីស្រាអែល ជាដើម។

ការរំលាយគណបក្សនេះ គឺដើម្បីរំលាយអង្គការចាត់តាំងនិងរចនាសម្ព័ន្ធនៃចលនាបដិវត្តន៍ពណ៌ សំដៅការពាររដ្ឋធម្មនុញ្ញ របបរាជានិយម លទ្ធិប្រជាធិបតេយ្យ អធិបតេយ្យជាតិ សន្តិសុខ ស្ថិរភាពសង្គម និងសន្តិភាព ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ជាពិសេសគឺការទប់ស្កាត់នូវការបង្ហូរឈាម ដែលនឹងអាចកើតមាននៅមុនថ្ងៃឬក្រោយថ្ងៃបោះឆ្នោតឆ្នាំ២០១៨។

ទោះបីជាគណបក្សសង្គ្រោះជាតិត្រូវបានរំលាយក៏ដោយ ក៏នៅមានគណបក្សជាច្រើន ដែលមានមនោគមវិជ្ជានិងនិន្នាការនយោបាយខុសៗគ្នា ត្រៀមនឹងចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឆ្នាំ២០១៨នេះ ហើយថ្នាក់ដឹកនាំ និងសកម្មជននៃអតីតគណបក្សសង្គ្រោះជាតិ ដែលមិនស្ថិតក្នុងបញ្ជីហាមឃាត់ធ្វើនយោបាយ មានសិទ្ធិបង្កើតគណបក្សនយោបាយថ្មី ឬចូលរួមជាមួយគណបក្សនយោបាយណាមួយ ដែលពួកគេពេញចិត្ត។ ទោះបីជាគណបក្សសង្គ្រោះជាតិ ត្រូវបានរំលាយដោយតុលាការកំពូលក៏ដោយ ក៏ស្ថានភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់ និងស្ថិរភាពសង្គមនៅកម្ពុជាពុំមានការប្រែប្រួលឡើយ ហើយថែមទាំងមានលក្ខណៈល្អប្រសើរទៀតផង។

ស្ថិរភាពនយោបាយបច្ចុប្បន្ន បានផ្តល់នូវបរិយាកាសនយោបាយល្អប្រសើរ បង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋប្រកបរបរទទួលទាន និងជំរុញសកម្មភាពសេដ្ឋកិច្ច និងបានទាក់ទាញវិនិយោគិនពីបរទេសមកដាក់ទុនវិនិយោគក្នុងវិស័យផ្សេងៗ។

អ្នកការទូតអាស៊ី និងសហគមន៍ធុរកិច្ចនៅកម្ពុជា បានវាយតម្លៃថា ការរំលាយគណបក្សសង្គ្រោះជាតិ ពុំជះឥទ្ធិពលដល់សេដ្ឋកិច្ចកម្ពុជាទេ ជាពិសេស ការវិនិយោគបរទេសដែលភាគច្រើនមកពីបណ្តាប្រទេសអាស៊ី។ ភាពជោគជ័យរបស់គណបក្សប្រជាជនកម្ពុជា ក្នុងការបោះឆ្នោតនៅឆ្នាំ២០១៨ ខាងមុខ ត្រូវបានចាត់ទុកថាជាជម្រើសដ៏ល្អបំផុត សម្រាប់ធានាស្ថិរភាពដល់ធុរកិច្ចនៅកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបន្តជំរុញបរិយាកាសវិនិយោគ និងធុរកិច្ចឱ្យបានកាន់តែល្អប្រសើរ ព្រមទាំងសហការយ៉ាងជិតស្និទ្ធជាមួយវិស័យឯកជន ក្នុងភាពជាដៃគូ ដើម្បីបង្កើតឱកាសការងារបន្ថែមទៀត និងរួមចំណែកដល់ការជំរុញកំណើនសេដ្ឋកិច្ច។

## ៧.៨. ការគាំរាមលុបភាពអនុគ្រោះពន្ធសម្រាប់ទំនិញកម្ពុជានាំចូលអឺរ៉ុប

ដើម្បីឆ្លើយតបនឹងភាពអនុគ្រោះពន្ធ សម្រាប់ទំនិញកម្ពុជានាំចូលអឺរ៉ុប និងដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលបាននិងកំពុងខិតខំប្រឹងប្រែងយកចិត្តទុកដាក់ លើការកែលម្អលក្ខខណ្ឌការងារ ការដំឡើងប្រាក់បៀវត្ស និងការផ្តល់អត្ថប្រយោជន៍ផ្សេងៗ ជូនដល់កម្មករ កម្មការិនីរាប់សែននាក់។ ការយកចិត្តទុកដាក់ចំពោះកម្មករ កម្មការិនីពីសំណាក់សម្តេចតេជោ **ហ៊ុន សែន** ដែលភាគច្រើនលើសលុបជាស្ត្រី គឺជាការលើកកម្ពស់ការគោរពសិទ្ធិមនុស្ស សិទ្ធិនិងតួនាទីរបស់ស្ត្រីក្នុងសង្គមកម្ពុជា និងជាពិសេសគឺជួយកែលម្អ ស្ថានភាពជីវភាពរស់នៅរបស់កម្មករ កម្មការិនីឱ្យកាន់តែល្អប្រសើរឡើង ក្នុងពេលដែលអ្នកនយោបាយមួយចំនួនបាននិង

កំពុងអំពាវនាវឱ្យសហរដ្ឋអាមេរិកនិងអឺរ៉ុប លុបភាពអនុគ្រោះពន្ធឬហាមឃាត់ការនាំចូលទំនិញពីកម្ពុជា ដែលទង្វើនេះជាការបំផ្លិចបំផ្លាញផលប្រយោជន៍ប្រជាជននិងប្រទេសជាតិ។

ប្រសិនបើសភាអឺរ៉ុបលុបភាពអនុគ្រោះពន្ធលើទំនិញកម្ពុជា នោះគឺមានន័យថា សភាអឺរ៉ុបមិនគ្រាន់តែមិនបានគិតគូរអំពីសិទ្ធិទទួលបានការងារនិងសុខុមាលភាពរបស់កម្មករ កម្មការិនីកម្ពុជារាប់សែននាក់ ដែលអាចនឹងទទួលរងផលប៉ះពាល់ ដោយសារការសម្រេចដោយអយុត្តិធម៌បែបនេះប៉ុណ្ណោះទេ តែទង្វើនេះគឺផ្ទុយទាំងស្រុងទៅនឹងគោលការណ៍ពាណិជ្ជកម្មអន្តរជាតិនិងការសន្យារបស់ខ្លួនក្នុងការគិតគូរចំពោះសុខុមាលភាព និងការរស់នៅរបស់ប្រជាពលរដ្ឋនៃប្រទេសកំពុងអភិវឌ្ឍ។

កម្ពុជាបាននិងកំពុងថែរក្សាទំនាក់ទំនង ដ៏ល្អដែលមានកន្លងមក ក្នុងឋានៈជាដៃគូស្មើភាព និងក្នុងនាមជារដ្ឋអធិបតេយ្យ ដែលមានសិទ្ធិស្វ័យសម្រេច ទទួលខុសត្រូវចំពោះប្រជាជន និងតម្កល់ផលប្រយោជន៍ជាតិជាធំ។ រាជរដ្ឋាភិបាលកម្ពុជា ជំរុញទំនាក់ទំនងល្អជាប្រពៃណីជាមួយបណ្ដាប្រទេសជាសមាជិកសហភាពអឺរ៉ុប ដែលបានផ្ដល់យុត្តិធម៌ដល់កម្ពុជា។ កម្ពុជាជឿជាក់ថាសភាអឺរ៉ុបនឹងមិនយកបញ្ហានេះដើម្បីធ្វើការសម្រេចចិត្ត ដែលមានលក្ខណៈនយោបាយទេ ហើយនឹងបន្តគិតគូរពីផលប្រយោជន៍ទូទៅរបស់កម្មករ កម្មការិនី និងក្រុមគ្រួសារ ជាជាងផ្ដល់សារៈសំខាន់ទៅលើតែអ្នកនយោបាយមួយក្រុមតូច។

## ៧.៩. គម្រោងរឹតត្បិតទិដ្ឋាការនិងការបង្កកទ្រព្យសម្បត្តិ

គម្រោងរឹតត្បិតទិដ្ឋាការ លើថ្នាក់ដឹកនាំនៃស្ថាប័ននានារបស់កម្ពុជាមិនមែនជាជម្រើសល្អត្រឹមត្រូវនោះទេ ហើយកម្ពុជាក៏មានសិទ្ធិចាត់វិធានការចាំបាច់មួយចំនួន តបតវិញដែរ។ ទោះបីជាសហរដ្ឋអាមេរិក និងសភាអឺរ៉ុបបានគំរាមរឹតត្បិតទិដ្ឋាការរបស់មន្ត្រីកម្ពុជាក៏ដោយ ក៏កម្ពុជានៅតែមានទំនាក់

ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីល្អជាមួយបណ្តាប្រទេសជាមិត្តមួយចំនួន ដែលជាសមាជិកសហភាពអឺរ៉ុបដែរ។

ជាងនេះទៀត កម្ពុជាក៏មិនផ្តល់សារៈសំខាន់ដល់ការគំរាមបង្កកទ្រព្យសម្បត្តិរបស់ថ្នាក់ដឹកនាំកម្ពុជានោះដែរ។ ផ្ទុយទៅវិញ រាជរដ្ឋាភិបាលកម្ពុជា នឹងចូលរួមសហការ ដើម្បីស្វែងរកឱ្យឃើញនូវទ្រព្យសម្បត្តិខុសច្បាប់ទាំងឡាយណាដែលកំពុងស្ថិតនៅអាមេរិក ឬអឺរ៉ុប។

ជារួម គម្រោងការរឹតត្បិតទិដ្ឋាការ និងការបង្កកទ្រព្យសម្បត្តិ ពុំអាចធ្វើឱ្យកម្ពុជាងាកចេញពីក្របខ័ណ្ឌច្បាប់ និងបុព្វហេតុនៃការការពារ និងទប់ស្កាត់នូវការប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាល តាមរបៀបបដិវត្តន៍ពណ៌ដែលបានកើតនៅក្នុងប្រទេសកម្ពុជាកន្លងមកទេ។ ផ្ទុយទៅវិញ វិធានការនេះគឺអាចធ្វើឱ្យទំនាក់ទំនងការទូតរវាងកម្ពុជា ជាមួយអាមេរិកនិងសហភាពអឺរ៉ុប ដើរថយក្រោយទៅវិញប៉ុណ្ណោះ។

### ៧.១០. ការផ្តាច់ជំនួយនិងបុរេនិច្ឆ័យ សម្រាប់ការបោះឆ្នោតឆ្នាំ២០១៨

ភស្តុតាងច្បាស់មួយដែលជាធាតុផ្សំនៅក្នុងសង្គមប្រជាធិបតេយ្យ គឺកម្ពុជាបានរៀបចំការបោះឆ្នោតដោយជោគជ័យ តាមបែបប្រជាធិបតេយ្យសេរីជាបន្តបន្ទាប់ ក្នុងរយៈពេលកន្លងមកនេះ។ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ កម្ពុជា នឹងរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលទី៤ និងនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ គឺការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦។ ការបោះឆ្នោតដោយទៀងទាត់តាមពេលវេលាកំណត់ ដោយមានស្ថាប័នពាក់ព័ន្ធអនុវត្តប្រកបដោយវិជ្ជាជីវៈនិងជំនាញច្បាស់លាស់ មានការទទួលខុសត្រូវខ្ពស់ និងបំពេញការងារប្រកបដោយប្រសិទ្ធភាព គឺជាធាតុផ្សំចាំបាច់ដើម្បីធានាឱ្យការបោះឆ្នោតមួយប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព។ គ.ជ.ប. ដែលបានក្លាយជាស្ថាប័ន

ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញចាប់តាំងពីឆ្នាំ២០១៤មក គឺជាយន្តការស្នូលក្នុងកិច្ចការនេះ ដែលបានពង្រឹងតួនាទីរបស់ខ្លួនកាន់តែប្រសើរថែមទៀតតាមរយៈការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីប្រទេសជាមិត្តមួយចំនួន។ ជាមួយគ្នានេះ គ.ជ.ប. ក៏បានអនុញ្ញាតឱ្យអង្គការសង្គមស៊ីវិលភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បរទេស និងអង្គការអន្តរជាតិនានា ចូលរួមសង្កេតការក្នុងគ្រប់ដំណាក់កាលនៃដំណើរការបោះឆ្នោតនាពេលខាងមុខ ដើម្បីបញ្ជាក់អំពីសុចរិតភាព និងភាពត្រឹមត្រូវនៃដំណើរការនេះ។

បច្ចុប្បន្ន កម្ពុជាមានគណបក្សនយោបាយចំនួន៣៥ ដែលបានចុះបញ្ជីនិងត្រៀមប្រកួតប្រជែងក្នុងការបោះឆ្នោតនៅឆ្នាំ២០១៨។ កម្ពុជាស្វាគមន៍រាល់ជំនួយឧបត្ថម្ភនានា សម្រាប់ការរៀបចំការបោះឆ្នោត ហើយប្តេជ្ញាចិត្តរៀបចំដំណើរការការបោះឆ្នោតនៅឆ្នាំ២០១៨ ប្រកបដោយលក្ខណៈសេរីត្រឹមត្រូវ និងយុត្តិធម៌ គ្មានការគំរាមកំហែង និងធានាបាននូវបរិយាកាសប្រកួតប្រជែងស្មើភាព ដោយមានគណបក្សដែលមាននិន្នាការនយោបាយផ្សេងៗគ្នា ចូលរួមប្រកួតប្រជែង ហើយប្តេជ្ញារៀបចំការបោះឆ្នោតនេះឱ្យបានកាន់តែល្អប្រសើរជាងការបោះឆ្នោតឆ្នាំ២០១៧ទៅទៀត ដូចដែលសហភាពអឺរ៉ុបធ្លាប់បានលើកសរសើរ នាពេលកន្លងមក។ ទន្ទឹមនឹងនេះ កម្ពុជានឹងស្វាគមន៍អ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិ ដែលមានបំណងមកសង្កេតការដូចការបោះឆ្នោតកន្លងទៅ ដើម្បីឆ្លុះបញ្ចាំងអំពីដំណើរការនៃការបោះឆ្នោតតាមបែបលទ្ធិប្រជាធិបតេយ្យ។

ទន្ទឹមនឹងជំនួយឧបត្ថម្ភលើការរៀបចំការបោះឆ្នោត ពីបណ្តាប្រទេសជាមិត្ត កម្ពុជាក៏បានត្រៀមធនធានហិរញ្ញវត្ថុខ្លួនឯង ដើម្បីធានាការប្រព្រឹត្តទៅនៃការបោះឆ្នោតឆ្នាំ២០១៨នេះ ឱ្យបានរលូននិងជោគជ័យ។ ការផ្អាកជំនួយសម្រាប់កិច្ចការបោះឆ្នោតនិងវិធានការដាក់ទណ្ឌកម្ម មិនមែនជាជម្រើស

ត្រឹមត្រូវដើម្បីពង្រឹងគុណភាពលទ្ធិប្រជាធិបតេយ្យនៅកម្ពុជានោះទេ ហើយការផ្អាកជំនួយនេះ ក៏មិនប៉ះពាល់ដល់ដំណើរការបោះឆ្នោតនៅកម្ពុជាដែរ។

ទោះបីការបោះឆ្នោតឆ្នាំ២០១៣កន្លងមក មានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ តែគណបក្សសង្គ្រោះជាតិមួលបង្កាច់ និងបំផ្លើសថា គ.ជ.ប. លួចបន្លំសន្លឹកឆ្នោត ដើម្បីឱ្យគណបក្សប្រជាជនកម្ពុជាបានឈ្នះឆ្នោត។ តាមរយៈការចោទប្រកាន់នេះ មេដឹកនាំគណបក្សសង្គ្រោះជាតិបានកៀរគរបាតុករ ឱ្យធ្វើបាតុកម្មប្រឆាំងតវ៉ាអស់រយៈពេល១ឆ្នាំ តាមបែបបដិវត្តន៍ពណ៌ផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ ក្នុងរូបភាពផ្សេងៗ ដូចជា (១) កុហកថាស្ថានទូតនៃប្រទេសប្រជាធិបតេយ្យមួយបានប្រាប់ថា គណបក្សសង្គ្រោះជាតិឈ្នះឆ្នោត (២) បំផុសឱ្យប្រជាជន កងកម្លាំងប្រដាប់អាវុធ និងសង្គមស៊ីវិលក្រោកឈរឡើងប្រឆាំង និងបែរចុងអាវុធប្រឆាំងរាជរដ្ឋាភិបាល (៣) ចោទថាគណបក្សប្រជាជនកម្ពុជានិង គ.ជ.ប. លួចសន្លឹកឆ្នោត តាមវិធីលួចបន្លំសន្លឹកឆ្នោតខ្យល់ និងយួនបោះឆ្នោតឱ្យ (៤) បង្រៀនបាតុករឱ្យជៀលត្មិះថ្នាក់ដឹកនាំ និងសមាជិកគណបក្សប្រជាជនកម្ពុជាថា «ពួកអាក្បាលយួន ខ្លួនខ្មែរ» និងរើសអើងពូជសាសន៍ចំពោះប្រជាជនវៀតណាម (៥) ចោទថាទឹកខ្មៅលុបជ្រះ ដោយមនុស្សម្នាក់អាចបោះឆ្នោត២ឬ៣កន្លែងបាន (៦) កុហកថាថ្ងៃស្អែក សម្តេចតេជោ **ហ៊ុន សែន** នឹងលាលែងពីតំណែង តែយួនហៅទៅដាក់ថ្នាំ ហើយត្រឡប់មកវិញ មិនព្រមលាលែងតំណែង (៧) កុហកប្រជាពលរដ្ឋថា ប្រសិនបើមិនផ្តួលរំលំរដ្ឋអំណាចស្របច្បាប់នេះទេ ៣ឬ៤ឆ្នាំទៀតយួនមកគ្រប់គ្រង ប្រទេសកម្ពុជាទាំងមូល (៨) ណែនាំឱ្យបាតុករប្រើពាក្យថា «ហ៊ុន សែន អើយ ចុះចេញទៅ» នៅគ្រប់ពេលធ្វើបាតុកម្ម (៩) បិទផ្លូវដោយសកម្មជនរបស់គណបក្សប្រឆាំង ធ្វើជានគរបាលចរាចរណ៍ (១០) ធ្វើបាតុកម្មពីអហិង្សាឈានទៅហិង្សា ដែលបានបំផ្លាញទ្រព្យសម្បត្តិនិងបង្ហូរឈាម

(១១) បោកបញ្ឆោតកម្មករ ដោយយកប្រាក់ខែធ្វើជានុយ ដើម្បីអូសទាញពួកគេឱ្យធ្វើបាតុកម្ម។ល។ ម្យ៉ាងវិញទៀត កឹម សុខា បាននិយាយថា «គណបក្សប្រជាជន ឈ្នះក៏ចាញ់ ចាញ់ក៏ចាញ់» មានន័យថា ទោះបីជាគណបក្សប្រជាជនកម្ពុជាឈ្នះ ក៏គណបក្សសង្គ្រោះជាតិត្រូវតែផ្តួលរំលំ និងដណ្តើមអំណាចដែរ។ ល្បែងនយោបាយដ៏កខ្វក់នេះបានធ្វើឱ្យប្រជាជនមួយចំនួនតូច ដែលមិនបានយល់ដឹង និងចូលរួមហែរហមបាតុកម្មអស់រយៈពេល១ឆ្នាំ ដែលបានបង្កើតឱ្យមានអំពើហិង្សា ប៉ះពាល់សណ្តាប់ធ្នាប់សង្គម នៅតាមទីកន្លែងមួយចំនួននៅរាជធានីភ្នំពេញ។ អំពើរបស់មេដឹកនាំគណបក្សសង្គ្រោះជាតិបានបង្កឱ្យមានការបែកបាក់សង្គម អសន្តិសុខ អស្ថិរភាពនយោបាយ របួសស្នាម និងការបាត់បង់អាយុជីវិតមនុស្ស។

រោងចក្រនិងសហគ្រាសរាប់រយត្រូវបានបិទទ្វារ ទ្រព្យសម្បត្តិសាធារណៈនិងឯកជនមួយចំនួនត្រូវបានបំផ្លាញ ប្រជាជននិងក្រុមហ៊ុនជាច្រើនបានផ្ទេរលុយទៅបរទេសដោយភ័យខ្លាចសង្គ្រាម វិនិយោគិនមួយចំនួនបានផ្អាកការវិនិយោគដើម្បីរង់ចាំមើលសភាពការណ៍ថ្មី ឬបានបង្វិលទុនទៅវិនិយោគនៅប្រទេសផ្សេង។ ការធ្វើបាតុកម្មនាពេលនោះ អាចធ្វើឱ្យប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងធុរកិច្ច ប្រសិនបើរាជរដ្ឋាភិបាលគ្មានសមត្ថភាពគ្រប់គ្រងស្ថានការណ៍បានល្អនោះទេ។

លទ្ធផលនៃការបោះឆ្នោតឆ្នាំ២០១៧ ធៀបនឹងការបោះឆ្នោតឆ្នាំ២០១៣ គឺគណបក្សប្រជាជនកម្ពុជា កើនជាង៣០ម៉ឺនសំឡេង ពី៣ ២៣៥ ៩៦៩ សំឡេង ទៅ៣ ៥៤០ ០៥៦សំឡេង ចំណែកគណបក្សសង្គ្រោះជាតិ កើនជាង១០ម៉ឺនសំឡេង ពី២ ៩៤៦ ១៧៦សំឡេង ទៅ៣ ០៥៦ ៨២៤សំឡេង។ កំណើននេះ ជាភស្តុតាងបញ្ជាក់យ៉ាងច្បាស់ថា គណបក្សប្រជាជនកម្ពុជាពិតជាឈ្នះការបោះឆ្នោតឆ្នាំ២០១៣ និងការបោះឆ្នោតមុនៗ ដោយស្មោះត្រង់និង

យុត្តិធម៌។ បន្ថែមលើនេះទៀត ប្រសិនបើគណបក្សប្រជាជនកម្ពុជាបន្លំសន្លឹកឆ្នោត ឬលុបឈ្មោះអ្នកបោះឆ្នោតដែលគាំទ្រគណបក្សសង្គ្រោះជាតិចំនួនជាង១,២៥លាននាក់ ឬ១,០៤លាននាក់ ដូចការប្រឌិតរបស់អង្គការ COMFREL វិទ្យាស្ថាន NDI និងមេដឹកនាំគណបក្សសង្គ្រោះជាតិមែននោះ នៅឆ្នាំ២០១៧ គណបក្សប្រជាជនកម្ពុជាត្រូវមានសំឡេងគាំទ្រតិចជាង៣លាននាក់ ហើយគណបក្សសង្គ្រោះជាតិត្រូវមានសំឡេងគាំទ្រច្រើនជាង៤លាននាក់។ ផ្ទុយទៅវិញ គណបក្សប្រជាជនកម្ពុជាបានទទួលសំឡេងគាំទ្រច្រើនជាងគណបក្សសង្គ្រោះជាតិចំនួន៥០ម៉ឺនសំឡេង ដែលច្រើនជាងសំឡេងគាំទ្រឆ្នាំ២០១៣ទៅទៀត។ ទោះជាគណបក្សប្រជាជនកម្ពុជាឈ្នះច្រើនយ៉ាងដូច្នេះក៏ដោយ ក៏គណបក្សសង្គ្រោះជាតិ ពុំមានហេតុផលណាមួយសម្រាប់បដិសេធ ឬតវ៉ាលទ្ធផលបោះឆ្នោតនេះទេ ពីព្រោះសម្រាប់ការបោះឆ្នោតឆ្នាំ២០១៧នេះ ការរៀបចំប្រព័ន្ធចុះបញ្ជីឈ្មោះអ្នកបោះឆ្នោត ត្រូវបានជួយឧបត្ថម្ភដោយប្រទេសជប៉ុន។ ភស្តុតាងយ៉ាងច្បាស់មួយបន្ថែមទៀត គឺខែតុលា ឆ្នាំ២០១៣ បន្ទាប់ពីការបោះឆ្នោត៣ខែមក មានការចុះឈ្មោះអ្នកបោះឆ្នោតថ្មីចំនួនប្រមាណ១៨០ ០០០នាក់ ដែលភាគច្រើនជាយុវជន ទើបគ្រប់អាយុ១៨ឆ្នាំ។ ដូច្នេះតួលេខនេះបញ្ជាក់យ៉ាងច្បាស់ថា ពុំមានការលុបឈ្មោះអ្នកគាំទ្រគណបក្សប្រឆាំងជាង១លាននាក់ ដូចការចោទ ដើម្បីធ្វើជាលេសក្នុងការបដិសេធលទ្ធផលបោះឆ្នោតនោះទេ។ **តើឈ្មោះជាង១លាននាក់នៅឯណា? ហេតុដូចម្តេចបានជាមិនមកចុះឈ្មោះ?**

គណបក្សប្រជាជនកម្ពុជាមានជំនឿយ៉ាងមុតមាំថា នឹងទទួលបានជោគជ័យក្នុងការបោះឆ្នោតឆ្នាំ២០១៨ ហើយការរំលាយគណបក្សសង្គ្រោះជាតិ គឺជាករណីអនុវត្តច្បាប់សុទ្ធសាធ ដោយហេតុថា គណបក្សនេះបានធ្វើសកម្មភាពបំផ្លាញលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា តាមរយៈការឃុបឃិតជាមួយ

បរទេសនិងការទទួលហិរញ្ញវត្ថុពីបរទេស ដើម្បីធ្វើសកម្មភាពផ្តួលរំលំរដ្ឋអំណាចស្របច្បាប់។ ផ្ទុយពីការសន្និដ្ឋានរបស់អ្នកនយោបាយអាមេរិកមួយចំនួនដែលជាសម្ព័ន្ធមិត្តរបស់គណបក្សប្រឆាំងដែលថា «គណបក្សប្រជាជនកម្ពុជា ដឹងខ្លួនថាចាញ់ឆ្នោតនៅឆ្នាំ២០១៨ ទើបរំលាយគណបក្សសង្គ្រោះជាតិ» គឺពុំមានមូលដ្ឋានទាល់តែសោះ និងមានចរិតប្រឌិតរឿងដើម្បីបន្តចលនាគាំទ្រគណបក្សក្បត់ជាតិនេះ ហើយពួកគេពុំដែលបានស្គាល់កម្ពុជាច្បាស់ និងពុំដែលមកមើលការពិតនៃការវិវត្តជាវិជ្ជមាននៅកម្ពុជាដែរ។ ក្រុមអ្នកនយោបាយនេះបានទទួលព័ត៌មានតែម្ខាងពីគណបក្សប្រឆាំង និងព័ត៌មានតាមបណ្តាញសារព័ត៌មាន ដែលចុះផ្សាយអំពីភាពអវិជ្ជមាន និងខុសពីការពិតនៅកម្ពុជា ក្នុងពេលជនបរទេសជាច្រើនដែលបានមកកាន់កម្ពុជាផ្ទាល់ មានការភ្ញាក់ផ្អើល និងកោតសរសើរចំពោះការអភិវឌ្ឍលើសពីការនឹកស្មានរបស់ពួកគេ។

ដូចគ្នានេះដែរ ចំពោះការបោះឆ្នោតនៅកម្ពុជា អ្នកនយោបាយខាងលើក៏ពុំបានដឹងអំពីសភាពការណ៍ពិត នៃដំណើរការរៀបចំរហូតដល់ថ្ងៃបោះឆ្នោត នីតិវិធីបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ហើយជាពិសេស ការទទួលស្គាល់លទ្ធផល តាមរយៈហត្ថលេខារបស់ភ្នាក់ងារគណបក្សនិងអ្នកសង្កេតការណ៍នៅគ្រប់ការិយាល័យទាំងអស់ ប៉ុន្តែបែរជាចោទថាការបោះឆ្នោតនៅឆ្នាំ២០១៣មានការលួចបន្លំ ហើយធ្វើការសន្និដ្ឋានដោយងងឹតងងល់ថា សម្តេចតេជោ **ហ៊ុន សែន** ខ្លាចចាញ់ឆ្នោត ទើបរំលាយគណបក្សសង្គ្រោះជាតិ។ នៅឆ្នាំ២០១២ គណបក្សប្រជាជនកម្ពុជាទទួលបានសំឡេង៣ ៦៣១ ០៨២ ហើយនៅឆ្នាំ២០១៣ បានថយចុះមកនៅត្រឹម ៣ ២៣៥ ៩៦៩សំឡេង ពោលគឺថយចុះចំនួន៤០ម៉ឺនសំឡេង ដោយសារមូលហេតុមួយចំនួន ដូចជា ការប្រឡាច់បញ្ចូលគ្នានៃគណបក្សប្រឆាំងទាំងពីរ ក៏ដូចជាការនិយាយកុហក ការបំផ្លើស និងការប្រឌិតរឿង ជាពិសេស ការសន្យាខ្យល់មុនការបោះឆ្នោតចំពោះប្រាក់

បៀវត្សរ៍២៥០ដុល្លាររបស់មន្ត្រីរាជការ និងកម្លាំងប្រដាប់អាវុធ ប្រាក់ខែកម្មករ ១៥០ដុល្លារ និងឧបត្ថម្ភចាស់ជរា១០ដុល្លារក្នុងមួយខែ។ល។

យើងអាចធ្វើការសន្និដ្ឋានយ៉ាងច្បាស់ អំពីការថយចុះនៃសំឡេងគាំទ្រថា អ្នកដែលនៅតែបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា គឺអ្នកដែលស្មោះស្ម័គ្រ ជាមួយគណបក្ស។ ភស្តុតាងដែលអាចបញ្ជាក់បន្ថែមគឺលទ្ធផលនៃការបោះឆ្នោតឆ្នាំ២០១៧ ដែលគណបក្សប្រជាជនកម្ពុជាបានទទួលសំឡេងបន្ថែមចំនួន៣០ម៉ឺនសំឡេងទៀត នៅពេលគណបក្សប្រឆាំងបានទទួលតែ១០ម៉ឺនសំឡេងបន្ថែមប៉ុណ្ណោះ។ ដូច្នេះ គណបក្សប្រជាជនកម្ពុជាជឿជាក់យ៉ាងមុតមាំថា ឆ្នាំ២០១៨ សំឡេងគាំទ្រនឹងកើនឡើងច្រើនជាងសំឡេងគាំទ្រនៅឆ្នាំ២០១៧ថែមទៀត ហើយឈ្នះដាច់តែម្តង ដោយហេតុផលមួយចំនួនដូចជា (១) ការប៉ុនប៉ងធ្វើបដិវត្តន៍ពណ៌ រហូតដល់ឆ្នាំ២០១៧ ត្រូវបានលាតត្រដាង (២) ការសន្យាខ្យល់ពុំមានប្រសិទ្ធភាពទៀតទេ ពីព្រោះប្រជាពលរដ្ឋកាន់តែយល់ដឹងអំពីការភូតភរបោកប្រាស់របស់ថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិ (៣) ប្រជាពលរដ្ឋបាត់ជំនឿលើថ្នាក់ដឹកនាំអតីតគណបក្សសង្គ្រោះជាតិ ដោយសារការបែកធ្លាយរឿងអាស្រូវជាច្រើនដូចជា ស្រី ល្បែង និងបក្សពួកនិយម ជាដើម (៤) អតីតគណបក្សសង្គ្រោះជាតិបានបោកប្រាស់អ្នកគាំទ្រ ដោយស្បថនៅមុខប្រាសាទអង្គរវត្តថានឹងមិនចូលធ្វើការជាសមាជិករដ្ឋសភា ដែលខ្លួនចោទថាជាចោរនោះទេ តែទីបំផុតបែរជាតថ្លៃយកតំណែងដើម្បីចូលរដ្ឋសភា ដោយក្បត់នឹងការសន្យាក្តែងៗ ដើម្បីបោកពួកគេឱ្យមកធ្វើបាតុកម្ម ដែលបណ្តាលឱ្យអ្នកគាំទ្របាត់ជំនឿទុកចិត្តលើគណបក្សនេះ (៥) រាជរដ្ឋាភិបាលបានដឹកនាំប្រទេសបានជោគជ័យ ដោយជំរុញកំណើនសេដ្ឋកិច្ចក្នុងអត្រាប្រចាំឆ្នាំ៧% អត្រាភាពក្រីក្រថយនៅត្រឹមប្រហែល១៣% កំណើនការងារ កំណើនប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់

អាវុធ ព្រមទាំងប្រាក់បៀវត្សកម្មករមានការកើនឡើងជាលំដាប់ ប្រៀបធៀបនឹងប្រទេសជាច្រើននៅអាស៊ី។

រាជរដ្ឋាភិបាលកម្ពុជា សូមធ្វើការអំពាវនាវដល់មជ្ឈដ្ឋានអមិត្តមួយចំនួនដែលមានសកម្មភាពបង្កវិទ្ធង្សនា និងឧបសគ្គដល់ការអភិវឌ្ឍកម្ពុជា ឱ្យបញ្ឈប់រាល់សកម្មភាពរបស់ខ្លួន ដើម្បីទុកឱកាសឱ្យប្រជាជននិងរាជរដ្ឋាភិបាលកម្ពុជាធ្វើការអភិវឌ្ឍប្រទេសកាន់តែល្អប្រសើរថែមទៀត។



*រូបភាពទី១២៖ ទិដ្ឋភាពរាជធានីភ្នំពេញនាពេលបច្ចុប្បន្ន*

រាជរដ្ឋាភិបាលកម្ពុជាសូមស្វាគមន៍រាល់ការជួយជ្រោមជ្រែង និងកិច្ចសហការពីអ្នកនយោបាយនិងស្ថាប័នបរទេស និងបណ្ដាប្រទេសនានាក្នុងការរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រជាជន និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកសាងមូលដ្ឋានគ្រឹះនៃនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងការអភិវឌ្ឍ នៅកម្ពុជា។

បដិវត្តន៍ពណ៌មិនមែនជាការការពារ និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ដូចក្រុមបក្សប្រឆាំងយកមកធ្វើជាអាជីវកម្មនយោបាយនោះទេ ប៉ុន្តែ គឺជាចលនាគាស់រំលើងរបបដឹកនាំដែលមិនយល់ព្រមដើរតាមគោល

នយោបាយ និងការបង្គាប់បញ្ជារបស់មហាអំណាចបស្ចិមប្រទេសនិងសម្ព័ន្ធមិត្ត ដើម្បីផលប្រយោជន៍មនោគមវិជ្ជា ឥទ្ធិពលនយោបាយ និងភូមិសាស្ត្រនយោបាយរបស់ខ្លួនតែប៉ុណ្ណោះ។

ការប្រឆាំងចលនាបដិវត្តន៍ពណ៌ តាមរយៈការរំលាយអង្គការចាត់តាំងនយោបាយ ដោយវិធានការនីតិរដ្ឋ គឺដើម្បីធានាសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម និងការអភិវឌ្ឍ ហើយរាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្ត បន្តដឹកនាំប្រទេសស្របតាមរដ្ឋធម្មនុញ្ញ ដោយគោរពតាមគោលការណ៍នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងការគោរពសិទ្ធិមនុស្ស។ ដោយយល់ច្បាស់អំពីតម្លៃនៃសន្តិភាពនិងការអភិវឌ្ឍ រាជរដ្ឋាភិបាលកម្ពុជាមិនអនុញ្ញាតឱ្យជនណាម្នាក់ ឬក្រុមណាមួយ ធ្វើសកម្មភាពបំផ្លាញសន្តិភាពនិងសមិទ្ធផលដែលសម្រេចបានដោយលំបាក ដែលអាចធ្វើឱ្យកម្ពុជាធ្លាក់ចូលក្នុងភ្លើងសង្គ្រាមសាជាថ្មីទៀតបានទេ។ ប្រសិនបើសង្គ្រាមពិតជាកើតមានឡើងមែននោះ ប្រជាជនកម្ពុជាគឺជាអ្នកទទួលរងគ្រោះ ហើយមិនមែនជាជនបរទេសដែលនៅខាងក្រៅប្រទេសនោះទេ។